សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMICS



# ព័ត៌មាន សាលាក្រោយបរិញ្ញាបត្រ ២០២៥

## GRADUATE SCHOOL PROSPECTUS 2025

# ប្លង់ 3D នៃអគារទាំងអស់របស់
# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

1. Building D
2. Building A
3. Building C
4. Building E
5. Building I
6. Building F
7. Building H
8. Building G
9. Building B30.
10. Hall B
11. Hall A
12. Building B




**វេន និងម៉ោងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាលាក្រោយបរិញ្ញាបត្រ**
**នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

- វេន ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ៖ ម៉ោង១៧:៣០-២០:០០
- វេន ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ៖ ថ្ងៃសៅរ៍ ម៉ោង១៣:០០-២០:៣០ និង
  ថ្ងៃអាទិត្យ ម៉ោង០៧:០០-១២:០០

# មាតិកា


## ផ្នែកទី១ សាកលវិទ្យាល័យ និងសាលាក្រោយបរិញ្ញាបត្រ

១. សាកលវិទ្យាល័យ ---- 1

២. សាលាក្រោយបរិញ្ញាបត្រ ---- 3

## ផ្នែកទី២ ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

១. គោលការណ៍បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ---- 7

២. សេចក្តីណែនាំស្តីពីការសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ---- 10

៣. សេចក្តីណែនាំស្តីពីការសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ---- 12

៤. គោលការណ៍ផ្តល់ក្រេឌីតសិក្ខាសាលា ---- 16

៥. គោលការណ៍សកម្មភាពសង្គមសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ---- 17

៦. គោលការណ៍បង់ថ្លៃសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ---- 19

៧. គម្រោងការជ្រើសរើសការសរសេររបាយការណ៍ស្រាវជ្រាវឬនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ---- 20

៨. កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ---- 21

៩. ស្ថិតិនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០២៤ ---- 27

## ផ្នែកទី៣ ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

១. គោលការណ៍បណ្តុះបណ្តាលបណ្ឌិត ---- 31

២. គោលការណ៍បង្កើតគណៈកម្មការនានាសម្រាប់ថ្នាក់បណ្ឌិត ---- 36

៣. ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ---- 42

៤. ថ្នាក់បណ្ឌិតនឹងបើកនៅពេលឆាប់ៗ ---- 43

## ផ្នែកទី៤ គ្រូណែនាំ និងគ្រូជំនួយ សារពីនិស្សិត ប្រតិទិនសម្រាប់ជំនាន់និងជំហាននីមួយៗ និងសកម្មភាពក្រៅកម្មវិធីសិក្សា

១. បញ្ជីរាយនាមគ្រូណែនាំ និងគ្រូជំនួយសម្រាប់ការណែនាំនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ---- 45

២. បញ្ជីរាយនាមគ្រូណែនាំ និងគ្រូជំនួយសម្រាប់ការណែនាំនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ---- 52

៣. សារពីនិស្សិត ---- 57

៤. ប្រតិទិនសម្រាប់ជំនាន់ និងជំហាននីមួយៗ ពេលចូលរៀន និងពេលបញ្ចប់ ---- 65

៥. សកម្មភាពក្រៅកម្មវិធីសិក្សារបស់សាលាក្រោយបរិញ្ញាបត្រ ---- 66

## ផ្នែកទី៥ ថ្នាក់ដឹកនាំ និងមន្ត្រី

១. ថ្នាក់ដឹកនាំសាលាក្រោយបរិញ្ញាបត្រ ---- 73

២. មន្ត្រីទទួលបន្ទុកការងាររបស់សាលាក្រោយបរិញ្ញាបត្រ ---- 74

# ផ្នែកទី១
# សាកលវិទ្យាល័យ
# និង
# សាលាក្រោយបរិញ្ញាបត្រ

# ១. សាកលវិទ្យាល័យ

## ១.១. ប្រវត្តិសង្ខេប

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (**ស.ភ.ន.វ.ស.**) គឺជាគ្រឹះស្ថានឧត្តមសិក្សាដែលកើតមុនគេនៅកម្ពុជា។ សាកលវិទ្យាល័យនេះបានបង្កើតជាដំបូងនៅឆ្នាំ១៩៤៩ ដែលមានឈ្មោះថា "**វិទ្យាស្ថានសិក្សាច្បាប់ និងសេដ្ឋកិច្ច**" បន្ទាប់មកក៏ត្រូវបានប្រែក្លាយជា "**មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**" ហើយត្រូវបានដាក់ឱ្យស្ថិតនៅក្រោម "**សាកលវិទ្យាល័យភ្នំពេញ**" នៅឆ្នាំ១៩៥៧។ ជាអកុសល សាកលវិទ្យាល័យនេះត្រូវបានបិទទាំងស្រុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ប៉ុន្តែត្រូវបានបើកឡើងវិញនៅឆ្នាំ១៩៨២ ដែលមានឈ្មោះថា "**សាលាកម្មាភិបាលរដ្ឋបាល និងនីតិសាស្ត្រ**"។ នៅឆ្នាំ១៩៩២ សាកលវិទ្យាល័យនេះត្រូវបានប្ដូរឈ្មោះមកជា "**មហាវិទ្យាល័យនីតិសាស្ត្រ**"។ ជាថ្មីម្ដងទៀត នៅឆ្នាំ១៩៩៤ សាកលវិទ្យាល័យនេះត្រូវបានប្ដូរឈ្មោះជា "**មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**" ហើយដាក់ឱ្យនៅក្រោម "**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**"។

នៅដើមសតវត្សថ្មីនេះ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានអភិវឌ្ឍស្ថាប័នរបស់ខ្លួនគួរឱ្យកត់សម្គាល់។ នៅឆ្នាំ២០០៣ សាកលវិទ្យាល័យបានប្រែក្លាយពី "**មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**" ទៅជា "**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**" តាមអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣។ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានមហាវិទ្យាល័យចំណុះចំនួន៤ និងថ្នាក់ស្មើមហាវិទ្យាល័យចំនួន១។ មហាវិទ្យាល័យទាំង៤ និងថ្នាក់ស្មើមហាវិទ្យាល័យចំនួន១ មានឈ្មោះដូចតទៅនេះ៖ ១.មហាវិទ្យាល័យនីតិសាស្ត្រ ២. មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ៣. មហាវិទ្យាល័យរដ្ឋបាលសាធារណៈ ៤. មហាវិទ្យាល័យសេដ្ឋកិច្ចព័ត៌មានវិទ្យា និង ៥. ថ្នាក់ក្រោយបរិញ្ញាបត្រ។ នៅឆ្នាំ២០០៧ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចត្រូវបានប្រែក្លាយជា "**គ្រឹះស្ថានសាធារណៈរដ្ឋបាល**" តាមអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧។



សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## ១.២. ផែនការយុទ្ធសាស្ត្រ

### ១.២.១. ចក្ខុវិស័យ

ជាសាកលវិទ្យាល័យឈានមុខនៅកម្ពុជា និងទទួលស្គាល់ជាអន្តរជាតិ ចំពោះគុណភាពអប់រំ ការស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងនវានុវត្តន៍។

### ១.២.២. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ***ស.ភ.ន.វ.ស.*** បានដាក់ចេញនូវបេសកកម្មដូច ខាងក្រោម៖

1. ផ្តល់ឲ្យនិស្សិតនូវចំណេះដឹង ជំនាញ សមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងការទទួលខុសត្រូវសង្គម ដើម្បីឆ្លើយតបនឹងតម្រូវការ ទីផ្សារការងារ និងសង្គមជាតិ
2. លើកកម្ពស់សកម្មភាពស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងនវានុវត្តន៍
3. បង្កើនសហប្រតិបត្តិការជាតិ និងអន្តរជាតិ
4. លើកកម្ពស់ការសិក្សាពេញមួយជីវិត និងការយល់ដឹងអន្តរវប្បធម៌។

### ១.២.៣. គោលដៅ

ដើម្បីសម្រេចបេសកកម្មខាងលើ ***ស.ភ.ន.វ.ស.*** មានគោលដៅមួយចំនួនដូចខាងក្រោម៖

- អភិវឌ្ឍគោលនយោបាយរៀននិងបង្រៀន ប្រកបដោយការទាក់ទាញ និងគំនិត ច្នៃប្រឌិត
- អភិវឌ្ឍការស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងនវានុវត្តន៍
- បង្កើនកិច្ចសហប្រត្តិការជាតិ និងអន្តរជាតិ
- ធានាដំណើរការអភិបាលកិច្ចល្អដែលបង្កើត បាននូវភាពខ្លាំង និងឧត្តមភាពអប់រំជានិរន្តរ៍របស់សាកលវិទ្យាល័យ
- លើកកម្ពស់ការសិក្សាពេញមួយជីវិត និងបង្កើតសៀវភៅមគ្គុទ្ទេសក៍ការងារ និងវិជ្ជាជីវៈ



# ២. សាលាក្រោយបរិញ្ញាបត្រ

## ២.១. ប្រវត្តិសង្ខេប

ថ្នាក់ក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញធំៗ ២ គឺ៖ នីតិសាស្ត្រ និងធុរកិច្ច។ នៅពេលបើកដំបូងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តម្រូវឱ្យសិក្សារយៈពេល ២ឆ្នាំ ដោយចែកចេញជា ៦វគ្គ (6 terms) ដែលក្នុងនោះ ឆ្នាំទី១មាន ៣វគ្គ និងឆ្នាំទី២ មាន ៣វគ្គ។ នៅឆ្នាំសិក្សា២០១០-២០១១ និងឆ្នាំសិក្សា២០១១-២០១២ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ត្រូវបានអនុញ្ញាតឱ្យដំណើរការបណ្តុះបណ្តាលជា ៥វគ្គ វិញ ដែលក្នុងនោះឆ្នាំទី១មាន ៣វគ្គ និងឆ្នាំទី២មាន ២វគ្គ។ ប៉ុន្តែចាប់ពីឆ្នាំសិក្សា២០១២-២០១៣ រហូតមកដល់បច្ចុប្បន្ន ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ត្រូវបានកំណត់ជាឆមាសវិញ ដែលតម្រូវឱ្យសិក្សា២ឆមាសនៅឆ្នាំទី១ និង២ឆមាសនៅឆ្នាំទី២។

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបានអនុញ្ញាតដោយក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ១៨៥២ អយក.ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២។ ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនេះ វាជាបន្ទុករបស់ថ្នាក់ក្រោយបរិញ្ញាបត្រ នាំឱ្យថ្នាក់ក្រោយបរិញ្ញាបត្រត្រូវបានពង្រីកខ្លួន និងបានប្តូរឈ្មោះពី “**ថ្នាក់ក្រោយបរិញ្ញាបត្រ**” ទៅជា “**សាលាក្រោយបរិញ្ញាបត្រ**” តាមអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣។ សាលាក្រោយបរិញ្ញាបត្រ មានការិយាល័យចំណុះចំនួន២គឺ៖ “**ការិយាល័យបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**” និង “**ការិយាល័យបណ្តុះបណ្តាលថ្នាក់បណ្ឌិត**” តាមប្រកាសអន្តរក្រសួងលេខ ១៤៨៨ អយក.ប្រក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤។ “**ការិយាល័យបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**” ត្រូវបានប្តូរឈ្មោះពី “**ការិយាល័យនីតិសាស្ត្រ និងធុរកិច្ច**” ចំណែកឯ “**ការិយាល័យបណ្តុះបណ្តាលថ្នាក់បណ្ឌិត**” វាជាការិយាល័យបង្កើតថ្មី សម្រាប់ឆ្លើយតបទៅនឹងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។




បន្ទប់សាលាក្រោយបរិញ្ញាបត្រ

ស្លាកសញ្ញាសាលាក្រោយបរិញ្ញាបត្រនៅទទឹងផ្លូវដើរចន្លោះអគារ A និង C មើលពីកើតទៅលិច




ស្លាកសញ្ញាសាលាក្រោយបរិញ្ញាបត្រនៅទទឹងផ្លូវដើរចន្លោះអគារ A និង C មើលពីលិចទៅកើត



## ២.២. ផែនការយុទ្ធសាស្ត្ររបស់សាលាក្រោយបរិញ្ញាបត្រ

### ២.២.១. ចក្ខុវិស័យ

ជាសាលាក្រោយបរិញ្ញាបត្រឈានមុខនៅកម្ពុជា និងទទួលស្គាល់ជាអន្តរជាតិចំពោះគុណភាពអប់រំ។

### ២.២.២. បេសកកម្ម

ដើម្បីសម្រេចបានចក្ខុវិស័យខាងលើ សាលាក្រោយបរិញ្ញាបត្រ បានដាក់ចេញនូវបេសកកម្ម ដូចខាងក្រោម៖

1. ផ្តល់ឲ្យនិស្សិតនូវចំណេះដឹង ជំនាញ សមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងការ ទទួលខុសត្រូវសង្គម ដើម្បី ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងសង្គមជាតិ
2. លើកកម្ពស់គុណភាពនៃការស្រាវជ្រាវ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ
3. ផ្តល់ឱកាសឲ្យមានការច្នៃប្រឌិតទាក់ទងនឹងជំនាញ
4. លើកកម្ពស់ការសិក្សាពេញមួយជីវិត និងការយល់ដឹងអន្តរវប្បធម៌។

### ២.២.៣. គោលដៅ

ដើម្បីសម្រេចបេសកកម្មខាងលើ សាលាក្រោយបរិញ្ញាបត្រមានគោលដៅបង្កើតយន្តការដើម្បីធានាគុណភាពអប់រំ ដែលត្រូវបានទទួលស្គាល់ ទាំងកម្រិតជាតិ និងអន្តរជាតិ។



# មន្ត្រីទាំងអស់នៃសាលាក្រោយបរិញ្ញាបត្រ



# ផ្នែកទី២
# ការបណ្តុះបណ្តាល
# ថ្នាក់បរិញ្ញាបត្រ
# ជាន់ខ្ពស់

# ១. គោលការណ៍បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

គោលបំណងនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច គឺដើម្បីលើកកម្ពស់គុណភាពអប់រំក្នុងការបំពេញទំនើបភាវូបនីយកម្មនៃចំណេះដឹងឲ្យកាន់តែមានភាពទូលំទូលាយ សំដៅចូលរួមចំណែកក្នុងការកសាងធនធានមនុស្សរបស់ព្រះរាជាណាចក្រកម្ពុជា។ ការបណ្តុះបណ្តាលនេះបង្កលក្ខណៈឲ្យនិស្សិតគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលមានសញ្ញាបត្រគ្រប់ជំនាញចាប់ពីបរិញ្ញាបត្រឡើងទៅ ដែលចង់បន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្រ្ត ឯកទេសនីតិឯកជន ឬរដ្ឋបាលសាធារណៈ បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសហិរញ្ញវត្ថុ ឬឯកទេសគ្រប់គ្រងមានឱកាសសិក្សាស៊ីជម្រៅបន្ថែមទៀត។

## ១.១. លក្ខខណ្ឌជ្រើសរើសនិស្សិត

### ១.១.១. លក្ខខណ្ឌចូលរៀនថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់

បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រផ្សេងៗ ឬមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិតជំនាញផ្សេងខុសមុខជំនាញបរិញ្ញាបត្រជាន់ខ្ពស់ដែលនឹងចូលរៀន ត្រូវរៀនត្រៀម១វគ្គ (៤ខែ) ឲ្យបានជោគជ័យសិន ទើបអាចចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឆ្នាំទី១បាន។

### ១.១.២. លក្ខខណ្ឌចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឆ្នាំទី១

ចំពោះបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្រ្ត បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្រនីតិសាស្រ្ត ឬបរិញ្ញាបត្រ ដែលមានតម្លៃស្មើឬជំនាញប្រហាក់ប្រហែល ឬបរិញ្ញាបត្រមុខជំនាញដទៃនិងមានបរិញ្ញាបត្ររងនៃមុខជំនាញ ខាងលើបន្ថែមមួយទៀត។

ចំពោះបរិញ្ញាបត្រជាន់ខ្ពស់ហិរញ្ញវត្ថុ និងបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រង បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្រ្តសេដ្ឋកិច្ច បរិញ្ញាបត្រធុរកិច្ច បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ ឬបរិញ្ញាបត្រដែលមានតម្លៃស្មើឬជំនាញប្រហាក់ប្រហែល ឬបរិញ្ញាបត្រមុខជំនាញដទៃនិងមានបរិញ្ញាបត្ររងនៃមុខជំនាញខាងលើបន្ថែមមួយទៀត។

បេក្ខជនដែលបានបំពេញលក្ខខណ្ឌ ចំណុច១.១.១ "លក្ខខណ្ឌចូលរៀនថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់" ខាងលើអាចចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមជំនាញដែលបានរៀនត្រៀម។

### ១.១.៣. ការធ្វើតេស្តចូលរៀនថ្នាក់ត្រៀម និងថ្នាក់ឆ្នាំទី១

មុននឹងចូលរៀនថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឆ្នាំទី១ និស្សិតទាំងអស់ត្រូវឆ្លងកាត់ការធ្វើតេស្តដោយជោគជ័យមុខវិជ្ជាចំនួនពីរជាមុនសិន ទៅតាមជំនាញរៀងៗខ្លួន។

បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្រ្ត ឯកទេសនីតិឯកជន ត្រូវធ្វើតេស្តមុខវិជ្ជានីតិរដ្ឋប្បវេណី និងភាសាបរទេស (អង់គ្លេស ឬបារាំង)។

បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្រ្ត ឯកទេសរដ្ឋបាលសាធារណៈ ត្រូវធ្វើតេស្តមុខវិជ្ជានីតិរដ្ឋបាល និងភាសាបរទេស (អង់គ្លេស ឬបារាំង)។

បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសហិរញ្ញវត្ថុ និងបរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រង ត្រូវធ្វើតេស្តមុខវិជ្ជាម៉ាក្រូសេដ្ឋកិច្ច និង ភាសាបរទេស (អង់គ្លេស ឬបារាំង)។

ថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់គ្រប់មុខជំនាញ ត្រូវធ្វើតេស្តមុខវិជ្ជាវប្បធម៌ទូទៅ និងភាសាបរទេស (អង់គ្លេស ឬបារាំង)។

## ១.២. កម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

### ១.២.១. កម្មវិធីបណ្ដុះបណ្ដាល

និស្សិតទាំងអស់ត្រូវរៀនមុខវិជ្ជាដែលកំណត់ដោយសាកលវិទ្យាល័យ ឲ្យបានក្រេឌីតសរុបយ៉ាងតិចចំនួន ៥៥ក្រេឌីត រួមទាំងក្រេឌីតសិក្ខាសាលា និងសកម្មភាពសង្គម។ រយៈពេលបណ្ដុះបណ្ដាលបរិញ្ញាបត្រជាន់ខ្ពស់ សរុបមានចំនួនពីរឆ្នាំ ដែលមាន៤ឆមាស (ឆ្នាំទី១មាន២ឆមាស និងឆ្នាំទី២មាន២ឆមាស)។

ចាប់ពីឆមាសទី២នៃឆ្នាំទី១ទៅ និស្សិតត្រូវជ្រើសរើសជម្រើសណាមួយក្នុងចំណោមជម្រើស២ ខាងក្រោម ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

- **ជម្រើសទី១គឺប្រឡងបញ្ចប់**។ និស្សិតដែលជ្រើសរើសការប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ត្រូវរៀនបីមុខវិជ្ជានៅឆមាសទី២នៃឆ្នាំទី២ និងត្រូវសរសេររបាយការណ៍ស្រាវជ្រាវ ឲ្យចប់នៅដើមឆមាសទី២នៃឆ្នាំទី២។ កាលបរិច្ឆេទប្រមូលរបាយការណ៍ស្រាវជ្រាវនឹងត្រូវជូនដំណឹងដោយសាកលវិទ្យាល័យ។
- **ជម្រើសទី២គឺសរសេរនិក្ខេបបទបញ្ចប់**។ និស្សិតដែលជ្រើសរើសការសរសេរនិក្ខេបបទមិនបាច់រៀននៅឆមាសទី២នៃឆ្នាំទី២ទេ តែត្រូវសរសេរនិក្ខេបបទឲ្យចប់សព្វគ្រប់នៅឆមាសទី២នៃឆ្នាំទី២។ កាលបរិច្ឆេទប្រមូលនិក្ខេបបទនឹងត្រូវជូនដំណឹងដោយសាកលវិទ្យាល័យ។

ទាំងការសរសេររបាយការណ៍ស្រាវជ្រាវ និងការសរសេរនិក្ខេបបទ និស្សិតត្រូវជ្រើសរើសគ្រូណែនាំ ដោយខ្លួនឯង ប៉ុន្តែចំពោះការសរសេរនិក្ខេបបទ តម្រូវឲ្យនិស្សិតជ្រើសរើសគ្រូជំនួយម្នាក់ទៀត។ គ្រូណែនាំនិក្ខេបបទត្រូវតែជាគ្រូណែនាំដែលមានសញ្ញាបត្របណ្ឌិត ចំណែកឯគ្រូជំនួយនិក្ខេបបទ ឬគ្រូណែនាំរបាយការណ៍ស្រាវជ្រាវអាចមានសញ្ញាបត្របណ្ឌិត ឬបរិញ្ញាបត្រជាន់ខ្ពស់។

### ១.២.២. លក្ខខណ្ឌសិក្សា

និស្សិតត្រូវមករៀនទៀងទាត់ និងទាន់ពេលវេលា។ ជាមួយគ្នានេះដែរ និស្សិតក៏ត្រូវបំពេញកិច្ចការមួយចំនួនដែលត្រូវបានផ្ដល់ឲ្យដោយគ្រូបង្រៀនមុខវិជ្ជានីមួយៗ។ រាល់ការខកខានមិនបានបំពេញតាមលក្ខខណ្ឌរបស់គ្រូបង្រៀននៃមុខវិជ្ជានីមួយៗ អាចនឹងមានផលប៉ះពាល់ដល់លទ្ធផលនៃការសិក្សាលើមុខវិជ្ជានោះ។ ទោះជាយ៉ាងណាក៏ដោយ សាកលវិទ្យាល័យកំណត់លក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- និស្សិតដែលអវត្តមានឥតច្បាប់លើសពី៤០% ឬអវត្តមានមានច្បាប់លើសពី៥០% មិនត្រូវអនុញ្ញាតឲ្យប្រឡងឡើយ ហើយត្រូវរៀនឡើងវិញចំពោះមុខវិជ្ជាដដែលនេះ។ និស្សិតត្រូវដាក់ពាក្យរៀនឡើងវិញ ដោយបង់ថ្លៃសិក្សាចំនួន៩០ដុល្លារក្នុងមួយមុខវិជ្ជាដែលមាន៣ក្រេឌីត។
- និស្សិតដែលបានប្រឡងបញ្ចប់ឆមាសនីមួយៗ ប្រសិនបើធ្លាក់មុខវិជ្ជាណាមួយ និស្សិតត្រូវរៀនមុខវិជ្ជា នោះម្ដងទៀត ដោយដាក់ពាក្យសុំចូលរៀនឡើងវិញនិងបង់ថ្លៃសិក្សាចំនួន៩០ដុល្លារ ក្នុងមួយមុខវិជ្ជា ដែលមាន៣ក្រេឌីត។

## ១.៣. លក្ខខណ្ឌបញ្ចប់ការសិក្សា

### ១.៣.១. និស្សិតដែលជ្រើសរើសការសរសេររបាយការណ៍បញ្ចប់

និស្សិតទាំងអស់ត្រូវទទួលបានលទ្ធផលជោគជ័យគ្រប់មុខវិជ្ជាទាំងអស់ ដែលមានពិន្ទុចាប់ពី៦០%ឡើងទៅ ចាប់ពីឆ្នាំទី១ ដល់ឆមាសទី១នៃឆ្នាំទី២ និងទទួលបានជោគជ័យក្នុងការសរសេររបាយការណ៍បញ្ចប់ ទើបអនុញ្ញាតឲ្យប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅចុងឆមាសទី២នៃឆ្នាំទី២។ ពិន្ទុប្រឡងបញ្ចប់ និងពិន្ទុរបាយការណ៍ស្រាវជ្រាវចាត់ទុកថាជាប់ លុះត្រាតែបានទទួលចាប់ពី៦០%ឡើងទៅ។

### ១.៣.២. និស្សិតដែលជ្រើសរើសការសរសេរនិក្ខេបបទបញ្ចប់

និស្សិតទាំងអស់ត្រូវទទួលបានលទ្ធផលជោគជ័យគ្រប់មុខវិជ្ជាទាំងអស់ ដែលមានពិន្ទុចាប់ពី៦០%ឡើងទៅ ចាប់ពីឆ្នាំទី១ដល់ឆមាសទី១នៃឆ្នាំទី២និងទទួលបានជោគជ័យក្នុងការសរសេរនិក្ខេបបទដែលបញ្ជាក់ដោយគ្រូណែនាំ ទើបអនុញ្ញាតឲ្យដាក់និក្ខេបបទការពារនៅចុងឆមាសទី២នៃឆ្នាំទី២។ លទ្ធផលនិក្ខេបបទ ចាត់ទុកថាជាប់ លុះត្រាតែទទួលបានពិន្ទុចាប់ពី៧០%ឡើងទៅ។



ពិធីចែកសញ្ញាបត្រ, ៥ មិថុនា ២០២៣




ខួបលើកទី២០ឆ្នាំនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់, ១១ វិច្ឆិកា ២០២៣

## ២. សេចក្តីណែនាំស្តីពីការសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

វង្វាយតម្លៃនិក្ខេបបទ គឺជាដំណាក់កាលចុងក្រោយនៃកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ហើយមានលក្ខណៈសំខាន់បំផុតក្នុងការធានាសមត្ថភាពចំណេះដឹងរបស់និស្សិត ក្នុងការទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។ និស្សិតដែលជ្រើសរើសការសរសេរនិក្ខេបបទសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ត្រូវស្វែងយល់ គោរព និងអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

### ២.១. វាយតម្លៃលើគម្រោងស្រាវជ្រាវនិក្ខេបបទ

និស្សិតអាចជ្រើសរើសប្រធានបទណាមួយដែលខ្លួនពេញចិត្តដើម្បីធ្វើការស្រាវជ្រាវ។ ការស្រាវជ្រាវនេះត្រូវបានអនុញ្ញាតឲ្យមានគ្រូណែនាំម្នាក់ ដែលមានជំនាញពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវនោះ និង គ្រូជំនួយម្នាក់ទៀត។ គម្រោងស្រាវជ្រាវនិក្ខេបបទ រួមមានផ្នែក៣សំខាន់ៗគឺ៖

- **សេចក្តីផ្តើម**

នៅក្នុងផ្នែកនេះ និស្សិតត្រូវសរសេរដោយគ្របដណ្តប់លើចំណុចសំខាន់ៗមួយចំនួនដូចជា លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ដែនកំណត់និងទំហំនៃការស្រាវជ្រាវ សារៈសំខាន់ និងរចនាសម្ព័ន្ធនៃនិក្ខេបបទ។

- **ខ្លឹមសារនិក្ខេបបទ**

និស្សិតអាចសរសេរជាជំពូកទៅតាមតម្រូវការរបស់ប្រធានបទជាក់ស្តែង។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកនេះត្រូវគ្របដណ្តប់លើការរំឭកទ្រឹស្តី វិធីសាស្ត្រស្រាវជ្រាវ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា/ការវិភាគ។

- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

សេចក្តីសន្និដ្ឋានគឺជាការសរុបខ្លឹមសារនិក្ខេបបទ និងអំណះអំណាង ព្រមទាំងការរៀបរាប់ពីលទ្ធផលដែលទទួលបាន រួមមានទាំងចំណុចល្អ និងចំណុចខ្វះខាត។ ការផ្តល់អនុសាសន៍ត្រូវលើកឡើងពីចំណុចដែលត្រូវបំពេញបន្ថែម និងចំណុចដែលត្រូវផ្លាស់ប្តូរ។ រាល់ការលើកឡើងទាំងនៅក្នុងសេចក្តីសន្និដ្ឋាន និងនៅក្នុងការផ្តល់អនុសាសន៍គឺត្រូវផ្អែកលើអ្វីដែលបានសរសេរខាងលើ។ ជាទូទៅ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ត្រូវខ្លីមិនត្រូវបានអនុញ្ញាតឲ្យអធិប្បាយពាក្យទាំងឡាយណាដែលគ្មានប្រយោជន៍ ឬដែលមិនពាក់ព័ន្ធឡើយ។

ផ្នែកចុងក្រោយនៃនិក្ខេបបទគឺត្រូវសរសេរគន្ថនិទ្ទេស ឬឯកសារយោង/ឯកសារពិគ្រោះ។ មិនអនុញ្ញាតឲ្យយករបាយការណ៍ ឬសារណាថ្នាក់បរិញ្ញាបត្រមកធ្វើជាឯកសារពិគ្រោះឡើយ។

### ២.២. រចនាសម្ព័ន្ធនៃនិក្ខេបបទ

ត្រូវសរសេរឲ្យបានត្រឹមត្រូវ ច្បាស់លាស់ មានលក្ខណៈវិទ្យាសាស្ត្រ និងមិនអនុញ្ញាតឲ្យកោសលុបឡើយ ហើយត្រូវដាក់លេខទំព័រ លេខតារាង រូប និងក្រាភិកឲ្យបានត្រឹមត្រូវ។ និក្ខេបបទមួយត្រូវបានទទួលស្គាល់ថារួចរាល់ជាស្ថាពរ លុះត្រាតែបេក្ខជនបានសរសេរតាមលំដាប់លំដោយត្រឹមត្រូវ ដូចការណែនាំខាងក្រោម៖

- ក្របមុខនិក្ខេបបទ (រៀបចំជាគំរូដោយសាលាក្រោយបរិញ្ញាបត្រ)
- ក្របបន្ទាប់ (ក្រដាសធម្មតាពណ៌លឿងអក្សរពណ៌ទឹកប៊ិចខ្មៅ)
- សង្ខេបសេចក្តី (Abstract)
- សេចក្តីថ្លែងអំណរគុណ
- អារម្ភកថា
- មាតិកា (ត្រូវសរសេរឲ្យបានត្រឹមត្រូវតាមលំដាប់លំដោយ)

- តារាងសម្គាល់អក្សរកាត់ត្រូវរៀបតាមលំដាប់លំដោយអក្សរ (បើមាន)
- បញ្ជីតារាង (បើមាន)
- បញ្ជីរូប (បើមាន)
- បញ្ជីក្រាភិក (បើមាន)
- បញ្ជីប្រអប់ (បើមាន) ឬផ្សេងៗទៀតប្រសិនបើមាន
- សេចក្តីផ្តើម
- ជំពូកទី១
- ជំពូកទី២
- ជំពូកទី៣
- ....
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍
- គន្ថនិទ្ទេស ឬឯកសារយោង/ឯកសារពិគ្រោះ

## ២.៣. ទំហំក្រដាស និងប្រភេទអក្សរ

ក-ទំហំក្រដាស (paper size): A4 (21 cm × 29,7 cm)




ខ. ប្រភេទ និងទំហំអក្សរ (Font type and font size) ប្រើ Khmer Unicode

| **របៀបតាក់តែង** | **ប្រភេទអក្សរ** | **ទំហំអក្សរ** |
|---|---|---|
| **ចំណងជើងជំពូក** | Khmer OS Muol Light | 12 |
| **ចំណងជើងរង** (១.១.) | Khmer OS Muol Light | 11 |
| **ចំណងជើងរងបន្ទាប់** (១.១.១.) | Khmer OS Muol Light | 10.5 |
| **ចំណងជើងរងចុងក្រោយ** (១.១.១.១.) | Khmer OS Muol Light | 10 |
| អត្ថបទ | Khmer OS Siemreap | 11 |
| សម្គាល់ក្រោមទំព័រ (footnote) | Khmer OS Siemreap | 9 |
| Header and Footer<br>ត្រូវសរសេរចាប់ពីទំព័រសេចក្តីផ្តើម ដល់អនុសាសន៍ | Khmer OS Siemreap | 8 |
| ចន្លោះបន្ទាត់ (Line Spacing) = Multiple 1.2 | | |
| Spacing: After 6 pt | | |

**កំណត់សម្គាល់**

- និក្ខេបបទមួយត្រូវសរសេរដោយនិស្សិតតែម្នាក់។
- និក្ខេបបទត្រូវសរសេរនៅតែផ្នែកម្ខាងនៃក្រដាស។
- និស្សិតត្រូវចាប់ផ្ដើមជ្រើសរើសប្រធានបទ និងរៀបចំគម្រោងស្រាវជ្រាវនៅឆមាសទី១នៃឆ្នាំទី១ហើយត្រូវដាក់ជូនសាលាក្រោយបរិញ្ញាបត្រនៅដើមឆមាសទី២នៃឆ្នាំទី២ក្រោយពីបានទទួលការអនុញ្ញាតពីគ្រូណែនាំរួច។
- និក្ខេបបទនឹងត្រូវបានរៀបចំចងក្រងតាមការកំណត់ដោយសាលាក្រោយបរិញ្ញាបត្រ ប៉ុន្តែការចំណាយលើការបោះពុម្ពជាបន្ទុករបស់និស្សិត។
- ការលួចចម្លងស្នាដៃរបស់អ្នកដទៃមកធ្វើជារបស់ខ្លួនមិនត្រូវបានអនុញ្ញាតឡើយ។
- និក្ខេបបទត្រូវបានអនុញ្ញាតឲ្យសរសេរចន្លោះពី៧០ទំព័រទៅ២០០ទំព័រចំពោះវិទ្យាសាស្ត្រសង្គម និងចន្លោះពី៦០ទំព័រទៅ១៥០ទំព័រចំពោះវិទ្យាសាស្ត្រធម្មជាតិ (ដោយរាប់ចាប់ពីសេចក្ដីផ្ដើមដល់អនុសាសន៍)។

និស្សិតដែលសរសេរនិក្ខេបបទទាំងអស់ត្រូវសុំណាត់ជួបជាមួយគ្រូណែនាំទៅតាមពេលវេលាជាក់ស្ដែង ហើយត្រូវសរសេរឲ្យបានរួចរាល់ និងបានទទួលការឯកភាពពីគ្រូណែនាំ មុនពេលប្រគល់ ជូនសាលាក្រោយបរិញ្ញាបត្រទៅតាមកាលបរិច្ឆេទដែលបានកំណត់ដោយសាកលវិទ្យាល័យ។



សកម្មភាពទទួលរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា, ខែធ្នូ ឆ្នាំ២០២៣

# ៣. សេចក្តីណែនាំ
# ស្តីអំពីការសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

និស្សិតដែលជ្រើសរើសការសរសេររបាយការណ៍ស្រាវជ្រាវ សម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ត្រូវស្វែងយល់ គោរព និងអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

## ៣.១. រចនាសម្ព័ន្ធលើរបាយការណ៍ស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

និស្សិតអាចជ្រើសរើសប្រធានបទណាមួយដែលខ្លួនពេញចិត្តដើម្បីធ្វើការស្រាវជ្រាវ។ ការស្រាវជ្រាវនេះត្រូវបានអនុញ្ញាតឲ្យមានគ្រូណែនាំម្នាក់ដែលមានជំនាញពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវនោះ។ របាយការណ៍ស្រាវជ្រាវត្រូវមានចំនួន២០ទំព័រយ៉ាងតិច ដែលរួមមានផ្នែក៣សំខាន់ៗគឺ៖

- **សេចក្តីផ្តើម**

នៅក្នុងផ្នែកនេះ និស្សិតត្រូវសរសេរដោយគ្របដណ្តប់នូវចំណុចសំខាន់ៗមួយចំនួនដូចជា លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ដែនកំណត់និងវិសាលភាព សារៈសំខាន់ និងរចនាសម្ព័ន្ធនៃរបាយការណ៍ស្រាវជ្រាវ។

- **ខ្លឹមសាររបាយការណ៍ស្រាវជ្រាវ**

និស្សិតអាចសរសេរជាជំពូកទៅតាមតម្រូវការរបស់ប្រធានបទជាក់ស្តែង។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកនេះត្រូវគ្របដណ្តប់លើការរំឭកទ្រឹស្តី វិធីសាស្ត្រស្រាវជ្រាវ លទ្ធផលស្រាវជ្រាវ និងការវិភាគលទ្ធផលនៃការស្រាវជ្រាវនេះ។

- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

ផ្នែកនេះគឺជាការសរុបនូវខ្លឹមសាររបាយការណ៍ និងអំណះអំណាង ព្រមទាំងការរៀបរាប់អំពីលទ្ធផលដែលទទួលបានរួមមានទាំងចំណុចល្អ និងចំណុចខ្វះខាត។ អនុសាសន៍ត្រូវលើកឡើងចំណុចដែលត្រូវបំពេញបន្ថែម និងចំណុចដែលត្រូវផ្លាស់ប្តូរ។ រាល់ការលើកឡើងទាំងនៅក្នុងសេចក្តីសន្និដ្ឋាន និងនៅក្នុងអនុសាសន៍ គឺត្រូវផ្អែកលើអ្វីដែលបានសរសេរខាងលើ។ ជាទូទៅ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ត្រូវខ្លីហើយមិនត្រូវបានអនុញ្ញាតឲ្យអធិប្បាយនូវពាក្យទាំងឡាយណាដែលគ្មានប្រយោជន៍។

ផ្នែកខាងក្រោយនៃរបាយការណ៍គឺត្រូវសរសេរឯកសារពិគ្រោះ/ឯកសារយោង ឬគន្ថនិទ្ទេស។ មិនអនុញ្ញាតឲ្យយករបាយការណ៍សារណារបស់អ្នកផ្សេងមកធ្វើជាឯកសារពិគ្រោះ ឬយកមកចម្លងឡើយ។

## ៣.២. រចនាសម្ព័ន្ធនៃរបាយការណ៍ស្រាវជ្រាវ

ត្រូវសរសេរឲ្យបានត្រឹមត្រូវ ច្បាស់លាស់ សង្ខេបឲ្យមានលក្ខណៈវិទ្យាសាស្ត្រ និងមិនអនុញ្ញាតឲ្យកោសលុបឡើយ ហើយត្រូវដាក់លេខទំព័រលេខតារាងរូប និងក្រាភិក។ របាយការណ៍ស្រាវជ្រាវមួយត្រូវបានទទួលស្គាល់ថារួចរាល់ជាស្ថាពរ លុះត្រាតែបេក្ខជនសរសេរបានតាមលំដាប់លំដោយត្រឹមត្រូវ ដូចគំរូខាងក្រោម៖

- ក្របមុខរបាយការណ៍ស្រាវជ្រាវ (រៀបចំជាគំរូដោយមន្ត្រីទទួលបន្ទុកសាលាក្រោយបរិញ្ញាបត្រ)
- ក្របបន្ទាប់ (ក្រដាសធម្មតាពណ៌លឿង អក្សរពណ៌ទឹកប៊ិចខ្មៅ)
- លិខិតថ្លែងអំណរគុណ
- អារម្ភកថា
- អំណះអំណាង
- តារាងសម្គាល់អក្សរកាត់ ត្រូវរៀបតាមលំដាប់លំដោយអក្សរ (បើមាន) ប៉ុន្តែពុំគប្បីប្រើអក្សរកាត់ឡើយ នៅក្នុងរបាយការណ៍ស្រាវជ្រាវ។

- មាតិកា (ត្រូវសរសេរឲ្យបានត្រឹមត្រូវ តាមលំដាប់លំដោយ)
- សេចក្ដីផ្ដើម
- ខ្លឹមសាររបាយការណ៍ និងសេចក្ដីសន្និដ្ឋាននៃខ្លឹមសារតាមជំពូកនីមួយៗ លេខលំដាប់របស់ជំពូក ផ្នែកនៅក្នុងជំពូកត្រូវសរសេរជាលេខខ្មែរដូចក្នុងឧទាហរណ៍ខាងក្រោម៖

**ជំពូកទី១**

**១.១** ........................................................................

**១.១.១** ..............................................................

**១.១.២** ..............................................................

**១.១.៣** ..............................................................

**ជំពូកទី២**

**២.១** ........................................................................

**២.១.១** ..............................................................

........................................................................................

**សេចក្ដីសន្និដ្ឋាន និងអនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ** (បើមាន)

## ៣.៣. ទំហំក្រដាស និងប្រភេទអក្សរ

ក-ទំហំក្រដាស (paper size): A4 (21 cm × 29,7 cm)



ខ. ប្រភេទ និងទំហំអក្សរ (Font type and font size)៖ ត្រូវប្រើKhmer Unicode

| **របៀបតាក់តែង** | **ប្រភេទអក្សរ** | **ទំហំអក្សរ** |
|---|---|---|
| **ចំណងជើងជំពូក** | Khmer OS Muol Light | 12 |
| **ចំណងជើងរង** (១.១.) | Khmer OS Muol Light | 11 |
| **ចំណងជើងរងបន្ទាប់** (១.១.១.) | Khmer OS Muol Light | 10.5 |
| **ចំណងជើងរងចុងក្រោយ** (១.១.១.១.) | Khmer OS Muol Light | 10 |
| អត្ថបទ | Khmer OS Siemreap | 11 |
| សម្គាល់ក្រោមទំព័រ (footnote) | Khmer OS Siemreap | 9 |
| Header and Footer<br>ត្រូវសរសេរចាប់ពីសេចក្តីផ្តើម ដល់អនុសាសន៍ | Khmer OS Siemreap | 8 |
| ចន្លោះបន្ទាត់ (Line Spacing) = Multiple 1.2 | | |
| Spacing: After 6 pt | | |

## កំណត់សម្គាល់

- របាយការណ៍ស្រាវជ្រាវត្រូវសរសេរនៅតែផ្នែកម្ខាងនៃក្រដាស។
- និស្សិតត្រូវចាប់ផ្តើមជ្រើសរើសប្រធានបទ និងសរសេររបាយការណ៍ស្រាវជ្រាវចាប់ពីឆមាស**ទី១ នៃឆ្នាំទី១**ទៅ ហើយ**ត្រូវដាក់ជូនសាលាក្រោយបរិញ្ញាបត្រនៅដើមឆមាសទី២នៃឆ្នាំទី២**ក្រោយពីបានទទួលការអនុញ្ញាតពីគ្រូណែនាំរួច។
- របាយការណ៍ស្រាវជ្រាវនឹងត្រូវបានរៀបចំចងក្រងចំនួន១០ច្បាប់ ដោយមន្ត្រីទទួលបន្ទុកនៅសាលាក្រោយបរិញ្ញាបត្រ ប៉ុន្តែការចំណាយលើការបោះពុម្ពជាបន្ទុករបស់និស្សិត។
- ការលួចចម្លងស្នាដៃរបស់អ្នកដទៃមកធ្វើជារបស់ខ្លួនមិនត្រូវបានអនុញ្ញាតឡើយ។



សិក្ខាសាលាស្តីពីគុណធម៌នៃការសិក្សាស្រាវជ្រាវ, ខែកក្កដា ឆ្នាំ២០២៣

# ៤. គោលការណ៍ផ្តល់ក្រេឌីតសិក្ខាសាលា

ការចូលរួមសិក្ខាសាលា ជាលក្ខខណ្ឌមួយសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សិក្ខាសាលាផ្តល់ឱកាសឲ្យនិស្សិតស្វែងយល់បន្ថែមពីបញ្ហានានាពាក់ព័ន្ធនឹងការសិក្សា និងបទពិសោធន៍ការងារ ដោយនិស្សិតអាចជជែក ចោទជាសំណួរ និងបង្ហាញហេតុផលរបស់ខ្លួនចំពោះមុខវាគ្មិននៃសិក្ខាសាលានីមួយៗ។ វាគ្មិនអាចត្រូវបានអញ្ជើញមកពីគ្រប់មជ្ឈដ្ឋានរួមមានទាំងស្ថាប័នសិក្សា និងស្ថាប័នវិជ្ជាជីវៈ។

នៅពេលបើកសិក្ខាសាលាម្តងៗ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តម្រូវឲ្យចូលរួមសិក្ខាសាលា តាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ ដើម្បីទទួលបានឱកាសគ្រប់គ្រាន់ក្នុងការស្វែងយល់បន្ថែម និងជជែកពិភាក្សា។ និស្សិតតម្រូវឲ្យចូលរួមសិក្ខាសាលាយ៉ាងតិច៤ដង ទើបអាចបំពេញលក្ខខណ្ឌក្រេឌីតសិក្ខាសាលា។

លក្ខណវិនិច្ឆ័យនៃការផ្តល់ក្រេឌីតសិក្ខាសាលាមានដូចតទៅ៖

## ៤.១. និទ្ទេស A

និស្សិតដែលបានចូលរួមទាន់ពេលវេលា ដោយបានចុះហត្ថលេខាលើបញ្ជីវត្តមានមុនពេលសិក្ខាសាលាចាប់ផ្តើម និងបានបំពេញទម្រង់ក្រេឌីតសិក្ខាសាលានៅពេលចុងម៉ោង ហើយប្រគល់ឲ្យវិញនៅក្រោយពេលបញ្ចប់សិក្ខាសាលាភ្លាម នឹងត្រូវទទួលបាននិទ្ទេសA។

## ៤.២. និទ្ទេស B

និស្សិតដែលមិនបានចូលរួមសិក្ខាសាលាទាន់ពេលវេលា ពោលគឺមិនបានចុះហត្ថលេខាលើបញ្ជីវត្តមានមុនពេលចាប់ផ្តើមសិក្ខាសាលា ប៉ុន្តែបានបំពេញទម្រង់ក្រេឌីតសិក្ខាសាលានៅពេលចុងម៉ោង ហើយប្រគល់ឲ្យវិញនៅក្រោយពេលបញ្ចប់សិក្ខាសាលាភ្លាម នឹងត្រូវទទួលបាននិទ្ទេសB។

## ៤.៣. និទ្ទេសសរុប

និទ្ទេសសិក្ខាសាលាសរុបគឺជានិទ្ទេសណាមួយដែលចំនួនដងនៃការចូលរួមច្រើនជាងពាក់កណ្តាល។ ក្នុងករណីចំនួនដងនៃការចូលរួមសិក្ខាសាលាមាននិទ្ទេសA និងBស្មើគ្នា និទ្ទេសសរុបគឺនិទ្ទេសB។

និស្សិតដែលបានបញ្ចប់ក្រេឌីតសិក្សាក្នុងថ្នាក់ ប៉ុន្តែមិនទាន់បានបំពេញក្រេឌីតសិក្ខាសាលាយ៉ាងតិចចំនួន៤ដងទេ មិនត្រូវបានអនុញ្ញាតឲ្យទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើយ។

គោលការណ៍ផ្តល់ក្រេឌីតសិក្ខាសាលានេះ នឹងត្រូវអនុវត្តចំពោះនិស្សិតចាប់ពីជំនាន់១៧ ជំហាន២តទៅ។



សិក្ខាសាលាស្តីពីការណែនាំជ្រើសរើសការសរសេររបាយការណ៍ស្រាវជ្រាវ ឬការសរសេរនិក្ខេបបទ, ខែមិថុនា ឆ្នាំ២០២៣

# ៥. គោលការណ៍សកម្មភាពសង្គមសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ការចូលរួមសកម្មភាពសង្គមជាលក្ខខណ្ឌមួយសម្រាប់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សកម្មភាពសង្គមផ្តល់ឱកាសឲ្យនិស្សិតរៀនសូត្រពីរបៀបចែករំលែកចំណេះដឹង បទពិសោធន៍ និងធនធានរបស់ខ្លួនទៅតាមលទ្ធភាពដើម្បីចូលរួមចំណែកអភិវឌ្ឍសង្គម និងបង្កើតវប្បធម៌ចែករំលែកនៅពេលពួកគេបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ។

សកម្មភាពសង្គមនៅក្នុងគោលការណ៍នេះសំដៅទៅលើកម្មវិធីវិភាគទានសប្បុរសធម៌នានា កម្មវិធីដាំដើមឈើ ការចូលរួមការពារបរិស្ថាន និងកម្មវិធីពាក់ព័ន្ធផ្សេងទៀតដែលនិស្សិតត្រូវចូលរួម ឬអនុវត្តដោយខ្លួនឯងផ្ទាល់។

ចាប់ពីឆមាសទី១នៃឆ្នាំទី១រហូតដល់ឆមាសទី២នៃឆ្នាំទី២ និស្សិតអាចចូលរួម និង/ឬបង្កើតសកម្មភាពសង្គមណាមួយ ដូចខាងក្រោម៖

## ៥.១. សកម្មភាពសង្គមដែលរៀបចំដោយសាលាក្រោយបរិញ្ញាបត្រ

សាលាក្រោយបរិញ្ញាបត្របង្កើតសកម្មភាពសង្គមផ្សេងៗរៀងរាល់ឆមាស។ កម្មវិធីសង្គមមួយចំនួនមានភ្ជាប់ ជាមួយនឹងការធ្វើទស្សនកិច្ចសិក្សាតែម្តង។

និស្សិតដែលបានចូលរួមវិភាគទានសប្បុរសធម៌ និងបានចូលរួមក្នុងទស្សនកិច្ចសិក្សាម្តងយ៉ាងតិច នឹងត្រូវចាត់ទុកថាបានបំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ទាក់ទងនឹងសកម្មភាពសង្គម។

## ៥.២. សកម្មភាពសង្គមដែលរៀបចំដោយថ្នាក់រៀននីមួយៗឬដោយក្រុមនិស្សិតនៅក្នុងថ្នាក់

និស្សិតទូទាំងថ្នាក់ ឬជាក្រុមដែលមានសមាជិកយ៉ាងតិច៥នាក់អាចផ្តួចផ្តើមរៀបចំសកម្មភាពសង្គម ដោយខ្លួនឯងបាន ដោយបំពេញសំណុំបែបបទដាក់ជូនសាលាក្រោយបរិញ្ញាបត្រជាមុន។

និស្សិតដែលបានចូលរួមក្នុងសកម្មភាពសង្គមដែលរៀបចំដោយថ្នាក់រៀននីមួយៗ ឬដោយក្រុមនិស្សិត នៅក្នុងថ្នាក់យ៉ាងតិចម្តង នឹងត្រូវចាត់ទុកថាបានបំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ទាក់ទងនឹងសកម្មភាពសង្គម។

និស្សិតដែលបានចូលរួម និង/ឬរៀបចំសកម្មភាពសង្គមចាប់ពី៤ដងឡើងទៅក្នុងរយៈពេលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នឹងត្រូវបានផ្តល់ជូនលិខិតសរសើរពីសាកលវិទ្យាល័យ។ របាយការណ៍ស្តីពីសកម្មភាពសង្គមរបស់និស្សិតម្នាក់ៗគឺជាភស្តុតាងចាំបាច់ក្នុងការវាយតម្លៃពីការចូលរួម និង/ឬរៀបចំសកម្មភាពសង្គម។

គោលការណ៍សកម្មភាពសង្គមសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ នឹងត្រូវអនុវត្តចំពោះនិស្សិតចាប់ពីជំនាន់១៧ ជំហាន២តទៅ។




សកម្មភាពសង្គម និងទស្សនកិច្ចសិក្សានៅខេត្តព្រៃវែង
២៧ សីហា ២០២៣



សកម្មភាពសង្គម និងទស្សនកិច្ចសិក្សានៅខេត្តសៀមរាប
២៤-២៦ កុម្ភៈ ២០២៣



សកម្មភាពសង្គម និងទស្សនកិច្ចសិក្សានៅខេត្តខេត្តកំពត
២៨-២៩ សីហា ២០២២



សកម្មភាពសង្គម នៅវិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី
៣១ មីនា ២០២២




សកម្មភាពសង្គមនៅខេត្តកំពង់ចាម
២៦ កញ្ញា ២០២១



ទស្សនកិច្ចសិក្សា និងសកម្មភាពសង្គម នៅខេត្តមណ្ឌលគិរី
១៨-២០ មករា ២០២០



ទស្សនកិច្ចសិក្សាទៅខេត្តព្រះវិហារ និងសៀមរាប
១៦-១៨ មិថុនា ២០១៨



ទស្សនកិច្ចសិក្សាទៅខេត្តកំពង់ធំ
០៤ មីនា ២០១៨

## ៦. គោលការណ៍បង់ថ្លៃសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបើកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមរូបភាពបង់ថ្លៃ។ គោលការណ៍នៃការបង់ថ្លៃសិក្សាចំពោះនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ត្រូវបានកំណត់ដូចខាងក្រោម៖

### ៦.១. អំពីការបង់ថ្លៃសិក្សា

#### ៦.១.១. ការបង់ថ្លៃសិក្សាក្នុងមួយឆ្នាំសិក្សា

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបានអនុញ្ញាតឲ្យបង់ថ្លៃសិក្សាចំនួន១១៥០ដុល្លារក្នុងមួយឆ្នាំសិក្សា ហើយការបង់ថ្លៃនេះត្រូវបានធ្វើឡើងនៅដើមឆ្នាំសិក្សានីមួយៗ។

បើការបង់ថ្លៃសិក្សាធ្វើឡើងក្រោយពេលចូលរៀន១ខែនៃដើមឆ្នាំសិក្សានីមួយៗ និស្សិតត្រូវបង់សរុបចំនួន១១០០ដុល្លារ។

#### ៦.១.២. ការបង់ថ្លៃសិក្សាតាមឆមាសនីមួយៗ

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អាចត្រូវបានអនុញ្ញាតឲ្យបង់ថ្លៃសិក្សាតាមឆមាសនៃឆ្នាំសិក្សានីមួយៗដូចខាងក្រោម៖

**ឆ្នាំទី១**

- ឆមាសទី១ (Semester 1) មានតម្លៃ៦០០ដុល្លារ
- ឆមាសទី២ (Semester 2) មានតម្លៃ៦០០ដុល្លារ

**ឆ្នាំទី២**

- ឆមាសទី១ (Semester 1) មានតម្លៃ៦០០ដុល្លារ
- ឆមាសទី២ (Semester 2) មានតម្លៃ៦០០ដុល្លារ

### ៦.២. អំពីដំណើរការនៃការបង់ថ្លៃសិក្សា

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបង់ថ្លៃសិក្សាដែលបានកំណត់នៅចំណុច "១. ការបង់ថ្លៃសិក្សា" ខាងលើយ៉ាងយូរបំផុតរយៈពេល១ខែ ក្រោយពេលប្រកាសអនុវត្តកាលវិភាគតាមឆមាសនីមួយៗ។

ក្នុងករណីនិស្សិតបង់ថ្លៃសិក្សាយឺត ចាប់ពីក្រោយរយៈពេល១ខែរហូតដល់ចប់ឆមាស និស្សិតត្រូវបង់ថ្លៃសិក្សាបន្ថែមចំនួន២៥ដុល្លារទៀត។

ក្នុងករណីនិស្សិតបង់ថ្លៃសិក្សាយឺត ដោយរំលង១ឆមាស ទៅបង់ថ្លៃសិក្សានៅឆមាសថ្មី និស្សិតត្រូវបង់ថ្លៃសិក្សាបន្ថែមចំនួន៥០ដុល្លារទៀត។

ក្នុងករណីនិស្សិតមិនបានបង់ថ្លៃសិក្សាពីរឆមាសជាប់គ្នា សាកលវិទ្យាល័យនឹងសម្រេចលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតកំពុងរៀននៅឆមាសបន្ទាប់។ និស្សិតដែលត្រូវបានលុបឈ្មោះនេះ ត្រូវបានចាត់ទុកថាជានិស្សិតបោះបង់ការសិក្សា។

### ៦.៣. អំពីប្រសិទ្ធភាពអនុវត្ត

គោលការណ៍បង់ថ្លៃសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ មានប្រសិទ្ធភាពអនុវត្ត ចំពោះនិស្សិតចាប់ពីជំនាន់១៧ ជំហាន២តទៅ។

## ៧. គម្រោងការជ្រើសរើសការសរសេររបាយការណ៍ស្រាវជ្រាវ ឬ និក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ត្រូវអនុវត្តតាមគម្រោងការសិក្សាដូចខាងក្រោមនេះចាប់ពីពេលចាប់ផ្ដើមការសិក្សារហូតដល់ពេលបញ្ចប់។

<table>
<tr><th>ឆ្នាំទី</th><th>ឆមាស</th><th colspan="3">ការពិពណ៌នា</th></tr>
<tr><td rowspan="4">១</td><td rowspan="3">១</td><td rowspan="3">រៀន</td><td colspan="2">សម្រេចចិត្តជ្រើសរើស</td></tr>
<tr><td>ប្រឡងបញ្ចប់</td><td>ប្រឡងបញ្ចប់</td></tr>
<tr><td>- រកប្រធានបទនៃរបាយការណ៍ស្រាវជ្រាវ និងគ្រូណែនាំ<br>- ស្វែងរកឯកសារ និងរៀបចំគម្រោងស្រាវជ្រាវ<br>- ពិគ្រោះជាមួយគ្រូណែនាំ</td><td>- រកប្រធានបទនៃនិក្ខេបបទ និងគ្រូណែនាំ<br>- ស្វែងរកឯកសារ និងរៀបចំគម្រោងស្រាវជ្រាវ<br>- ពិគ្រោះជាមួយគ្រូណែនាំ</td></tr>
<tr><td>២</td><td>រៀន</td><td>- ស្រាវជ្រាវ សរសេរ កែសម្រួល ពិគ្រោះជាមួយគ្រូណែនាំ</td><td>- ស្រាវជ្រាវ សរសេរ កែសម្រួល ពិគ្រោះជាមួយគ្រូណែនាំ</td></tr>
<tr><td rowspan="2">២</td><td>១</td><td>រៀន</td><td>- ស្រាវជ្រាវ សរសេរ កែសម្រួល<br>- ពិគ្រោះជាមួយគ្រូណែនាំ</td><td>- ស្រាវជ្រាវ សរសេរ កែសម្រួល<br>- ពិគ្រោះជាមួយគ្រូណែនាំ</td></tr>
<tr><td>២</td><td colspan="2">- សរសេរបញ្ចប់<br>- ដាក់ជូនរបាយការណ៍ស្រាវជ្រាវ<br>- រៀនបីមុខវិជ្ជា និងប្រឡងបញ្ចប់</td><td>- សរសេរបញ្ចប់និក្ខេបបទ និងកែសម្រួល<br>- ដាក់ជូននិក្ខេបបទ<br>- ការពារបញ្ចប់ (ចុងឆមាស)</td></tr>
</table>



សិក្ខាសាលាស្ដីពី**ស្ថានភាពក្នុងវិស័យអចលនវត្ថុ និងការបញ្ចាំនៅកម្ពុជា**, ៣០ កញ្ញា ២០២៣

## ៨. កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

សាលាក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបើកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ២ប្រភេទគឺ៖

- ❖ បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ និង
- ❖ បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច។

### ៨.១. កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ

សាលាក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបើកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រលើឯកទេសចំនួន ២ គឺ៖

- ❖ ឯកទេស នីតិឯកជន និង
- ❖ ឯកទេស រដ្ឋបាលសាធារណៈ

### ៨.២. កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច

សាលាក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបើកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ចលើឯកទេសចំនួន ២ គឺ៖

- ❖ ឯកទេស ហិរញ្ញវត្ថុ និង
- ❖ ឯកទេស គ្រប់គ្រង



ការប្រជុំជាមួយគ្រូបង្រៀននៅសាលាក្រោយបរិញ្ញាបត្រ
ក្រោមអធិបតីភាពរបស់សាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី សាកលវិទ្យាធិការរង
នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៥

# កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសនីតិឯកជន

(Curriculum for Master of Laws in Private Law)

| ល.រ | មុខវិជ្ជា (Subjects) | ចំនួនម៉ោង | ចំនួនក្រេឌីត | ឆមាស | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា (Research Methodology and Academic Writing) | 45 | 3 | 1 | **ឆ្នាំទី១** |
| 2 | នីតិសាជីវកម្មប្រៀបធៀប (Comparative Corporate Law) | 45 | 3 | | |
| 3 | នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប (Comparative Constitutional Law) | 45 | 3 | | |
| 4 | ឧក្រិដ្ឋវិទ្យា (Criminology) | 45 | 3 | | |
| 5 | នីតិព្រហ្មទណ្ឌអន្តរជាតិ (International Criminal Law) | 45 | 3 | | |
| 6 | នីតិទ្រព្យសម្បត្តិឯកជន (Private Property Law) | 45 | 3 | 2 | |
| 7 | នីតិគ្រួសារ (Family law)/នីតិចិត្តសាស្ត្រ (Psychology Law) | 45 | 3 | | |
| 8 | វិធីសាស្ត្រ និងគោលការណ៍បកស្រាយគតិយុត្ត (Methodology and Principle of Legal Interpretation) | 45 | 3 | | |
| 9 | នីតិការងារប្រៀបធៀប (Comparative Labor Law) | 45 | 3 | | |
| 10 | នីតិវិធីរដ្ឋប្បវេណី (Civil Procedural Law)/ នីតិសមុទ្រ (Law of the Sea) | 45 | 3 | 1 | **ឆ្នាំទី២** |
| 11 | បច្ចេកទេសអនុវត្តក្នុងកិច្ចសន្យាពិសេស (Strategies Applied to Special Contract) | 45 | 3 | | |
| 12 | នីតិមត៌កប្រៀបធៀប (Comparative Succession Law) | 45 | 3 | | |
| 13 | នីតិកម្មសិទ្ធិបញ្ញា (Intellectual Property Law) | 45 | 3 | | |
| 14 | នីតិវិនិយោគ (Investment Law) | 45 | 3 | 2 | ប្រឡង (បញ្ចប់) |
| 15 | ប្រាតិភោគ (Security) | 45 | 3 | | |
| 16 | អាស៊ានភាវូបនីយកម្ម (Aseanization) | 45 | 3 | | |
| 17 | ការសរសេររបាយការណ៍ស្រាវជ្រាវ (Report Writing) | | 3 | | |
| 18 | ការសរសេរនិក្ខេបបទ (Thesis Writing) | | 12 | ការពារនិក្ខេបបទ | |
| 19 | សិក្ខាសាលា និងសកម្មភាពសង្គម (Seminars & Social Activities) | | 1 | | |
| | **សរុប** (Total) | **720** | **52** | | |

**សម្គាល់៖**

មុខវិជ្ជានីតិទ្រព្យសម្បត្តិឯកជនបង្រៀនជាថ្នាក់សិក្ខាសាលា ចំណែកមុខវិជ្ជានីតិកម្មសិទ្ធិបញ្ញា ជាថ្នាក់ជជែកដេញដោល។

និស្សិតទាំងអស់ត្រូវជ្រើសរើសប្រធានបទស្រាវជ្រាវនៅចុងឆមាសទី១នៃឆ្នាំទី១។ និស្សិតដែលជ្រើសរើសការប្រឡងបញ្ចប់ ត្រូវសរសេររបាយការណ៍ស្រាវជ្រាវចាប់ពីឆមាសទី២ នៃឆ្នាំទី១ និងរៀន៣មុខវិជ្ជានៅឆមាសទី២នៃឆ្នាំទី២ដើម្បីប្រឡងបញ្ចប់។ មុខវិជ្ជាបម្រុងមួយចំនួននឹងកំណត់ ដោយសាកលវិទ្យាល័យ។ សាកលវិទ្យាល័យរក្សាសិទ្ធិផ្តល់ក្រេឌីតមួយចំនួនទៅលើសកម្មភាពផ្សេងៗរបស់និស្សិត និងទទួលស្គាល់ការផ្ទេរក្រេឌីតពីសាកលវិទ្យាល័យដៃគូនានាដែលបានព្រមព្រៀង។ និស្សិតដែលសរសេរនិក្ខេបបទ ត្រូវស្រាវជ្រាវចាប់ពីឆមាសទី២នៃឆ្នាំទី១តទៅ និងបញ្ចប់ស្ពាពរនៅឆមាសទី២ នៃឆ្នាំទី១ ដើម្បីការពារបញ្ចប់។ ឆមាសទី២នៃឆ្នាំទី១ មានមួយមុខវិជ្ជាសិក្សាក្នុងទម្រង់ជាសិក្ខាសាលា និងឆមាសទី១នៃឆ្នាំទី២ មានមួយមុខវិជ្ជាសិក្សាទម្រង់ជាការពិភាក្សាដេញដោលគ្នា។ និស្សិតត្រូវចូលរួមសិក្ខាសាលាចំនួនយ៉ាងតិច៤ដង និងធ្វើសកម្មភាពសង្គមយ៉ាងហោច១កម្មវិធី ទើបអាចបំពេញលក្ខខណ្ឌទទួលសញ្ញាបត្រ។

កម្មវិធីសិក្សានេះនឹងត្រូវអនុវត្តចំពោះនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ចាប់ពីជំនាន់២១ ជំហាន១តទៅ។

# កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសរដ្ឋបាលសាធារណៈ

(Curriculum for Master of Laws in Public Administration)

| ល.រ | មុខវិជ្ជា (Subjects) | ចំនួនម៉ោង | ចំនួនក្រេឌីត | ឆមាស | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | វិធីសាស្ត្រស្រាវជ្រាវនិងការសរសេរបែបសិក្សា (Research Methodology and Academic Writing) | 45 | 3 | 1 | **ឆ្នាំទី១** |
| 2 | ការគ្រប់គ្រងរដ្ឋបាលដែនដី (Territorial Administrative Management) | 45 | 3 | | |
| 3 | គោលនយោបាយសាធារណៈ (Public Policy) | 45 | 3 | | |
| 4 | នីតិសេវាសាធារណៈ (Law of Public Service) | 45 | 3 | | |
| 5 | នគរូបនីយកម្ម (Urbanization) | 45 | 3 | | |
| 6 | នីតិសមុទ្រ (Law of the Sea)/ កំណែទម្រង់រដ្ឋបាលសាធារណៈ (Public Administration Reform) | 45 | 3 | 2 | |
| 7 | គ្រប់គ្រងសាធារណៈ (Pubic Management) | 45 | 3 | | |
| 8 | ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលអាស៊ាន (ASEAN Administrative Management System) | 45 | 3 | | |
| 9 | ទ្រឹស្តីនៃរដ្ឋ (Theory of the State) | 45 | 3 | | |
| 10 | ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ (Human Resources in Public Administration) | 45 | 3 | 1 | **ឆ្នាំទី២** |
| 11 | នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប (Comparative Constitutional Law) | 45 | 3 | | |
| 12 | វិធីសាស្ត្រនិងគោលការណ៍បកស្រាយគតិយុត្ត (Methodology and Principle of Legal Interpretation) | 45 | 3 | | |
| 13 | ច្បាប់សភាកម្ពុជា (Law of Cambodian Assembly)/ អភិបាលកិច្ចល្អ (Good Governance) | 45 | 3 | | |
| 14 | ហិរញ្ញវត្ថុសាធារណៈ (Public Finance) | 45 | 3 | 2 | ប្រឡង (បញ្ចប់) |
| 15 | វិវាទរដ្ឋបាល (Administrative Disputes) | 45 | 3 | | |
| 16 | នីតិទ្រព្យសម្បត្តិសាធារណៈ (Public Property Law) | 45 | 3 | | |
| 17 | ការសរសេររបាយការណ៍ស្រាវជ្រាវ (Report Writing) | | 3 | | |
| 18 | ការសរសេរនិក្ខេបបទ (Thesis Writing) | | 12 | ការពារនិក្ខេបបទ | |
| 19 | សិក្ខាសាលា និងសកម្មភាពសង្គម (Seminars & Social Activities) | | 1 | | |
| | **សរុប** (Total) | **720** | **52** | | |

## សម្គាល់៖

មុខវិជ្ជាគ្រប់គ្រងសាធារណៈបង្រៀនជាថ្នាក់សិក្ខាសាលា ចំណែកមុខវិជ្ជាធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈជាថ្នាក់ជជែកដេញដោល។

និស្សិតទាំងអស់ត្រូវជ្រើសរើសប្រធានបទស្រាវជ្រាវនៅចុងឆមាសទី១នៃឆ្នាំទី១។ និស្សិតដែលជ្រើសរើសការប្រឡងបញ្ចប់ ត្រូវសរសេររបាយការណ៍ស្រាវជ្រាវចាប់ពីឆមាសទី២ នៃឆ្នាំទី១ និងរៀន៣មុខវិជ្ជានៅឆមាសទី២នៃឆ្នាំទី២ដើម្បីប្រឡងបញ្ចប់។ មុខវិជ្ជាបម្រុងមួយចំនួននឹងកំណត់ ដោយសាកលវិទ្យាល័យ។ សាកលវិទ្យាល័យរក្សាសិទ្ធិផ្តល់ក្រេឌីតមួយចំនួនទៅលើសកម្មភាពផ្សេងៗរបស់និស្សិត និងទទួលស្គាល់ការផ្ទេរក្រេឌីតពីសាកលវិទ្យាល័យដៃគូនានាដែលបានព្រមព្រៀង។ និស្សិតដែលសរសេរនិក្ខេបបទ ត្រូវស្រាវជ្រាវចាប់ពីឆមាសទី២នៃឆ្នាំទី១តទៅ និងបញ្ចប់ស្តាពរនៅឆមាសទី២ នៃឆ្នាំទី១ ដើម្បីការពារបញ្ចប់។ ឆមាសទី២នៃឆ្នាំទី១ មានមួយមុខវិជ្ជាសិក្សាក្នុងទម្រង់ជាសិក្ខាសាលា និងឆមាសទី១នៃឆ្នាំទី២ មានមួយមុខវិជ្ជាសិក្សាទម្រង់ជាការពិភាក្សាដេញដោលគ្នា។ និស្សិតត្រូវចូលរួមសិក្ខាសាលាចំនួនយ៉ាងតិច៤ដង និងធ្វើសកម្មភាពសង្គមយ៉ាងហោច១កម្មវិធី ទើបអាចបំពេញលក្ខខណ្ឌទទួលសញ្ញាបត្រ។

កម្មវិធីសិក្សានេះនឹងត្រូវអនុវត្តចំពោះនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ចាប់ពីជំនាន់២១ ជំហាន១តទៅ។

# កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសហិរញ្ញវត្ថុ

(Curriculum for Master of Business in Finance)

| ល.រ | មុខវិជ្ជា (Subjects) | ចំនួនម៉ោង | ចំនួនក្រេឌីត | ឆមាស | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | គណនេយ្យហិរញ្ញវត្ថុកម្រិតមធ្យម (Intermediate Financial Accounting) | 45 | 3 | 1 | **ឆ្នាំទី១** |
| 2 | មីក្រូសេដ្ឋកិច្ចកម្រិតមធ្យម (Intermediate Microeconomics) | 45 | 3 | | |
| 3 | ស្ថិតិពាណិជ្ជកម្មអនុវត្ត (Applied Business Statistics) | 45 | 3 | | |
| 4 | វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា (Research Methodology and Academic Writing) | 45 | 3 | | |
| 5 | ក្រមសីលធម៌ធុរកិច្ច និងភាពជាអ្នកដឹកនាំ (Business Ethics and Leadership) | 45 | 3 | | |
| 6 | ស្ថាប័ន និងទីផ្សារហិរញ្ញវត្ថុ (Financial Markets and Institutions) | 45 | 3 | 2 | |
| 7 | ម៉ាក្រូសេដ្ឋកិច្ចកម្រិតមធ្យម (Intermediate Macroeconomics)/ អភិបាលកិច្ចសាជីវកម្ម (Corporate Governance) | 45 | 3 | | |
| 8 | វិភាគវិនិយោគ (Investment Analysis) | 45 | 3 | | |
| 9 | ហិរញ្ញវត្ថុសាជីវកម្ម (Corporate Finance) | 45 | 3 | | |
| 10 | គ្រប់គ្រងផលបត្រ (Portfolio Management) | 45 | 3 | 1 | **ឆ្នាំទី២** |
| 11 | វិនិយោគ និងហិរញ្ញវត្ថុនៃអចលនទ្រព្យ (Real Estate Finance and Investments) | 45 | 3 | | |
| 12 | ហិរញ្ញវត្ថុសាជីវកម្មកម្រិតខ្ពស់ (Advanced Corporate Finance) | 45 | 3 | | |
| 13 | ករណីសិក្សាក្នុងហិរញ្ញវត្ថុ (Case Study in Finance)/ គ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុ (Financial Institution Management) | 45 | 3 | | |
| 14 | គ្រប់គ្រងហិរញ្ញវត្ថុអន្តរជាតិ (International Financial Management) | 45 | 3 | 2 | ប្រឡង (បញ្ចប់) |
| 15 | ទីផ្សារឧបករណ៍និទស្សន៍ និងសញ្ញាប័ណ្ណ (Bond and Derivatives Markets) | 45 | 3 | | |
| 16 | ធានារ៉ាប់រង និងគ្រប់គ្រងហានិភ័យ (Risk Management and Insurance) | 45 | 3 | | |
| 17 | ការសរសេររបាយការណ៍ស្រាវជ្រាវ (Report Writing) | | 3 | | |
| 18 | ការសរសេរនិក្ខេបបទ (Thesis Writing) | | 12 | ការពារនិក្ខេបបទ | |
| 19 | សិក្ខាសាលា និងសកម្មភាពសង្គម (Seminars & Social Activities) | | 1 | | |
| | **សរុប** (Total) | **720** | **52** | | |

## សម្គាល់៖

មុខវិជ្ជាវិភាគវិនិយោគបង្រៀនជាថ្នាក់សិក្ខាសាលា ចំណែកមុខវិជ្ជាវិនិយោគ និងហិរញ្ញវត្ថុនៃអចលនទ្រព្យ ជាថ្នាក់ជដែកដេញដោល។

និស្សិតទាំងអស់ត្រូវជ្រើសរើសប្រធានបទស្រាវជ្រាវនៅចុងឆមាសទី១នៃឆ្នាំទី១។ និស្សិតដែលជ្រើសរើសការប្រឡងបញ្ចប់ ត្រូវសរសេររបាយការណ៍ស្រាវជ្រាវចាប់ពីឆមាសទី២ នៃឆ្នាំទី១ និងរៀន៣មុខវិជ្ជានៅឆមាសទី២នៃឆ្នាំទី២ដើម្បីប្រឡងបញ្ចប់។ មុខវិជ្ជាបម្រុងមួយចំនួននឹងកំណត់ ដោយសាកលវិទ្យាល័យ។ សាកលវិទ្យាល័យរក្សាសិទ្ធិផ្តល់ក្រេឌីតមួយចំនួនទៅលើសកម្មភាពផ្សេងៗរបស់និស្សិត និងទទួលស្គាល់ការផ្ទេរក្រេឌីតពីសាកលវិទ្យាល័យដៃគូនានាដែលបានព្រមព្រៀង។ និស្សិតដែលសរសេរនិក្ខេបបទ ត្រូវស្រាវជ្រាវចាប់ពីឆមាសទី២នៃឆ្នាំទី១តទៅ និងបញ្ចប់ស្ពាពនៅឆមាសទី២ នៃឆ្នាំទី១ ដើម្បីការពារបញ្ចប់។ ឆមាសទី២នៃឆ្នាំទី១ មានមួយមុខវិជ្ជាសិក្សាក្នុងទម្រង់ជាសិក្ខាសាលា និងឆមាសទី១នៃឆ្នាំទី២ មានមួយមុខវិជ្ជាសិក្សាទម្រង់ជាការពិភាក្សាដេញដោលគ្នា។ និស្សិតត្រូវចូលរួមសិក្ខាសាលាចំនួនយ៉ាងតិច៤ដង និងធ្វើសកម្មភាពសង្គមយ៉ាងហោច១កម្មវិធី ទើបអាចបំពេញលក្ខខណ្ឌទទួលសញ្ញាបត្រ។

កម្មវិធីសិក្សានេះនឹងត្រូវអនុវត្តចំពោះនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ចាប់ពីជំនាន់២១ ជំហាន១តទៅ។

# កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រង

(Curriculum for Master of Business in Management)

| ល.រ | មុខវិជ្ជា (Subjects) | ចំនួនម៉ោង | ចំនួនក្រេឌីត | ឆមាស | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | គណនេយ្យគ្រប់គ្រង (Managerial Accounting) | 45 | 3 | 1 | **ឆ្នាំទី១** |
| 2 | សេដ្ឋកិច្ចគ្រប់គ្រង (Managerial Economics) | 45 | 3 | | |
| 3 | ស្ថិតិពាណិជ្ជកម្មអនុវត្ត (Applied Business Statistics) | 45 | 3 | | |
| 4 | វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា (Research Methodology and Academic Writing) | 45 | 3 | | |
| 5 | ក្រមសីលធម៌ធុរកិច្ច និងភាពជាអ្នកដឹកនាំ (Business Ethics and Leadership) | 45 | 3 | | |
| 6 | គ្រប់គ្រងផលិតកម្ម និងប្រតិបត្តិការ (Production and Operation Management) | 45 | 3 | 2 | |
| 7 | ស្ថាប័ន និងទីផ្សារហិរញ្ញវត្ថុ (Financial Markets and Institutions)/ អភិបាលកិច្ចសាជីវកម្ម (Corporate Governance) | 45 | 3 | | |
| 8 | ហិរញ្ញវត្ថុសាជីវកម្ម (Corporate Finance) | 45 | 3 | | |
| 9 | គ្រប់គ្រងធនធានមនុស្ស (Human Resource Management) | 45 | 3 | | |
| 10 | ករណីសិក្សាក្នុងការគ្រប់គ្រង (Case Study in Management)/ គ្រប់គ្រងនវានុវត្តន៍ (Managing Innovation) | 45 | 3 | 1 | **ឆ្នាំទី២** |
| 11 | គ្រប់គ្រង និងវិភាគគម្រោង (Project Analysis & Management) | 45 | 3 | | |
| 12 | គ្រប់គ្រងម៉ាឃេធីង (Marketing Management) | 45 | 3 | | |
| 13 | ប្រព័ន្ធព័ត៌មានគ្រប់គ្រង (Management Information System) | 45 | 3 | | |
| 14 | គ្រប់គ្រងអន្តរជាតិ (International Management) | 45 | 3 | 2 | ប្រឡង (បញ្ចប់) |
| 15 | គ្រប់គ្រងបម្រែបម្រួល (Management of Change) | 45 | 3 | | |
| 16 | ផែនការយុទ្ធសាស្ត្រសាជីវកម្ម (Corporate Strategic Planning) | 45 | 3 | | |
| 17 | ការសរសេររបាយការណ៍ស្រាវជ្រាវ (Report Writing) | | 3 | | |
| 18 | ការសរសេរនិក្ខេបបទ (Thesis Writing) | | 12 | ការពារនិក្ខេបបទ | |
| 19 | សិក្ខាសាលា និងសកម្មភាពសង្គម (Seminars & Social Activities) | | 1 | | |
| | **សរុប** (Total) | **720** | **52** | | |

## សម្គាល់៖

មុខវិជ្ជាគ្រប់គ្រងធនធានមនុស្សបង្រៀនជាថ្នាក់សិក្ខាសាលា ចំណែកមុខវិជ្ជាគ្រប់គ្រង និងវិភាគគម្រោង ជាថ្នាក់ជជែកដេញដោល។

និស្សិតទាំងអស់ត្រូវជ្រើសរើសប្រធានបទស្រាវជ្រាវនៅចុងឆមាសទី១នៃឆ្នាំទី១។ និស្សិតដែលជ្រើសរើសការប្រឡងបញ្ចប់ ត្រូវសរសេររបាយការណ៍ស្រាវជ្រាវចាប់ពីឆមាសទី២ នៃឆ្នាំទី១ និងរៀន៣មុខវិជ្ជានៅឆមាសទី២នៃឆ្នាំទី២ដើម្បីប្រឡងបញ្ចប់។ មុខវិជ្ជាបម្រុងមួយចំនួននឹងកំណត់ ដោយសាកលវិទ្យាល័យ។ សាកលវិទ្យាល័យរក្សាសិទ្ធិផ្ដល់ក្រេឌីតមួយចំនួនទៅលើសកម្មភាពផ្សេងៗរបស់និស្សិត និងទទួលស្គាល់ការផ្ទេរក្រេឌីតពីសាកលវិទ្យាល័យដៃគូនានាដែលបានព្រមព្រៀង។ និស្សិតដែលសរសេរនិក្ខេបបទ ត្រូវស្រាវជ្រាវចាប់ពីឆមាសទី២នៃឆ្នាំទី១តទៅ និងបញ្ចប់ស្ថាពរនៅឆមាសទី២ នៃឆ្នាំទី១ ដើម្បីការពារបញ្ចប់។ ឆមាសទី២នៃឆ្នាំទី១ មានមួយមុខវិជ្ជាសិក្សាក្នុងទម្រង់ជាសិក្ខាសាលា និងឆមាសទី១នៃឆ្នាំទី២ មានមួយមុខវិជ្ជាសិក្សាទម្រង់ជាការពិភាក្សាដេញដោលគ្នា។ និស្សិតត្រូវចូលរួមសិក្ខាសាលាចំនួនយ៉ាងតិច៤ដង និងធ្វើសកម្មភាពសង្គមយ៉ាងហោច១កម្មវិធី ទើបអាចបំពេញលក្ខខណ្ឌទទួលសញ្ញាបត្រ។

កម្មវិធីសិក្សានេះនឹងត្រូវអនុវត្តចំពោះនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ចាប់ពីជំនាន់២១ ជំហាន១តទៅ។

## ៨.៣. កម្មវិធីសិក្សាថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ និងធុរកិច្ច

សាលាក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបើកបណ្តុះបណ្តាលថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ និងធុរកិច្ច សម្រាប់និស្សិតដែលមានបរិញ្ញាបត្រជំនាញមិនមែននីតិសាស្ត្រ និងធុរកិច្ច ចង់រៀនបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ និងធុរកិច្ច មានកម្មវិធីដូចខាងក្រោម៖

### កម្មវិធីសិក្សាថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ

| ល.រ | កូដមុខវិជ្ជា | មុខវិជ្ជា | ចំនួនម៉ោង | ចំនួនក្រេឌីត |
|---|---|---|---|---|
| 1 | PLLM001 | នីតិរដ្ឋធម្មនុញ្ញ (Constitutional Law) | 32 | 2 |
| 2 | PLLM002 | ទំនាក់ទំនងអន្តរជាតិ (International Relations) | 32 | 2 |
| 3 | PLLM003 | នីតិរដ្ឋបាល (Administrative Law) | 32 | 2 |
| 4 | PLLM004 | នីតិរដ្ឋប្បវេណី (Civil Law) | 32 | 2 |
| 5 | PLLM005 | សេចក្តីផ្តើមនីតិ (introduction to Law) | 32 | 2 |
| 6 | PLLM006 | ស្ថាប័នតុលាការ (Court Institutions) | 32 | 2 |
| | | **សរុប(Total)** | **192** | **12** |

### កម្មវិធីសិក្សាថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច

| ល.រ | កូដមុខវិជ្ជា | មុខវិជ្ជា | ចំនួនម៉ោង | ចំនួនក្រេឌីត |
|---|---|---|---|---|
| 1 | PMBus001 | មីក្រូសេដ្ឋកិច្ច (Micro Economics) | 45 | 3 |
| 2 | PMBus002 | ម៉ាក្រូសេដ្ឋកិច្ច (Macro Economics) | 45 | 3 |
| 3 | PMBus003 | គណនេយ្យហិរញ្ញវត្ថុ (Financial Accounting) | 45 | 3 |
| 4 | PMBus004 | ស្ថិតិ (Statistics) | 45 | 3 |
| | | **សរុប(Total)** | **180** | **12** |

**សម្គាល់៖** * ថ្នាក់ត្រៀមបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ និងធុរកិច្ច មានតែ វេន ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ

- ថ្ងៃសៅរ៍ ម៉ោង ១៣:០០-២០:០០
- ថ្ងៃអាទិត្យ ម៉ោង ០៧:០០-១៣:០០



ការប្រជុំជាមួយគ្រូបង្រៀននៅសាលាក្រោយបរិញ្ញាបត្រ
ក្រោមអធិបតីភាពរបស់សាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី សាកលវិទ្យាធិការរង
នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៥

## ៩. ស្ថិតិនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២៤

សាលាក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបើកបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមរូបភាពបង់ថ្លៃ ចាប់ផ្តើមពីចុងឆ្នាំ២០០៣។ ដោយសារថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាតែរយៈពេល ២ឆ្នាំ នាំឱ្យនៅឆ្នាំ២០០៦ សាកលវិទ្យាល័យបានបញ្ចេញធនធានមនុស្សជាច្រើនសម្រាប់បម្រើសង្គមជាតិ រហូតមកដល់ឆ្នាំ២០២៤ មានស្ថិតិតាមជំនាញដូចខាងក្រោម៖

ជំនាញនីតិសាស្ត្រ សរុបមាន ៥.៨៨៥ នាក់ ចែកចេញជា៖

- ឯកទេស រដ្ឋបាលសាធារណៈ ចំនួន ២.៨៧៤ នាក់
- ឯកទេស នីតិឯកជន ចំនួន ៣.០១១ នាក់

ជំនាញធុរកិច្ច សរុបមាន ២.៩០៦ នាក់ ដែលចែកចេញជា៖

- ឯកទេស គ្រប់គ្រងហិរញ្ញវត្ថុ ចំនួន ១.៥៧៨ នាក់
- ឯកទេស គ្រប់គ្រងទូទៅ ចំនួន ១.៣២៨ នាក់

### ៩.១. ស្ថិតិនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ

តារាងខាងក្រោមជាចំនួននិស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ តាមឆ្នាំនីមួយៗ តាមឯកទេសនីមួយៗ និងសរុបចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២៤៖

| ឆ្នាំ | នីតិឯកជន | រដ្ឋបាលសាធារណៈ | សរុប |
|---|---|---|---|
| 2006 | 98 | 239 | 337 |
| 2007 | 53 | 103 | 156 |
| 2008 | 88 | 164 | 252 |
| 2009 | 58 | 134 | 192 |
| 2010 | 167 | 211 | 378 |
| 2011 | 180 | 103 | 283 |
| 2012 | 167 | 325 | 492 |
| 2013 | 231 | 227 | 458 |
| 2014 | 98 | 72 | 170 |
| 2015 | 254 | 142 | 396 |
| 2016 | 219 | 153 | 372 |
| 2017 | 200 | 143 | 343 |
| 2018 | 219 | 147 | 366 |
| 2019 | 159 | 128 | 287 |
| 2020 | 181 | 168 | 349 |
| 2021 | 206 | 155 | 361 |
| 2022 | 122 | 72 | 194 |
| 2023 | 193 | 126 | 319 |
| 2024 | 118 | 62 | 180 |
| សរុប | 3011 | 2874 | 5885 |

ក្រាហ្វិចខាងក្រោមជាបម្រែបម្រួលនិស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ តាមឆ្នាំនីមួយៗ តាមឯកទេសនីមួយៗ និងសរុប ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២៤៖




## ៩.២. ស្ថិតិនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច

តារាងខាងក្រោមជាចំនួននិស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច តាមឆ្នាំនីមួយៗ តាមឯកទេសនីមួយៗ និងសរុបចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២៤៖

| ឆ្នាំ | ហិរញ្ញវត្ថុ | គ្រប់គ្រង | សរុប |
|---|---|---|---|
| 2006 | 54 | 40 | 94 |
| 2007 | 36 | 16 | 52 |
| 2008 | 83 | 71 | 154 |
| 2009 | 60 | 56 | 116 |
| 2010 | 173 | 90 | 263 |
| 2011 | 114 | 72 | 186 |
| 2012 | 167 | 113 | 280 |
| 2013 | 199 | 81 | 280 |
| 2014 | 75 | 66 | 141 |
| 2015 | 124 | 107 | 231 |
| 2016 | 99 | 99 | 198 |
| 2017 | 75 | 88 | 163 |
| 2018 | 61 | 99 | 160 |
| 2019 | 57 | 70 | 127 |
| 2020 | 68 | 87 | 155 |
| 2021 | 48 | 90 | 138 |
| 2022 | 37 | 39 | 76 |
| 2023 | 31 | 28 | 59 |
| 2024 | 17 | 16 | 33 |
| សរុប | 1578 | 1328 | 2906 |

ក្រាហ្វិចខាងក្រោមជាបម្រែបម្រួលនិស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច តាមឆ្នាំនីមួយៗ តាមឯកទេសនីមួយៗ និងសរុប ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២៤៖




## ៩.៣. ស្ថិតិនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

តារាងខាងក្រោមជាចំនួននិស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ តាមឆ្នាំនីមួយៗ តាមបរិញ្ញាបត្រជាន់ខ្ពស់ និងសរុបចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២៤៖

| ឆ្នាំ | នីតិសាស្ត្រ | ធុរកិច្ច | សរុប |
|---|---|---|---|
| 2006 | 337 | 94 | 431 |
| 2007 | 156 | 52 | 208 |
| 2008 | 252 | 154 | 406 |
| 2009 | 192 | 116 | 308 |
| 2010 | 378 | 263 | 641 |
| 2011 | 283 | 186 | 469 |
| 2012 | 492 | 280 | 772 |
| 2013 | 458 | 280 | 738 |
| 2014 | 170 | 141 | 311 |
| 2015 | 396 | 231 | 627 |
| 2016 | 372 | 198 | 570 |
| 2017 | 343 | 163 | 506 |
| 2018 | 366 | 160 | 526 |
| 2019 | 287 | 127 | 414 |
| 2020 | 349 | 155 | 504 |
| 2021 | 361 | 138 | 499 |
| 2022 | 194 | 76 | 270 |
| 2023 | 319 | 59 | 378 |
| 2024 | 180 | 33 | 213 |
| សរុប | 5885 | 2906 | 8791 |

ក្រាហ្វិចខាងក្រោមជាបម្រែបម្រួលនិស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ តាមឆ្នាំនីមួយៗ តាមបរិញ្ញាបត្រជាន់ខ្ពស់ និងសរុបចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២៤៖






ការប្រជុំជាមួយគ្រូបង្រៀននៅសាលាក្រោយបរិញ្ញាបត្រ
ក្រោមអធិបតីភាពរបស់សាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី សាកលវិទ្យាធិការរង
នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៥

# ផ្នែកទី៣
# ការបណ្តុះបណ្តាល
# ថ្នាក់បណ្ឌិត

## ១. គោលការណ៍បណ្តុះបណ្តាលថ្នាក់បណ្ឌិត

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត គឺជាការផ្តល់ឱកាសឲ្យនិស្សិតធ្វើការសិក្សាស្រាវជ្រាវកម្រិតខ្ពស់ ប្រកបដោយការវិភាគដ៏ស៊ីជម្រៅលើមុខជំនាញផ្សេងៗដែលស្ថិតនៅក្នុងវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រពិត។

គោលបំណងនៃការបណ្តុះបណ្តាលនេះ គឺដើម្បីអភិវឌ្ឍធនធានមនុស្សដែលពោរពេញដោយចំណេះដឹង និងសមត្ថភាពខ្ពស់ប្រកបដោយគុណធម៌ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។

និស្សិតថ្នាក់បណ្ឌិតទាំងអស់ ត្រូវបំពេញលក្ខខណ្ឌទាំងឡាយដែលកំណត់ដោយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

### ១.១. លក្ខខណ្ឌជ្រើសរើស

បេក្ខជនទាំងពីរភេទដែលមានបំណងបន្តការសិក្សានៅថ្នាក់បណ្ឌិត ត្រូវ៖

- ឆ្លងកាត់ការសិក្សាគ្រប់ភូមិសិក្សាដែលមានលក្ខណៈជាប្រព័ន្ធ និងប្រក្រតី
- មានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រដែលមានតម្លៃស្មើដោយមានការទទួលស្គាល់ពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ច
- ទទួលបានពិន្ទុមធ្យមភាគសរុប (GPA) នៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចាប់ពី៣.០០ឡើងទៅ ឬបានសរសេរនិក្ខេបបទ ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
- មានសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវ និងមានសំណើគម្រោងស្រាវជ្រាវបឋមច្បាស់លាស់
- មានសមត្ថភាពប្រើប្រាស់មូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវ (Words, Excel, Power Point និង Internet Search)
- មានកម្រិតយល់ដឹងភាសាបរទេស៖
    - ករណីសិក្សាជាភាសាខ្មែរ
        - មានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ពីប្រទេសក្រៅ ដែលប្រើភាសាអង់គ្លេសក្នុងការបណ្តុះបណ្តាល ឬភាសាបរទេសណាមួយទៀតសមស្របនឹងតម្រូវការរបស់មុខជំនាញបណ្តុះបណ្តាលតាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ ឬ
        - មានបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់នៅក្នុងប្រទេសដែលភាសាប្រើប្រាស់ក្នុងការបណ្តុះបណ្តាលជាភាសាអង់គ្លេសមិនឆ្លងកាត់អ្នកបកប្រែ ឬភាសាបរទេសណាមួយសមស្របនឹងតម្រូវការមុខជំនាញបណ្តុះបណ្តាលតាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ ឬ
        - មានបរិញ្ញាបត្រភាសាអង់គ្លេស ឬភាសាបរទេសណាមួយសមស្របនឹងតម្រូវការ មុខជំនាញបណ្តុះបណ្តាលតាមការសម្រេចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ ឬ
        - មានវិញ្ញាបនបត្រភាសាអង់គ្លេស TOEFL IBT ៦១ពិន្ទុ ឬTOEFL ៥០០ពិន្ទុ ឬ TOEFL ITP ៥០០ពិន្ទុ ឬ IELTS ៥.០ឡើងទៅ ឬសមមូល ឬ
        - មានកម្រិតភាសាអង់គ្លេសតាមរយៈការធ្វើតេស្តដែលរៀបចំដោយ **សភនវស**។
    - សិក្សាជាភាសាបរទេស

- ជាភាសាអង់គ្លេសត្រូវមាន TOEFL ចាប់ពី៦០០ឡើងទៅ ឬ IELTS ចាប់ពី៦,៥ ឡើងទៅ (ចំពោះនិស្សិតដែលស្រាវជ្រាវជាភាសាអង់គ្លេស)
- ជាភាសាបារាំងត្រូវមានវិញ្ញាបនបត្រភាសាបារាំង DELF ឬ DALF ឬសញ្ញាបត្រមានតម្លៃស្មើ។

## ១.២. លក្ខខណ្ឌសិក្សា

បេក្ខជនទាំងពីរភេទអាចចូលរៀនថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន លុះត្រាតែបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌជ្រើសរើសខាងលើ និងត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសដោយជោគជ័យ។ និស្សិតថ្នាក់បណ្ឌិតត្រូវបំពេញលក្ខខណ្ឌសិក្សាដែលបានកំណត់ដោយសាកលវិទ្យាល័យ។

### ១.២.១. ការជ្រើសរើសគ្រូណែនាំគោល និងសហគ្រូណែនាំ ឬគ្រូណែនាំរង

និស្សិតតម្រូវឲ្យជ្រើសរើសគ្រូណែនាំគោលដែលមានជំនាញស្របតាមប្រធានបទស្រាវជ្រាវ ដោយខ្លួនឯង។ និស្សិតក៏អាចជ្រើសរើសសហគ្រូណែនាំ ឬគ្រូណែនាំរងដោយខ្លួនឯងផងដែរ។ ក្នុងករណីដែលនិស្សិតបានដាក់គម្រោងស្រាវជ្រាវបឋមដោយមិនបានបញ្ជាក់ឈ្មោះគ្រូណែនាំគោល និងសហគ្រូណែនាំ ឬគ្រូណែនាំរង សាកលវិទ្យាល័យនឹងពិនិត្យលទ្ធភាពស្វែងរកគ្រូបង្រៀនណាដែលមានមុខជំនាញត្រូវគ្នានឹងប្រធានបទស្រាវជ្រាវរបស់និស្សិតនោះ។ ក្នុងករណីរកគ្រូណែនាំគោលមិនបាន និស្សិតមិនត្រូវបានជ្រើសរើសឲ្យចូលរៀនថ្នាក់បណ្ឌិតទេ។

### ១.២.២. ការសិក្សា

- **ឆ្នាំទី១៖** និស្សិតត្រូវសិក្សាមុខវិជ្ជាមួយចំនួនដើម្បីទទួលបានចំណេះដឹងជាមូលដ្ឋានក្នុងការស្រាវជ្រាវ និងពិគ្រោះយោបល់ជាមួយគ្រូណែនាំគោល និងសហគ្រូណែនាំ ឬគ្រូណែនាំរង។

| លរ | មុខវិជ្ជាសិក្សា | ក្រេឌីត | ចំនួនម៉ោង |
|---|---|---|---|
| 1 | វិធីសាស្ត្រស្រាវជ្រាវ | 3 | 45 |
| 2 | ស្ថិតិស្រាវជ្រាវ | 3 | 45 |
| 3 | មុខវិជ្ជាជំនាញ | 9 | 135 |
| 4 | ការស្រាវជ្រាវ និងការណែនាំ (១) | 3 | 45 |
| សរុប | | 18 | 270 |

- **ឆ្នាំទី២៖** និស្សិតត្រូវស្រាវជ្រាវ និងពិគ្រោះយោបល់ជាមួយគ្រូណែនាំគោល និងសហគ្រូណែនាំ ឬគ្រូណែនាំរង និងស្វែងរកស្ថាប័នចុះផ្សាយអត្ថបទស្រាវជ្រាវ។

| លរ | ផែនការស្រាវជ្រាវ | ក្រេឌីត | ចំនួនម៉ោង |
|---|---|---|---|
| 1 | ការស្រាវជ្រាវ និងការណែនាំ (២) | 3 | 45 |
| 2 | ការអភិវឌ្ឍ និងការការពារគម្រោងស្រាវជ្រាវ | 3 | |
| 3 | ការចូលរួមវេទិកាវិទ្យាសាស្ត្រ ដោយមានធ្វើបទបង្ហាញ | 2 | |
| 4 | ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន(១) | 2 | |
| 5 | ការចុះផ្សាយអត្ថបទស្រាវជ្រាវ (១) | 3 | |
| សរុប | | 13 | 45 |

- **ឆ្នាំទី៣៖** និស្សិតត្រូវស្រាវជ្រាវ និងពិគ្រោះយោបល់ជាមួយគ្រូណែនាំគោល និងសហគ្រូណែនាំ ឬគ្រូណែនាំរង និងការពារនិក្ខេបបទបញ្ចប់។

| លរ | ផែនការស្រាវជ្រាវ | ក្រេឌីត | ចំនួនម៉ោង |
|---|---|---|---|
| 1 | ការស្រាវជ្រាវ និងការណែនាំ (៣) | 3 | 45 |
| 2 | ការចូលរួមវេទិកាវិទ្យាសាស្ត្រ ដោយមានធ្វើបទបង្ហាញ | 1 | |
| 3 | ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន (២) | 1 | |
| 4 | ការចុះផ្សាយអត្ថបទស្រាវជ្រាវ (២) | 3 | |
| 5 | ការការពារនិក្ខេបបទសាកល្បង | 3 | |
| 6 | ការវាយតម្លៃនិក្ខេបបទ | 15 | |
| 7 | ការការពារនិក្ខេបបទបញ្ចប់ | 3 | |
| សរុប | | 29 | 45 |

ចំនួនក្រេឌីតសរុបសម្រាប់បញ្ចប់ការសិក្សាថ្នាក់បណ្ឌិតមាន៦០ក្រេឌីត។

ការចុះផ្សាយអត្ថបទស្រាវជ្រាវអាចធ្វើឡើងនៅឆ្នាំទី១ក៏បាន។

### ១.២.៣. ការពិគ្រោះយោបល់ជាមួយគ្រូណែនាំគោល និងសហគ្រូណែនាំ ឬគ្រូណែនាំរង

និស្សិតត្រូវជួបពិភាក្សាជាមួយគ្រូណែនាំគោលជាប្រចាំ យ៉ាងហោចណាស់ពីរដងក្នុងមួយខែ ដោយបញ្ជូនរបាយការណ៍សង្ខេបពីការពិភាក្សាជូននាយកសាលាក្រោយបរិញ្ញាបត្រ។

និស្សិតអាចពិគ្រោះយោបល់ជាមួយសហគ្រូណែនាំ ឬគ្រូណែនាំរង និងរាយការណ៍ពីការពិគ្រោះយោបល់ជូននាយកសាលាក្រោយបរិញ្ញាបត្រ។ ការជួបពិគ្រោះយោបល់ជាមួយសហគ្រូណែនាំ ឬគ្រូណែនាំរង យ៉ាងហោចណាស់មួយដងក្នុងមួយខែ។

### ១.២.៤. រយៈពេលសិក្សា

រយៈពេលសិក្សាថ្នាក់បណ្ឌិតសម្រាប់និស្សិតពេញម៉ោងត្រូវស្ថិតក្នុងចន្លោះពី៣ឆ្នាំ ទៅ៦ឆ្នាំ។

រយៈពេលសិក្សាថ្នាក់បណ្ឌិតសម្រាប់និស្សិតមិនពេញម៉ោងត្រូវស្ថិតក្នុងចន្លោះពី៣ឆ្នាំ ទៅ៨ឆ្នាំ។

### ១.២.៥. ប្រភេទនិស្សិត

និស្សិតដែលសិក្សាថ្នាក់បណ្ឌិតចែកចេញជាពីរប្រភេទ គឺនិស្សិតពេញម៉ោង និងនិស្សិតមិនពេញម៉ោង។

និស្សិតពេញម៉ោងជានិស្សិតដែលមិនបំពេញការងារពេញម៉ោងនៅស្ថាប័នផ្សេង និងសិក្សាពេញម៉ោងនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ និស្សិតប្រភេទនេះ អាចធ្វើការក្រៅម៉ោងបានតែមិនត្រូវលើសពី១៨ម៉ោងក្នុងមួយសប្តាហ៍។ ក្នុងករណីនិស្សិតកំពុងបំពេញការងារពេញម៉ោងនៅស្ថាប័នផ្សេង អាចក្លាយជានិស្សិតពេញម៉ោងបានលុះត្រាតែនិស្សិតនោះបានទទួលការអនុញ្ញាតពីកន្លែងការងារដើមរបស់ខ្លួនដើម្បីមកសិក្សាពេញម៉ោង។

និស្សិតមិនពេញម៉ោងជានិស្សិតដែលបំពេញការងារពេញម៉ោងនៅស្ថាប័នផ្សេង និងសិក្សាក្រៅម៉ោងនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

#### ១.២.៦. តម្លៃសិក្សា

តម្លៃសិក្សាថ្នាក់បណ្ឌិតគឺ៥០០០ដុល្លារក្នុងមួយឆ្នាំសិក្សា សម្រាប់រយៈពេលសិក្សា៣ឆ្នាំ។

ក្នុងករណីនិស្សិតសិក្សាលើសពី៣ឆ្នាំ និស្សិតដែលមិនបានឆ្លងកាត់ការការពារសាកល្បងដោយជោគជ័យ ត្រូវបង់ថ្លៃសិក្សាចំនួន១០០០ដុល្លារក្នុង១ឆ្នាំសិក្សា ប៉ុន្តែនិស្សិតដែលបានទទួលជោគជ័យក្នុងការការពារសាកល្បង ហើយរង់ចាំតែការការពារនិក្ខេបបទបញ្ចប់មិនចាំបាច់បង់ថ្លៃសិក្សាទេ។

### ១.៣. លក្ខខណ្ឌបញ្ចប់ការសិក្សា

#### ១.៣.១. ការសិក្សាមុខវិជ្ជាចាំបាច់មួយចំនួន

និស្សិតត្រូវរៀនមុខជំនាញសិក្សាដែលកំណត់ដោយសាកលវិទ្យាល័យ និងត្រូវបំពេញតាមលក្ខខណ្ឌដែលកំណត់ដោយគ្រូបង្រៀន ទើបអាចចាត់ទុកថាបានទទួលចំនួនក្រេឌីតទៅតាមមុខវិជ្ជានោះ។

#### ១.៣.២. ការការពារគម្រោងស្រាវជ្រាវ

និស្សិតត្រូវបានអនុញ្ញាតឲ្យការពារគម្រោងស្រាវជ្រាវបាន លុះត្រាតែបានទទួលការយល់ព្រមពីគ្រូណែនាំគោល។ លទ្ធផលនៃការការពារគម្រោងស្រាវជ្រាវចាត់ទុកថាជោគជ័យ លុះត្រាតែទទួលបានសំឡេងគាំទ្រ ឲ្យស្រាវជ្រាវពីរភាគបីនៃសមាសភាពគណៈកម្មការការពារគម្រោងស្រាវជ្រាវ។

ក្នុងករណីដែលការការពារគម្រោងស្រាវជ្រាវមិនបានជោគជ័យ និស្សិតអាចបន្តសិក្សាស្រាវជ្រាវ និងការពារគម្រោងនេះឡើងវិញក្នុងរយៈពេលចន្លោះពី៣ខែទៅ១ឆ្នាំ។ ការការពារគម្រោងស្រាវជ្រាវឡើងវិញអាចត្រូវបានអនុញ្ញាតចំនួនពីរដងយ៉ាងច្រើន និងមានរយៈពេលសរុបមិនលើសពី១ឆ្នាំ។ ក្នុងករណីដែលការរៀបចំការពារគម្រោងស្រាវជ្រាវឡើងវិញលើសពីរយៈពេល១ឆ្នាំ និស្សិតត្រូវបានចាត់ទុកថាធ្លាក់។

#### ១.៣.៣. ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធដោយមានធ្វើបទបង្ហាញ

និស្សិតថ្នាក់បណ្ឌិតត្រូវចូលរួមធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា និងសន្និសីទថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិ។ ការធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ឬសន្និសីទថ្នាក់ជាតិ ដោយមានឯកសារធ្វើបទបង្ហាញជា slides ម្តង ត្រូវទទួលបាន១ក្រេឌីត។ ការធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលា ឬសន្និសីទថ្នាក់អន្តរជាតិម្តង ត្រូវទទួលបាន១,៥ក្រេឌីត។ ប៉ុន្តែ បើមានការសរសេរជាអត្ថបទសម្រាប់សិក្ខាសាលា ឬសន្និសីទថ្នាក់អន្តរជាតិ ហើយដែលអ្នករៀបចំបានបោះពុម្ពផ្សាយក្នុងពេល ឬក្រោយពេលធ្វើសិក្ខាសាលា ឬសន្និសីទថ្នាក់អន្តរជាតិ ម្តងត្រូវទទួលបាន៣ក្រេឌីតតែម្តង។

#### ១.៣.៤. ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន

និស្សិតថ្នាក់បណ្ឌិតត្រូវធ្វើសិក្ខាសាលាផ្ទាល់ខ្លួន ដោយលើកយកប្រធានបទពាក់ព័ន្ធនឹងនិក្ខេបបទផ្ទាល់ខ្លួនមកពិភាក្សា។ ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួនម្តងត្រូវទទួលបាន១ក្រេឌីត។

#### ១.៣.៥. ការចុះផ្សាយអត្ថបទស្រាវជ្រាវ

ការចុះផ្សាយអត្ថបទស្រាវជ្រាវរបស់និស្សិតត្រូវមានការឯកភាពពីគ្រូណែនាំគោល និងបានទទួលការយល់ព្រមឲ្យចុះផ្សាយដោយទស្សនាវដ្តីវិទ្យាសាស្ត្រណាមួយដែលកំណត់ដោយសាកលវិទ្យាល័យ។ ការចុះផ្សាយក្នុងទស្សនាវដ្តីម្តងនឹងត្រូវទទួលបាន៣ក្រេឌីត។

### ១.៣.៦. ការការពារនិក្ខេបបទសាកល្បង

និស្សិតត្រូវបានអនុញ្ញាតឲ្យការពារនិក្ខេបបទសាកល្បងបាន លុះត្រាតែនិស្សិតបានចុះផ្សាយអត្ថបទស្រាវជ្រាវចំនួន២លើកយ៉ាងតិចដែលមាន៦ក្រេឌីត ព្រមទាំងបានទទួលការឯកភាពពីគ្រូណែនាំគោល និងសហគ្រូណែនាំ ឬគ្រូណែនាំរងយ៉ាងតិចម្នាក់។ លទ្ធផលនៃការការពារនិក្ខេបបទសាកល្បងត្រូវបានចាត់ទុកថាទទួលបានជោគជ័យ លុះត្រាតែសំឡេងគាំទ្រឲ្យបេក្ខជន អាចការពារនិក្ខេបបទបញ្ចប់បានចាប់ពីបីភាគបួននៃ សមាសភាពគណៈកម្មការការពារនិក្ខេបបទសាកល្បង។

ក្នុងករណីការពារនិក្ខេបបទសាកល្បងលើកទី១ធ្លាក់ និស្សិតត្រូវបានអនុញ្ញាតឲ្យការពារសាកល្បងឡើងវិញបាន។ ចំនួននៃការការពារសាកល្បងឡើងវិញអាចត្រូវបានអនុញ្ញាតមិនឲ្យលើសពីពីរដង និងមានរយៈពេលសរុបមិនលើសពី២ឆ្នាំឡើយ។

### ១.៣.៧. ការវាយតម្លៃនិក្ខេបបទដើម្បីដាក់ឲ្យការពារបញ្ចប់

ការវាយតម្លៃនិក្ខេបបទត្រូវបានចាត់ទុកថាជាប់ជាស្ថាពរ លុះត្រាតែលទ្ធផលសរុបនៃការវាយតម្លៃពីក្រុមអ្នកពិនិត្យវាយតម្លៃនិក្ខេបបទបានទទួលសំឡេងគាំទ្រ ចាប់ពីពីរភាគបីនៃសមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទ។

ក្នុងករណីការវាយតម្លៃនិក្ខេបបទមិនទទួលបានជោគជ័យ និស្សិតថ្នាក់បណ្ឌិតត្រូវកែលម្អ និងអភិវឌ្ឍនិក្ខេបបទឡើងវិញ និងដាក់ជូនសាកលវិទ្យាល័យសម្រាប់ការវាយតម្លៃនិក្ខេបបទម្តងទៀត។ ការដាក់ជូននិក្ខេបបទដើម្បីវាយតម្លៃឡើងវិញ អាចត្រូវបានធ្វើឡើងក្នុងអំឡុងពេលមិនឲ្យលើសពី៣ឆ្នាំ និងមានចំនួនយ៉ាងច្រើន២ដង។

### ១.៣.៨. ការការពារនិក្ខេបបទបញ្ចប់

និស្សិតអាចការពារនិក្ខេបបទបញ្ចប់បាន លុះត្រាតែនិស្សិតបានទទួលជោគជ័យនូវការការពារនិក្ខេបបទសាកល្បង ហើយនិក្ខេបបទបញ្ចប់នោះត្រូវបានកែលំអតាមអនុសាសន៍គណៈកម្មការការពារនិក្ខេបបទសាកល្បង និងត្រូវបានអនុញ្ញាតឲ្យដាក់ការពារបញ្ចប់ដោយគ្រូណែនាំគោល។ ការការពារនិក្ខេបបទបញ្ចប់ត្រូវបានចាត់ទុកថាជោគជ័យ លុះត្រាតែទទួលបានសំឡេងគាំទ្រ ចាប់ពីបីភាគបួននៃសមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់។ ក្នុងករណីការការពារមិនបានទទួលជោគជ័យ និស្សិតអាចការពារឡើងវិញក្នុងចន្លោះពេលសមស្របណាមួយដែលសរុបរយៈពេលទាំងអស់ មិនឲ្យលើសពីរយៈពេលសិក្សាថ្នាក់បណ្ឌិតទាំងមូល។ ការការពារនិក្ខេបបទឡើងវិញត្រូវបានអនុញ្ញាតតែ១ដង។

### ១.៣.៩. លទ្ធផលបញ្ចប់នៃការសិក្សាថ្នាក់បណ្ឌិត

លទ្ធផលបញ្ចប់របស់និស្សិតថ្នាក់បណ្ឌិតត្រូវបានចាត់ទុកថាជាប់ជាស្ថាពរ លុះត្រាតែនិស្សិតបានបំពេញចប់សព្វគ្រប់នូវលក្ខខណ្ឌនានារបស់សាកលវិទ្យាល័យ និងលទ្ធផលនៃការការពារនិក្ខេបបទត្រូវបានប្រកាសថាជោគជ័យ។

## ២. គោលការណ៍បង្កើតគណៈកម្មការនានាសម្រាប់ថ្នាក់បណ្ឌិត

ដើម្បីរួមចំណែកក្នុងការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា ប្រកបដោយគុណភាព និងប្រសិទ្ធភាព សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានរៀបចំគោលការណ៍ មួយចំនួនក្នុងការបង្កើតគណៈកម្មការនានាដើម្បីរៀបចំដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

### ២.១. ក្រុមប្រឹក្សាវិទ្យាសាស្ត្រ

**២.១.១**-ក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានភារកិច្ច ដូចតទៅ៖

- ផ្តល់ការប្រឹក្សាដល់សាកលវិទ្យាធិការក្នុងការងាររៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថាប័ន
- កំណត់ទិសដៅ ភារកិច្ច ផែនការរយៈពេលវែង និងវិស័យអាទិភាពស្រាវជ្រាវវិទ្យាសាស្ត្រ គោលនយោបាយ និងយន្តការក្នុងការគ្រប់គ្រងវិទ្យាសាស្ត្រ
- រៀបចំអនុវត្តកម្មវិធី និងផែនការបណ្តុះបណ្តាលប្រកបដោយគុណភាព
- ធ្វើក្រឹតការគ្រូបង្រៀន និងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រ
- រៀបចំការវាយតម្លៃស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ និងជ្រើសរើសស្នាដៃស្រាវជ្រាវដែលមានគុណភាពសម្រាប់ការលើកសរសើរ
- ចូលរួមរៀបចំគោលការណ៍នានាសម្រាប់បណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ពិនិត្យ ផ្តល់យោបល់ស្តាបនា លើកម្មវិធីសិក្សាគ្រប់កម្រិតទាំងអស់របស់ **សភនវស**។

**២.១.២**-សមាសភាពនៃក្រុមប្រឹក្សាវិទ្យាសាស្ត្ររួមមាន៖

| | |
|---|---|
| - សាកលវិទ្យាធិការ | ប្រធាន |
| - សាកលវិទ្យាធិការរងទទួលបន្ទុកសិក្សា | អនុប្រធាន |
| - នាយកសាលាក្រោយបរិញ្ញាបត្រ | អនុប្រធាន |
| - គ្រូបង្រៀនដែលមានសញ្ញាបត្របណ្ឌិតរបស់សាកលវិទ្យាល័យ | សមាជិក |

**២.១.៣**-ការវាយតម្លៃស្នាដៃស្រាវជ្រាវដែលដាក់ជូនសាកលវិទ្យាល័យ និងស្នាដៃបង្រៀនល្អរបស់គ្រូបង្រៀនត្រូវផ្អែកតាមមតិភាគច្រើនដាច់ខាតនៃសមាជិករបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រទាំងអស់។

**២.១.៤**-ប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្រ អាចចាត់តាំងអនុប្រធានណាម្នាក់ឲ្យដឹកនាំអង្គប្រជុំ ក្នុងករណីចាំបាច់។

**២.១.៥**-ប្រធានក្រុមប្រឹក្សាវិទ្យាសាស្ត្រអាចអញ្ជើញគ្រូបង្រៀនដែលមានសញ្ញាបត្របណ្ឌិត ឬភាគីពាក់-ព័ន្ធផ្សេងទៀត ពីក្រៅសាកលវិទ្យាល័យមកចូលរួមប្រជុំ ក្នុងករណីចាំបាច់។

### ២.២. គណៈកម្មការប្រឡងជ្រើសរើស

**២.២.១**-គណៈកម្មការប្រឡងជ្រើសរើសមានភារកិច្ចសម្រេចជ្រើសរើសនិស្សិត និងប្រកាសលទ្ធផលនៃការប្រឡងជ្រើសរើសនិស្សិត។

**២.២.២**-សមាសភាពនៃគណៈកម្មការប្រឡងជ្រើសរើសនិស្សិតឲ្យចូលរៀនថ្នាក់បណ្ឌិតរួមមាន៖

- សាកលវិទ្យាធិការ ប្រធាន
- សាកលវិទ្យាធិការរងទទួលបន្ទុកសិក្សា អនុប្រធាន
- នាយកសាលាក្រោយបរិញ្ញាបត្រ សមាជិក
- ក្រុមគ្រូណែនាំ សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក

គណៈកម្មការប្រឡងជ្រើសរើសមានសិទ្ធិបង្កើតគណៈកម្មការកណ្តាល អនុគណៈកម្មការមុខជំនាញ និង អនុគណៈកម្មការផ្សេងៗទៀតតាមការចាំបាច់ ដើម្បីឲ្យដំណើរការប្រឡងជ្រើសរើសប្រព្រឹត្តទៅដោយប្រសិទ្ធភាព និងមានតម្លាភាព។

**២.២.៣**-នាយកសាលាក្រោយបរិញ្ញាបត្រ ត្រូវជម្រាបជូនដំណឹងដល់គ្រូណែនាំគោល និងជូនដំណឹងទៅបេក្ខជនពីកាលបរិច្ឆេទនៃការធ្វើសម្ភាស និងរៀបចំទីកន្លែងនៃការធ្វើសម្ភាស។

**២.២.៤**-ក្រុមគ្រូណែនាំគោល មានភារកិច្ចវាយតម្លៃលើសំណុំឯកសាររបស់បេក្ខជន និងធ្វើសម្ភាសដោយផ្ទាល់។ គ្រូណែនាំគោលជាគ្រូបង្រៀនដែលមានអាទិភាពជាងគេក្នុងការសម្រេចទទួលយក និស្សិត។

**២.២.៥**-ក្រុមគ្រូណែនាំមានភារកិច្ចវាយតម្លៃលើសំណុំឯកសាររបស់បេក្ខជន និងធ្វើសម្ភាសបេក្ខជនដោយផ្ទាល់។ លទ្ធផលនៃការវាយតម្លៃលើសំណុំឯកសារ និងការធ្វើសម្ភាសចាត់ទុកថាជាប់ លុះត្រាតែនិស្សិតទទួលបានមតិឯកភាពពីគ្រូណែនាំគោល។

**២.២.៦**-បន្ទាប់ពីទទួលបានលទ្ធផលជ្រើសរើសដោយជោគជ័យពី ក្រុមគ្រូណែនាំរួចហើយ នាយកសាលាក្រោយបរិញ្ញាបត្រ ត្រូវរៀបចំប្រកាសលទ្ធផលដោយអញ្ជើញសមាសភាព នៃគណៈកម្មការប្រឡងជ្រើសរើសចូលរួមសម្រេចប្រកាសលទ្ធផលជ្រើសរើសចុងក្រោយ។

## ២.៣. ក្រុមគ្រូណែនាំ

**២.៣.១**-ក្រុមគ្រូណែនាំចែកចេញជាពីរប្រភេទគឺគ្រូណែនាំគោល និងសហគ្រូណែនាំ ឬគ្រូណែនាំរង។

**២.៣.២**-គ្រូណែនាំគោលគឺជាគ្រូបង្រៀនរបស់ ***សភនវស*** ដែលមានសញ្ញាបត្របណ្ឌិត និងមានជំនាញសមស្របនឹងប្រធានបទស្រាវជ្រាវរបស់និស្សិត។ គ្រូណែនាំគោលដែលអាចដឹកនាំនិស្សិតថ្នាក់បណ្ឌិត សិក្សាជាភាសាបរទេសបាន លុះត្រាតែគ្រូបង្រៀននោះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ភាសាបរទេសនោះ។

**២.៣.៣**-សហគ្រូណែនាំ ឬគ្រូណែនាំរងជាគ្រូបង្រៀន ឬអ្នកជំនាញដែលមានសញ្ញាបត្របណ្ឌិតស្ថិតក្នុងជំនាញសមស្របនឹងប្រធានបទស្រាវជ្រាវរបស់និស្សិត និងអាចមកពីក្នុង ឬក្រៅ ***សភនវស***។ សហគ្រូណែនាំ ឬគ្រូណែនាំរងអាចណែនាំនិស្សិតថ្នាក់បណ្ឌិតសិក្សាជាភាសាបរទេសបាន លុះត្រាតែមានចំណេះដឹងភាសាបរទេសនោះគ្រប់គ្រាន់ក្នុងការប្រឹក្សាយោបល់ជាមួយនិស្សិត និងមានបទពិសោធន៍បង្រៀន និង/ឬស្រាវជ្រាវសមស្រប។

**២.៣.៤**-គ្រូណែនាំគោលម្នាក់ៗ អាចមាននិស្សិតក្នុងបន្ទុកណែនាំនៅថ្នាក់បណ្ឌិត មិនលើសពី៦នាក់។ ក្នុងករណីនិស្សិតក្នុងបន្ទុកណែនាំរបស់ខ្លួនបានបញ្ចប់ការសិក្សា គ្រូណែនាំអាចទទួលនិស្សិត ក្នុងបន្ទុកណែនាំបន្ថែមទៀត។

**២.៣.៥**-គ្រូណែនាំគោល និងសហគ្រូណែនាំឬគ្រូណែនាំរង មានភារកិច្ចជួយនិស្សិតឲ្យបញ្ចប់ការស្រាវជ្រាវរបស់ខ្លួនតាមកាលកំណត់ ដូចមានចែងក្នុងមាត្រា៦នៃអនុក្រឹត្យលេខ១៥១អនក្រ/បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

**២.៣.៦**-ក្នុងករណីគ្រូណែនាំលាឈប់ ឬករណីផ្សេងដែលនាំឲ្យរាក់ខានដល់ការណែនាំ នៅមុនពេលនិស្សិតបញ្ចប់ការសិក្សារបស់ខ្លួន គ្រូណែនាំត្រូវផ្តល់យោបល់ ឬព័ត៌មានអំពីគ្រូបង្រៀនណាមួយដែលមានជំនាញដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដើម្បីឲ្យនិស្សិតសម្រេចចិត្តទទួលគ្រូបង្រៀនថ្មីនោះជា គ្រូណែនាំបន្ត។ ក្នុងករណីគ្រូណែនាំទទួលមរណភាព មុនកាលកំណត់បញ្ចប់ការសិក្សារបស់និស្សិត សាកលវិទ្យាល័យមានភារកិច្ចជ្រើសរើសគ្រូណែនាំថ្មីមកជំនួស។ គ្រូណែនាំថ្មីនេះ អាចត្រូវបានស្នើឡើងដោយនិស្សិត។

**២.៣.៧**-ក្នុងករណីរកគ្រូណែនាំគោលថ្មីដែលមានជំនាញដូច ឬប្រហាក់ប្រហែលនឹងប្រធានបទស្រាវ-ជ្រាវរបស់និស្សិតមិនបាន សាកលវិទ្យាល័យអាចអនុញ្ញាតឲ្យសហគ្រូណែនាំ ឬគ្រូណែនាំរង ដែលបម្រើការនៅ ***សភនវស*** ធ្វើជាគ្រូណែនាំគោលបន្តបាន។ ក្នុងករណីសហគ្រូណែនាំ ឬគ្រូណែនាំរងមិនបម្រើការនៅ ***សភន-វស*** សាកលវិទ្យាល័យអាចអនុញ្ញាតឲ្យគ្រូបង្រៀនផ្ទៃក្នុងរបស់ខ្លួនណាដែល មានជំនាញប្រហាក់ប្រហែលមកធ្វើជាគ្រូណែនាំគោលបន្តបាន។ ក្នុងករណីរកគ្រូបង្រៀនផ្ទៃក្នុង មិនបាន សាកលវិទ្យាល័យអាចស្នើសុំអនុញ្ញាតសហគ្រូណែនាំ គ្រូណែនាំរង ឬគ្រូបង្រៀនពីខាងក្រៅ ដែលមានជំនាញដូច ឬប្រហាក់ប្រហែល មកធ្វើជាគ្រូណែនាំ គោលជំនួសបាន។

## ២.៤. គណៈកម្មការការពារគម្រោងស្រាវជ្រាវ

**២.៤.១**-គណៈកម្មការការពារគម្រោងស្រាវជ្រាវ មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណើគម្រោងស្រាវជ្រាវរបស់និស្សិតថ្នាក់បណ្ឌិត មុនពេលអនុញ្ញាតឲ្យចាប់ផ្តើមធ្វើការស្រាវជ្រាវ។

**២.៤.២**-សមាសភាពនៃគណៈកម្មការការពារគម្រោងស្រាវជ្រាវរួមមាន៖

- គ្រូណែនាំគោល (១រូប) ប្រធាន
- សហគ្រូណែនាំ ឬគ្រូណែនាំរង (១រូប) សមាជិក
- គ្រូបង្រៀនដែលមានសញ្ញាបត្របណ្ឌិត ឬអ្នកជំនាញដែលមានសញ្ញាបត្របណ្ឌិត (៣រូប)សមាជិក

**២.៤.៣**-គណៈកម្មការការពារគម្រោងស្រាវជ្រាវ ត្រូវបានតែងតាំងឡើងនៅក្រោយពេលនិស្សិតបានបញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាប្រឡង ដើម្បីវាយតម្លៃសំណើគម្រោងស្រាវជ្រាវរបស់និស្សិតនោះ។

**២.៤.៤**-នាយកសាលាក្រោយបរិញ្ញាបត្រ មានភារកិច្ចរៀបចំកាលបរិច្ឆេទនៃការការពារគម្រោងស្រាវជ្រាវ។

**២.៤.៥**-ការវាយតម្លៃសំណើគម្រោងស្រាវជ្រាវអាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាសភាពចាប់ពី៣រូប។

**២.៤.៦**-ការវាយតម្លៃ និងផ្តល់យោបល់លើសំណើគម្រោងស្រាវជ្រាវត្រូវផ្អែកទៅតាមគំរូមានស្រាប់ដែលត្រូវបានប្រគល់ជូន។ លទ្ធផលនៃការការពារគម្រោងស្រាវជ្រាវចាត់ទុកថាជោគជ័យ លុះត្រាតែទទួលបានពិន្ទុមធ្យមភាគចាប់ពី ៧០%ឡើងទៅ ពីគណៈកម្មការវាយតម្លៃគម្រោងស្រាវជ្រាវ។

## ២.៥. គណៈកម្មការការពារនិក្ខេបបទសាកល្បង

**២.៥.១**-គណៈកម្មការការពារនិក្ខេបបទសាកល្បងមានភារកិច្ចពិនិត្យវាយតម្លៃ និងផ្តល់យោបល់លើការ-ការពារនិក្ខេបបទសាកល្បងរបស់និស្សិត ថាតើនិស្សិតអាចមានលទ្ធភាពការពារបញ្ចប់ នៅពេលទទួលបានមតិរិះគន់កែលំអនានាពីគណៈកម្មការ និងពីមតិផ្សេងទៀតដែលបានចូលរួម។

**២.៥.២**-សមាសភាពនៃគណៈកម្មការការពារនិក្ខេបបទសាកល្បងរួមមានៈ

- សាកលវិទ្យាធិការ ឬសាកវិទ្យាធិការរងទទួលបន្ទុកសិក្សា ប្រធាន
- គ្រូវាយតម្លៃ ត្រូវជំនាញ ឬប្រហាក់ប្រហែល (៣រូប) សមាជិក
- គ្រូណែនាំ (២រូប) សមាជិក
- លេខាកត់ត្រា (មានសញ្ញាបត្របណ្ឌិត១រូប) សមាជិក

**២.៥.៣**-គណៈកម្មការនេះ ត្រូវបានតែងតាំងឡើងនៅក្រោយពេលគ្រូណែនាំគោល សម្រេចថានិក្ខេបបទរបស់និស្សិតត្រូវបានសរសេរបញ្ចប់រួចហើយ និងអាចត្រូវបានការពារសាកល្បងបាន ដោយមានការឯកភាពពីសហគ្រូណែនាំ ឬគ្រូណែនាំរងយ៉ាងតិចម្នាក់។

**២.៥.៤**-ប្រធានគណៈកម្មការការពារនិក្ខេបបទសាកល្បង មានសិទ្ធិចាត់តាំងសមាជិកណាម្នាក់ឲ្យដឹកនាំផទិកាវាយតម្លៃនិក្ខេបបទសាកល្បងក្នុងករណីចាំបាច់។

**២.៥.៥**-នាយកសាលាក្រោយបរិញ្ញាបត្រ មានភារកិច្ចសម្រេចពីកាលបរិច្ឆេទនៃ ការការពារនិក្ខេបបទសាកល្បង។

**២.៥.៦**-ការការពារនិក្ខេបបទសាកល្បងអាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាសភាពចាប់ពី៥រូប។

**២.៥.៧**-ការការពារនិក្ខេបបទសាកល្បងត្រូវធ្វើឡើងជាសាធារណៈ។ នាយកទទួលបន្ទុកសាលាក្រោយបរិញ្ញាបត្រត្រូវផ្សព្វផ្សាយព័ត៌មានពីការការពារនិក្ខេបបទសាកល្បង ឲ្យបានយ៉ាងហោចណាស់១សប្ដាហ៍ មុនកាលបរិច្ឆេទការពារសាកល្បងចាប់ផ្ដើម។

**២.៥.៨**-ការវាយតម្លៃ និងផ្ដល់យោបល់ទៅលើការការពារនិក្ខេបបទសាកល្បងត្រូវផ្អែកតាមគំរូមានស្រាប់ដែលត្រូវបានប្រគល់ជូន។ លទ្ធផលនៃការការពារនិក្ខេបបទសាកល្បង ចាត់ទុកថាបានទទួលជោគជ័យលុះត្រាតែទទួលបានសំឡេងគាំទ្រ ចាប់ពីបីភាគបួននៃសមាសភាពគណៈកម្មការការពារនិក្ខេបបទសាកល្បង។

## ២.៦. ក្រុមអ្នកពិនិត្យវាយតម្លៃនិក្ខេបបទ

**២.៦.១**-ក្រុមអ្នកពិនិត្យវាយតម្លៃនិក្ខេបបទ ជាក្រុមអ្នកជំនាញដែលមានសញ្ញាបត្របណ្ឌិត និងជំនាញពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវរបស់និស្សិត និងមានភារកិច្ចពិនិត្យវាយតម្លៃលើនិក្ខេបបទ មុនពេលនិក្ខេបបទត្រូវបានការពារបញ្ចប់។

**២.៦.២**-សមាសភាពនៃក្រុមអ្នកពិនិត្យវាយតម្លៃមាន៣រូប ក្នុងនោះ១រូបជាអ្នកពិនិត្យវាយតម្លៃរបស់ ***សភនវស*** និង២រូបទៀតជាអ្នកពិនិត្យវាយតម្លៃមកពីគ្រឹះស្ថានខាងក្រៅ ហើយមិនមែនជាគ្រូណែនាំនិស្សិតឡើយ។

**២.៦.៣**-ការជ្រើសរើសក្រុមអ្នកពិនិត្យវាយតម្លៃ ត្រូវធ្វើឡើងតាមការព្រមព្រៀងគ្នាជាមួយសាកលវិទ្យាល័យដោយអ្នកពិនិត្យវាយតម្លៃមិនត្រូវជាប់សាច់ញាតិ ឬមិត្តភក្ដិជិតស្និទ្ធ ឬមានទំនាក់ទំនងផលប្រយោជន៍ជាមួយបេក្ខជនបណ្ឌិតឡើយ។

**២.៦.៤**-បញ្ជីឈ្មោះនៃក្រុមអ្នកពិនិត្យវាយតម្លៃ ត្រូវរក្សាទុកជាការសម្ងាត់សម្រាប់ ***សភនវស*** និងក្រសួងអប់រំ យុវជន និងកីឡា។

**២.៦.៥**-អ្នកពិនិត្យវាយតម្លៃម្នាក់ៗ ត្រូវម្ចាស់ការលើការវាយតម្លៃនិក្ខេបបទរបស់បេក្ខជនបណ្ឌិត ដោយឯករាជ្យ និងសុក្រឹត ព្រមទាំងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ។

**២.៦.៦**-អ្នកពិនិត្យវាយតម្លៃ មានភារកិច្ចវាយតម្លៃនិក្ខេបបទដែលបានដាក់ជូនមិនឲ្យលើសពីរយៈពេល២ខែ ចាប់តាំងពីថ្ងៃបានទទួលនិក្ខេបបទ។

**២.៦.៧**-ក្រោយពីវាយតម្លៃរួច អ្នកពិនិត្យវាយតម្លៃត្រូវប្រគល់ជូននាយកទទួលបន្ទុកសាលាក្រោយបរិញ្ញាបត្រដើម្បីរៀបចំដំណើរការនៃការការពារនិក្ខេបបទបញ្ចប់។ ការប្រគល់ជូនលទ្ធផលនៃរង្វាយតម្លៃនិក្ខេបបទត្រូវភ្ជាប់មកជាមួយហត្ថលេខាយល់ព្រម ឬមិនយល់ព្រមឲ្យការពារបញ្ចប់។

**២.៦.៨**-បន្ទាប់ពីទទួលបានការឯកភាពឲ្យការពារនិក្ខេបបទបញ្ចប់ហើយ ក្រុមអ្នកពិនិត្យវាយតម្លៃមានភារកិច្ចចូលរួមជាគណៈមេប្រយោគក្នុងការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់។

**២.៦.៩**-ក្នុងករណីអ្នកពិនិត្យវាយតម្លៃណាម្នាក់ ខកខានវាយតម្លៃដោយមូលហេតុអ្វីមួយ សាកលវិទ្យាល័យមានសិទ្ធិជ្រើសរើសអ្នកវាយតម្លៃថ្មីមកជំនួស។

## ២.៧. គណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់

**២.៧.១**-គណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ ជាអ្នកទទួលខុសត្រូវលើការពិនិត្យរបាយការណ៍ទាំងអស់និងវាយតម្លៃលើលទ្ធផលនៃការប្រឡងបញ្ចប់របស់បេក្ខជនម្នាក់ៗ។ គណៈកម្មការនេះត្រូវបានតែងតាំងតាមតម្រូវការជាក់ស្តែងនៃជំនាញដែលត្រូវគ្នានឹងប្រធានបទនីមួយៗ។

**២.៧.២**-សមាសភាពនៃគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់រួមមាន៖

- ប្រធាន (១រូប)
- គ្រូណែនាំគោល (១រូប)
- អ្នកពិនិត្យវាយតម្លៃនិក្ខេបបទឯករាជ្យ (៣រូប)
- លេខាកត់ត្រាដែលមានសញ្ញាបត្របណ្ឌិត (១រូប)
- គ្រូបង្រៀនដែលមានសញ្ញាបត្របណ្ឌិត (១រូប) ដែលមានជំនាញដូច ឬប្រហាក់ប្រហែល និងមិនមែនជាសហគ្រូណែនាំ ឬគ្រូណែនាំរង ឬមិនមែនជាសាច់ញាតិ មិត្តភក្តិ ឬអ្នករួមការងារជិតដិតនឹងបេក្ខជន។

**២.៧.៣**-សមាសភាពគណៈកម្មការនេះ ត្រូវសម្រេចដោយក្រសួងអប់រំ យុវជន និងកីឡា តាមការស្នើសុំរបស់ ***សភនវស***។

**២.៧.៤**-សមាជិកនៃគណៈកម្មការនេះត្រូវវាយតម្លៃលទ្ធផលនៃការស្រាវជ្រាវ និងការការពាររបស់បេក្ខជនទៅតាមទម្រង់ដែលរៀបចំដោយសាកលវិទ្យាល័យ។

**២.៧.៥**-គ្រូណែនាំគោលជាសេនាធិការឲ្យប្រធានគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ ក្នុងការវាយតម្លៃបញ្ចប់។

**២.៧.៦**-គណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ មានតួនាទីសម្រេចលើលទ្ធផលនៃការការពារនិក្ខេបបទ។

**២.៧.៧**-ការការពារនិក្ខេបបទបញ្ចប់អាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាសភាពចាប់ពី៥រូប។

**២.៧.៨**-ការការពារនិក្ខេបបទបញ្ចប់ត្រូវធ្វើឡើងជាសាធារណៈ។ នាយកសាលាក្រោយបរិញ្ញាបត្រត្រូវផ្សព្វផ្សាយព័ត៌មានពី ការការពារនិក្ខេបបទបញ្ចប់ឲ្យបានយ៉ាងហោចណាស់២សប្តាហ៍ មុនកាលបរិច្ឆេទការពារបញ្ចប់ចាប់ផ្តើម។

**២.៧.៩**-លទ្ធផលនៃការការពារបញ្ចប់និក្ខេបបទចាត់ទុកថាជោគជ័យ លុះត្រាតែទទួលបានសំឡេងគាំទ្រចាប់ពីបីភាគបួននៃសមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់។

## ២.៨. គណៈមេប្រយោគ

**២.៨.១**-គណៈមេប្រយោគជាអ្នកទទួលខុសត្រូវលើការពិនិត្យរបាយការណ៍ទាំងអស់ និងវាយតម្លៃលើលទ្ធ-ផលនៃការប្រឡងបញ្ចប់របស់បេក្ខជនថ្នាក់បណ្ឌិត។

**២.៨.២**-គណៈកម្មការនេះត្រូវបានតែងតាំង នៅពេលប្រឡងជ្រើសរើសនិស្សិតចូលរៀន និងនៅពេលប្រឡងបញ្ចប់ទៅតាមតម្រូវការជាក់ស្តែងនៃសាកលវិទ្យាល័យ។

## ២.៩. គណៈកម្មការដោះស្រាយបណ្តឹងតវ៉ា

**២.៩.១**-គណៈកម្មការដោះស្រាយទំនាស់មានភារកិច្ចសំខាន់ៗក្នុងការសម្របសម្រួល និងដោះស្រាយបញ្ហាផ្សេងៗដែលកើតឡើង ក្នុងចំណោមគ្រូណែនាំ ក្រុមអ្នកពិនិត្យវាយតម្លៃ គណៈកម្មការនានា និងបេក្ខ-ជន។

**២.៩.២**-សមាសភាពនៃគណៈកម្មការដោះស្រាយទំនាស់រួមមាន៖

- គណៈគ្រប់គ្រង **សភនវស**
- ក្រុមប្រឹក្សាវិទ្យាសាស្ត្រ
- គ្រូណែនាំ

**២.៩.៣**-ក្នុងករណីមានបណ្តឹងតវ៉ាពាក់ព័ន្ធនឹងប្រយោជន៍របស់បេក្ខជន នាយកសាលាក្រោយបរិញ្ញាបត្រត្រូវធ្វើការសម្រុះសម្រួលដោយពិភាក្សាជាមួយក្រុមគ្រូណែនាំ ឬ/និងភាគីពាក់ព័ន្ធផ្សេងទៀត។ ក្នុងករណី មិនអាចសម្រុះសម្រួលបាន នាយកសាលាក្រោយបរិញ្ញាបត្រត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការដោះស្រាយទំនាស់។

**២.៩.៤**-ប្រធានគណៈកម្មការដោះស្រាយទំនាស់ មានភារកិច្ច សម្រេចកាលបរិច្ឆេទកោះប្រជុំដោះស្រាយបណ្តឹងតវ៉ា។

**២.៩.៥**-ការដោះស្រាយបណ្តឹងតវ៉ា ត្រូវផ្អែកលើគោលការណ៍សម្រុះសម្រួល ប្រកបដោយសមធម៌ និងយុត្តិធម៌។ ក្នុងករណីមិនអាចមិនសម្រុះសម្រួលបាន ការសម្រេចផ្អាក ឬបញ្ឈប់បេក្ខជនបណ្ឌិត ឬសមាជិកគណៈកម្មការពាក់ព័ន្ធណាម្នាក់ ត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាត ដែលមានវត្តមានក្នុងពេលបោះឆ្នោតសម្រេច។ ក្នុងករណីសំឡេងស្មើគ្នា មតិខាងសំឡេងដែលមានប្រធានគណៈកម្មការដោះស្រាយទំនាស់ត្រូវមានឧត្តមានុភាព។

**២.៩.៦**-ក្នុងករណី មិនអាចចេញសេចក្តីសម្រេចក្នុងរឿងបណ្តឹងតវ៉ាបាន ប្រធានគណៈកម្មការដោះ-ស្រាយបណ្តឹងតវ៉ាត្រូវបញ្ជូនសំណុំរឿង និងកំណត់ហេតុប្រជុំទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការដោះ-ស្រាយចុងក្រោយ។

**២.៩.៧**-ក្នុងករណី ភាគីណាមួយមិនសុខចិត្តនឹងការសម្រេចរបស់គណៈកម្មការដោះស្រាយទំនាស់ ភាគីនោះមានសិទ្ធិដាក់ពាក្យបណ្តឹងបន្តទៅក្រសួងអប់រំ យុវជន នឹងកីឡា ដើម្បីធ្វើការដោះស្រាយចុងក្រោយ។

**២.៩.៨**-ការដោះស្រាយបណ្តឹងតវ៉ា អាចធ្វើទៅបានតែក្នុងអំឡុងពេលអត្ថិភាពនៃការសិក្សារបស់បេក្ខជនបណ្ឌិតតែប៉ុណ្ណោះ។

## ៣. ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត



## ៤. ថ្នាក់បណ្ឌិតនឹងបើកនៅពេលឆាប់ៗ

សាកលវិទ្យាល័យបានរៀបចំគោលការណ៍បណ្តុះបណ្តាលថ្នាក់បណ្ឌិត និងគោលការណ៍បង្កើតគណៈកម្មការនានាសម្រាប់ថ្នាក់បណ្ឌិត រួចរាល់ហើយ។

ក្រុមប្រឹក្សាវិទ្យាសាស្ត្រពិភាក្សាចុងក្រោយ
អំពីគោលការណ៍បណ្តុះបណ្តាលថ្នាក់បណ្ឌិត, ខែធ្នូ ឆ្នាំ២០២២



## ក្រុមប្រឹក្សាភិបាលប្រជុំអនុម័តគោលការណ៍បណ្តុះបណ្តាលថ្នាក់បណ្ឌិត, ខែមករា ឆ្នាំ២០២៣



# ផ្នែកទី៤
# គ្រូណែនាំ គ្រូជំនួយសារពីនិស្សិត ប្រតិទិនសម្រាប់ជំនាន់និងជំហាននីមួយៗ និងសកម្មភាពក្រោកម្មវិធីសិក្សា

# ១. បញ្ជីរាយនាមគ្រូណែនាំ និងគ្រូជំនួយ សម្រាប់ការណែនាំសរសេរនិក្ខេបបទ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ

## ១.១. គ្រូណែនាំ

| លរ. | គោត្តនាម និងនាម | ភេទ | សញ្ញាបត្រ | | ជំនាញ | បង្រៀន | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| | | | កម្រិតបណ្ឌិត | ប្រទេស | | | |
| 1 | ឃឹម គីរី | ប | នីតិសាស្ត្រ | ចិន | នីតិអន្តរជាតិ | -នីតិកម្មសិទ្ធិបញ្ញា<br>-នីតិអន្តរជាតិ | 088 7722221 |
| 2 | ឈុន ណាផ័ត | ប | វិទ្យាសាស្ត្រ នយោបាយ | រុស្ស៊ី | វិទ្យាសាស្ត្រនយោបាយ | -នយោបាយសាធារណៈ<br>-ទ្រឹស្តីរដ្ឋ<br>-រដ្ឋធម្មនុញ្ញប្រៀបធៀប | 012 995935 |
| 3 | ឌី ពុទ្ធារ៉ា | ប | វិទ្យាសាស្ត្រ នយោបាយ | កម្ពុជា | -ទ្រឹស្តីរដ្ឋ<br>-អាស៊ានការូបនីយកម្ម | ទ្រឹស្តីរដ្ឋ | 012 215161 |
| 4 | ព្រុំ រិទ្ធី | ប | នីតិសាស្ត្រ | បារាំង | នីតិឯកជន | -នីតិវិនិយោគ<br>-នីតិកាតព្វកិច្ច | 012 248840 |
| 5 | ទេព សុខ | ប | រដ្ឋបាលសាធារណៈ | កម្ពុជា | រដ្ឋបាលសាធារណៈ | -ហិរញ្ញវត្ថុសាធារណៈ<br>-នីតិវិនិយោគ | 017 450006 |
| 6 | សឿន សោភ័ណ | ប | រដ្ឋបាលសាធារណៈ | ឥណ្ឌូនេស៊ី | រដ្ឋបាលសាធារណៈ | -ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ<br>-គោលការណ៍ដឹកនាំក្នុងវិស័យសាធារណៈ | 016 776699 |
| 7 | ស្រៀង ស៊ីម | ស | នីតិសាស្ត្រ | ជប៉ុន | នីតិការងារ | -វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា | 069 83588 |
| 8 | ហាប់ ផល្លី | ប | នីតិសាស្ត្រ | ជប៉ុន | នីតិទ្រព្យសម្បត្តិ | -នីតិទ្រព្យសម្បត្តិ<br>-វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា | 016 846622 |
| 9 | ឡុង សារ៉ាពេជ្រ | ប | នីតិសាស្ត្រ | បារាំង | នីតិអន្តរជាតិសាធារណៈ | នីតិព្រហ្មទណ្ឌអន្តរជាតិ | 017 628185 |
| 10 | អ៊ឹង រដ្ឋា | ប | រដ្ឋបាលសាធារណៈ | បារាំង | រដ្ឋបាលសាធារណៈ | -នីតិព្រហ្មទណ្ឌអន្តរជាតិ<br>-នីតិសមុទ្រ | 012 864803<br>016 606168 |
| 11 | អ៊ុន សកក្កដា | ប | រដ្ឋបាលសាធារណៈ | កម្ពុជា | នគរូបនីយកម្ម | -នគរូបនីយកម្ម<br>-អាស៊ានការូបនីយកម្ម<br>-នីតិទ្រព្យសម្បត្តិសាធារណៈ | 011 888823 |
| 12 | គក បូផន | ស | នីតិសាស្ត្រ | ជប៉ុន | កម្មសិទ្ធិបញ្ញា | នីតិកម្មសិទ្ធិបញ្ញា | 012 899373 |
| 13 | ជា សៀវម៉ី | ស | នីតិសាស្ត្រ | ជប៉ុន | នីតិការងារ | -វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា | 061 202272 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 14 | ជិនកេត មេត្តា | ប | រដ្ឋបាលសាធារណៈ | ជប៉ុន | ការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការ | វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា | 085 273330 |
| 15 | ណុប កញ្ញារិទ្ធិ | ប | នីតិសាស្ត្រ | ជប៉ុន | នីតិការងារ | -នីតិការងារប្រៀបធៀប<br>-បច្ចេកទេសអនុវត្តក្នុងកិច្ចសន្យាពិសេស | 017 616188 |
| 16 | ធិន វុត្ថា | ប | នីតិសាស្ត្រ | ចិន | នីតិវិនិយោគ និង ពាណិជ្ជកម្ម | នីតិវិនិយោគ | 087 966 661 |
| 17 | បូ ច័ន្ទគូលិកា | ស | អប់រំ | អូស្ត្រាលី | គោលនយោបាយអប់រំ | វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា | 095 666916 |
| 18 | បេងហុង សុជាតិខេមរ៉ូ | ប | នីតិសាស្ត្រ | អង់គ្លេស | សេដ្ឋកិច្ច-នគរូបនីយកម្ម-សំណង់ | នគរូបនីយកម្ម | 012 485999 |
| 19 | ភិន សុវត្ថិ | ប | នីតិសាស្ត្រ | ជប៉ុន | កម្មសិទ្ធិបញ្ញា | នីតិកម្មសិទ្ធិបញ្ញា | 012 925417 |
| 20 | មាស បូរ៉ា | ប | នីតិសាស្ត្រ | ជប៉ុន | នីតិសិទ្ធិមនុស្ស | នីតិសិទ្ធិមនុស្ស | 016 638438 |
| 21 | លី សុភាព | ស | នីតិសាស្ត្រ | ជប៉ុន | រដ្ឋបាលសាធារណៈ | សេវាសាធារណៈ | 012 537759 |
| 22 | លឹម លីហុង | ប | នីតិសាស្ត្រ | ជប៉ុន | នីតិរដ្ឋធម្មនុញ្ញ | នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប | 015 388577 |
| 23 | ស សុជា | ប | សិក្សាអន្តរជាតិ | ជប៉ុន | សិក្សាអន្តរជាតិ | -នីតិទ្រព្យសម្បត្តិឯកជន<br>-វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា | 012 266882 |
| 24 | ស៊ន សុឃន | ប | នីតិសាស្ត្រ | កម្ពុជា | នីតិសាស្ត្រ | -នីតិមុខងារសាធារណៈអាស៊ាន<br>-ធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ | 012 898456 |
| 25 | សយ រាសី | ប | រដ្ឋបាលសាធារណៈ | ឥណ្ឌូនេស៊ី | រដ្ឋបាលសាធារណៈ | -កំណែទម្រង់រដ្ឋបាលសាធារណៈ<br>-អភិបាលកិច្ចល្អ | 016 669688 |
| 26 | ស៊ិន រិទ្ធ | ប | នីតិសាស្ត្រ | រុស្ស៊ី | នីតិសាស្ត្រ | -ឧក្រិដ្ឋវិទ្យា<br>-កិច្ចសន្យាពិសេស | 012 915749<br>017 321567 |
| 27 | ស៊ា ម៉ៅ | ប | នីតិសាស្ត្រ | កម្ពុជា | នីតិសាស្ត្រ | -វិធីសាស្ត្រ និងគោលការណ៍បកស្រាយគតិយុត្ត<br>-នីតិសាជីវកម្មប្រៀបធៀប | 017 228847 |
| 28 | ហែម ស្រស់ | ប | នីតិសាស្ត្រ | ជប៉ុន | អស្សាមិករណ៍ | វិធីសាស្ត្រស្រាវជ្រាវ និងការសរសេរបែបសិក្សា | 015 996099 |
| 29 | អ៊ាន ឆវីដា | ស | នីតិសាស្ត្រ | ជប៉ុន | រដ្ឋប្បវេណី | បច្ចេកទេសអនុវត្តក្នុងកិច្ចសន្យាពិសេស | 098901344 |


1


2


3

4


5


6


7


8


9


10


11

12


13


14


15


16


17


18

19

20

21


22


23


24


25



26



27



28



29

## ១.២. គ្រូជំនួយ

| ល.រ | គោត្តនាម និងនាម | ភេទ | សញ្ញាបត្រ | | ជំនាញ | បង្រៀន | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| | | | កម្រិត | ប្រទេស | | | |
| 30 | ឃឹម ម៉ាណែត | ស | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប | 092979659 |
| 31 | ជិន វណ្ណារ៉ា | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -នីតិរដ្ឋប្បវេណី<br>-នីតិកាតព្វកិច្ច | 012 316347 |
| 32 | ឈាន បូណា | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -សេចក្តីផ្តើមនីតិ<br>-នីតិរដ្ឋបាល | 016 538389 |
| 33 | ញឹក វុធ្ធី | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -នីតិរដ្ឋប្បវេណី<br>-នីតិកាតព្វកិច្ច | 016 654678 |
| 34 | ដុំ អ៊ុម | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -ទំនាក់ទំនងអន្តរជាតិ<br>-នីតិរដ្ឋធម្មនុញ្ញ | 077 668678<br>088 8677688 |
| 35 | ឌឿក ពិដោរ | ប | DEA | បារាំង | នីតិសាស្ត្រ | -ប្រព័ន្ធគ្រប់គ្រងអាស៊ីអាគ្នេយ៍<br>-គ្រប់គ្រងរដ្ឋបាលដែនដី<br>-នីតិសេវាសាធារណៈ | 012 556363 |
| 36 | តា សុទ្ធា | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | ប្រវត្តិទំ. អន្តរជាតិ | 092 962096 |
| 37 | ថោង ចន្ត្រា | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | នីតិរដ្ឋធម្មនុញ្ញ | 017 688878 |
| 38 | ធន ថាត | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | នីតិរដ្ឋធម្មនុញ្ញ | 012 278925 |
| 39 | ប៉ូលី បញ្ញា | ស | បរិ.ជាន់ខ្ពស់ | កាណាដា | នីតិសាស្ត្រ | -នគរូបនីយកម្ម<br>-នីតិវិនិយោគ | 017 776598 |
| 40 | ប៊ួយ ធីតា | ស | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | នីតិការងារប្រៀបធៀប | 012 499977 |
| 41 | ម៉ៅ បុណ្ណា | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -នីតិការងារប្រៀបធៀប<br>-ស្ថាប័នអន្តរជាតិ<br>-ឧក្រិដ្ឋវិទ្យា | 012 697295 |
| 42 | រុន ពណ្ណារិទ្ធ | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -ឧក្រិដ្ឋវិទ្យា<br>-នីតិគ្រួសារ | 012 499999 |
| 43 | សំណាង ផលដេត | ស | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | សេចក្តីផ្តើមនីតិ | 012965945 |
| 44 | ហៀង សាង | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -ការគ្រប់គ្រងរដ្ឋបាលដែនដី<br>-វិវាទរដ្ឋបាល | 088 8337337<br>077 337337 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 45 | ឡាញ់ ដា | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | ហិរញ្ញវត្ថុសាធារណៈ | 016 877727 |
| 46 | អម សុផាណារ៉ាត | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | នីតិរដ្ឋប្បវេណី | 012 414574 |
| 47 | កើយ វិញគឿម | ប | បរិ.ជាន់ខ្ពស់ | បារាំង | នីតិសាស្ត្រ | នីតិសាជីវកម្មប្រៀបធៀប | 092 933996 |
| 48 | គង់ ស្រ៊ីម | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | នីតិវិធីរដ្ឋប្បវេណី | 012 990933 |
| 49 | ង៉ែត វិបុល | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -នីតិកម្មសិទ្ធិបញ្ញា<br>-ពាណិជ្ជកម្មអន្តរជាតិ | 012 812444 |
| 50 | ចាយ ចន្ទតារាវណ្ណ | ប | បរិ.ជាន់ខ្ពស់ | សឹង្ហបូរី | នីតិសាស្ត្រ | -នីតិសាជីវកម្មប្រៀបធៀប<br>-ប្រាតិភោគ | 016 586665 |
| 51 | ចាំង ស៊ីណាត | ស | DEA | បារាំង | នីតិសាស្ត្រ | -នីតិសន្តិកម្ម<br>-ប្រាតិភោគ | 016 716016 |
| 52 | ជ័យ រិទ្ធី | ប | DEA | បារាំង | នីតិសាស្ត្រ | -ប្រាតិភោគ<br>-នីតិសន្តិកម្ម<br>-នីតិសាជីវកម្មប្រៀបធៀប | 012418670 |
| 53 | ប្អូន សារៈមុនី | ប | DEA | បារាំង | នីតិសាស្ត្រ | នីតិវិនិយោគ | 068 988988 |
| 54 | ពៅ សារឿន | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -វិធីសាស្ត្រ និងគោលការណ៍បកស្រាយគតិយុត្ត<br>-ច្បាប់សភាកម្ពុជា | 012 311131 |
| 55 | ម៉ុក ដារ៉ា | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប | 012 636007 |
| 56 | លី គង់សុច័ន្ទ | ប | បរិ.ជាន់ខ្ពស់ | អូស្ត្រាលី | ទំនាក់ទំនងអន្តរជាតិ | -នីតិសមុទ្រ<br>-អាស៊ានភាវូបនីយកម្ម<br>-ទ្រឹស្តីរដ្ឋ | 012 249924 |
| 57 | សន សោភ័ណ | ប | Maitrise | បារាំង | នីតិសាស្ត្រ | -នីតិសាជីវកម្មប្រៀបធៀប<br>-នីតិកម្មសិទ្ធិបញ្ញា | 012 797372 |
| 58 | សុខ វិសាល | ស | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -នីតិសាជីវកម្មប្រៀបធៀប | 012 311746 |
| 59 | ហ៊ី សោភា | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | នីតិសាស្ត្រ | -នីតិវិធីរដ្ឋប្បវេណី<br>-នីតិព្រហ្មទណ្ឌ | 012 832591 |



30

31



32



33



34



35

36

37

38

39



40



41



42

43



44

45

46



47



48



49



50



51



52



53



54



55



56



57



58



59

## កំណត់សម្គាល់

និស្សិតអាចស្នើសុំគ្រូបង្រៀនណាម្នាក់ខាងលើដែលមានមុខជំនាញពាក់ព័ន្ធ ធ្វើជាគ្រូណែនាំរបាយការណ៍ ស្រាវជ្រាវ ដោយមិនគិតពីកម្រិតសញ្ញាបត្រ។

និស្សិតអាចស្នើសុំគ្រូណែនាំដែលមានមុខជំនាញពាក់ព័ន្ធ ធ្វើជាគ្រូណែនាំនិក្ខេបបទ។ គ្រូណែនាំនិក្ខេបបទត្រូវជាគ្រូបង្រៀនមានសញ្ញាបត្របណ្ឌិត ចំណែកគ្រូជំនួយនិក្ខេបបទ អាចមានសញ្ញាបត្របណ្ឌិត ឬបរិញ្ញាបត្រជាន់ខ្ពស់។



# ២. បញ្ជីរាយនាមគ្រូណែនាំ និងគ្រូជំនួយ សម្រាប់ការណែនាំសរសេរ និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច

## ២.១. គ្រូណែនាំ

| លរ. | គោត្តនាម និងនាម | ភេទ | សញ្ញាបត្រ | | ជំនាញ | បង្រៀន | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| | | | កម្រិតបណ្ឌិត | ប្រទេស | | | |
| 1 | គីម ចំរើនវុឌ្ឍី | ប | គណិតវិទ្យា | បារាំង | ស្ថិតិ | ស្ថិតិពាណិជ្ជកម្ម | 017 245600 |
| 2 | ង៉ាន់ ស៊ុនដេត | ប | គ្រប់.សហគ្រាស | កម្ពុជា | គ្រប់គ្រងសហគ្រាស | វិធីសាស្ត្រស្រាវជ្រាវ និង ការសរសេរបែបសិក្សា | 092 999543 |
| 3 | ជា គឹមឡេង | ប | សេដ្ឋកិច្ច | កម្ពុជា | សេដ្ឋកិច្ច | ស្ថិតិធុរកិច្ច | 012 353834 |
| 4 | ជ្រឹង ហៃ | ប | គ្រប់.អាជីវកម្ម | កម្ពុជា | គ្រប់គ្រងពាណិជ្ជកម្ម | -ហិរញ្ញវត្ថុសាជីវកម្ម -វិភាគវិនិយោគ | 012 525558 |
| 5 | ឈុន ពហុ | ប | សេដ្ឋកិច្ច | រុស្ស៊ី | គ្រប់.សេវា.ទេសចរណ៍ | ហិរញ្ញវត្ថុសាធារណៈ | 012 591237 |
| 6 | ទិន ហេង | ប | គ្រប់គ្រងពាណិជ្ជកម្ម | កម្ពុជា | គ្រប់គ្រង | -គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា -វិធីសាស្ត្រស្រាវជ្រាវ និង ការសរសេរបែបសិក្សា | 092 317327 |
| 7 | ស្រ៊ុន សុភ័ក្ត្រ | ប | សេដ្ឋកិច្ច | បារាំង | ពាណិជ្ជកម្មអន្តរជាតិ | -វិធីសាស្ត្រស្រាវជ្រាវ និង ការសរសេរបែបសិក្សា -គ្រប់គ្រងផលិតកម្ម និង ប្រតិបត្តិការ | 078 767378 |
| 8 | ឡាយ សុខគីម | ប | សេដ្ឋកិច្ច | កម្ពុជា | សេដ្ឋកិច្ច | ក្រមសីលធម៌ពាណិជ្ជកម្ម ផែនការយុទ្ធសាស្ត្រ អាជីវកម្ម | 012 704 789 |
| 9 | ច័ន្ទ រ័ត្ន | ប | គណិតវិទ្យា | រុស្ស៊ី | គណិតវិទ្យា | វិភាគបរិមាណ | 011 697038 |
| 10 | ឆន ឌីណា | ប | សេដ្ឋកិច្ច | បារាំង | សេដ្ឋកិច្ចអភិវឌ្ឍន៍ និង យុទ្ធសាស្ត្រ | ផែនការយុទ្ធសាស្ត្រ អាជីវកម្ម | 086 405836 |
| 11 | ឈុន វណ្ណៈ | ប | សេដ្ឋកិច្ច | បារាំង | ម៉ាក្រូសេដ្ឋកិច្ច | Portfolio Analysis and Management | 089 880661 |
| 12 | ដោរ ណារ៉ា | ប | សេដ្ឋកិច្ច | រុស្ស៊ី | សេដ្ឋកិច្ច | ធានារ៉ាប់រង និងគ្រប់គ្រងហានិភ័យ | 095 888336 |
| 13 | ប្រាំង ឧត្តម | ប | គណនេយ្យ | នូវែលហ្សេឡង់ | គណនេយ្យគ្រប់គ្រង | ស្ថិតិធុរកិច្ច | 092 663558 |
| 14 | ព្រុំ ទេវី | ស | សេដ្ឋកិច្ច | អាល្លឺម៉ង់ | សេដ្ឋកិច្ច | -គ្រប់គ្រង និងវិភាគគម្រោង -វិធីសាស្ត្រស្រាវជ្រាវ និង ការសរសេរបែបសិក្សា | 012 839057 |
| 15 | លឹម ស៊ីផាត | ប | សេដ្ឋកិច្ច | ថៃ | សេដ្ឋកិច្ច | វិភាគវិនិយោគ | 016 853852 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 16 | សុក ច័ន្ទរិទ្ធី | ប | រដ្ឋបាលធុរកិច្ច | កម្ពុជា | រដ្ឋបាលធុរកិច្ច | -ក្រមសីលធម៌ធុរកិច្ច<br>-គ្រប់គ្រងបម្រែបម្រួល | 017 388989 |
| 17 | អៅ វេង | ប | គ្រប់.អាជីវកម្ម | កម្ពុជា | គ្រប់គ្រងអាជីវកម្ម | វិនិយោគ និងហិរញ្ញវត្ថុនៃអចលនទ្រព្យ | 012 911012 |
| 18 | ឡាយ គង់ | ប | បរិ.ជាន់ខ្ពស់ | អូស្ត្រាលី | គ្រប់គ្រងអាជីវកម្ម | -គ្រប់គ្រងអន្តរជាតិ<br>-គ្រប់គ្រងធនធានមនុស្ស | 012838963 |
| 19 | ប៉ុក ភារៈ | ប | បរិ.ជាន់ខ្ពស់ | តៃវ៉ាន់ | គ្រប់គ្រងអាជីវកម្ម | -មីក្រូសេដ្ឋកិច្ច | 012 331551 |
| 20 | ព្រុំ សុគុណ | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | គ្រប់គ្រងអាជីវកម្ម | -ស្ថិតិអាជីវកម្ម<br>-ហិរញ្ញវត្ថុសាជីវកម្ម | 012 525425 |


1


2


3


4


5


6


7


8


9


10


11


12


13


14


15


16


17


18

19


20

## ២.២. គ្រូជំនួយ

| ល.រ | គោត្តនាម និងនាម | ភេទ | សញ្ញាបត្រ | | ជំនាញ | បង្រៀន | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| | | | កម្រិត | ប្រទេស | | | |
| 18 | ឃឹម ជ័យ | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | គ្រប់គ្រងអាជីវកម្ម | គោលការណ៍គ្រប់គ្រង | 016 423159 |
| 19 | ងួន ហេង | ប | បរិ.ជាន់ខ្ពស់ | រុស្ស៊ី | សេដ្ឋកិច្ច<br>ឯកទេសគ្រប់គ្រង<br>ហិរញ្ញវត្ថុ និងធនាគារ | គណនេយ្យហិរញ្ញវត្ថុ | 011 906669 |
| 20 | ជា ម៉េងសែ | ប | បរិ.ជាន់ខ្ពស់ | កូរ៉េខាងត្បូង | គ្រប់គ្រងអាជីវកម្ម | -គណនេយ្យហិរញ្ញវត្ថុកម្រិតមធ្យម<br>-ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ | 012 773955 |
| 21 | ជុន ចាន់ណែត | ប | បរិ.ជាន់ខ្ពស់ | វៀតណាម | គ្រប់គ្រងអាជីវកម្ម | ម៉ាក្រូសេដ្ឋកិច្ច | 011 769436 |
| 22 | ឈាង ម៉េងហៀក | ប | DESS | បារាំង | គ្រប់គ្រងអាជីវកម្ម | -ធានារ៉ាប់រងនិងគ្រប់គ្រងហានិភ័យ<br>-គ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុ | 017 889944 |
| 23 | ឈាង ហ៊ុយ | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | គ្រប់គ្រងអាជីវកម្ម | -គ្រប់គ្រងហិរញ្ញវត្ថុអន្តរជាតិ<br>-វិភាគវិនិយោគ | 017 703707 |
| 24 | ទូន ផល្លា | ប | បរិ.ជាន់ខ្ពស់ | រុស្ស៊ី | គ្រប់គ្រងអាជីវកម្ម | -មីក្រូសេដ្ឋកិច្ចកម្រិតមធ្យម<br>-គ្រប់គ្រងធនធានមនុស្ស | 012 774577 |
| 25 | ធីម សុជាតិ | ប | បរិ.ជាន់ខ្ពស់ | វៀតណាម | គ្រប់គ្រងអាជីវកម្ម | គណនេយ្យហិរញ្ញវត្ថុ | 012638118 |
| 26 | ម៉ម ចរិយាវុធ | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | គ្រប់គ្រងអាជីវកម្ម | ស្ថិតិអាជីវកម្ម | 011 891360 |
| 27 | ស សុភាព | ប | បរិ.ជាន់ខ្ពស់ | ជប៉ុន | សេដ្ឋកិច្ចអភិវឌ្ឍន៍ | -អភិបាលកិច្ចសាជីវកម្ម<br>-ហិរញ្ញវត្ថុសាជីវកម្មកម្រិតខ្ពស់<br>-គ្រប់គ្រងនវានុវត្តន៍ | 012 957960 |
| 28 | សាន មន្ថិយ៉ា | ប | DESS | បារាំង | សេដ្ឋកិច្ច | -សេដ្ឋកិច្ចគ្រប់គ្រង<br>-ម៉ាក្រូសេដ្ឋកិច្ចកម្រិតមធ្យម | 088 9936970 |
| 29 | សូវ វេងនី | ប | បរិ.ជាន់ខ្ពស់ | ថៃ | គ្រប់គ្រងអាជីវកម្ម | ក្រមសីលធម៌ធុរកិច្ច | 012 837886 |
| 30 | សួន ចំរើន | ប | បរិ.ជាន់ខ្ពស់ | វៀតណាម | សេដ្ឋកិច្ច | -ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ | 012 500097 |
| 31 | ឡាយ ប៉េងហុង | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | គ្រប់គ្រងអាជីវកម្ម | គណនេយ្យគ្រប់គ្រង | 012 251919 |
| 32 | ឡុង ម៉ាមីឌី | ស | បរិ.ជាន់ខ្ពស់ | តៃវ៉ាន់ | គ្រប់គ្រងអាជីវកម្ម | -ពាណិជ្ជកម្មអន្តរជាតិ<br>-ម៉ាក្រូសេដ្ឋកិច្ច<br>-ហិរញ្ញវត្ថុអន្តរជាតិ | 077 562121 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 33 | អ៊ុន ម៉ារឌី | ប | បរិ. ជាន់ខ្ពស់ | បារាំង | វិទ្យាសាស្ត្រសេដ្ឋកិច្ច | ទ្រឹស្តីគ្រប់គ្រង និងការអនុវត្ត | 085 344446 |
| 34 | អឿន មុនីរដ្ឋ | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | គ្រប់គ្រងអាជីវកម្ម | -ទ្រឹស្តីគ្រប់គ្រង និងការអនុវត្ត<br>-គណនេយ្យហិរញ្ញវត្ថុកម្រិតមធ្យម | 097 7009398 |
| 35 | កុយ ជំនិត | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | គ្រប់គ្រងអាជីវកម្ម | គណនេយ្យហិរញ្ញវត្ថុ | 012 766667 |
| 36 | កែប សំភី | ប | បរិ.ជាន់ខ្ពស់ | ថៃ | គ្រប់គ្រងអាជីវកម្ម | ហិរញ្ញវត្ថុនៃអចលនវត្ថុ | 012 886909 |
| 37 | ជី គឹមអ៊ី | ប | បរិ.ជាន់ខ្ពស់ | កម្ពុជា | បច្ចេកវិទ្យាព័ត៌មានវិទ្យា | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រង | 012 321322 |
| 38 | ឈុន សម្បត្តិ | ប | បរិ.ជាន់ខ្ពស់ | បារាំង | គ្រប់គ្រងអាជីវកម្ម | -ផែនការយុទ្ធសាស្ត្រអាជីវកម្ម<br>-សាជីវកម្ម និងគ្រប់គ្រងអន្តរជាតិ | 092 316205 |
| 39 | ណង សេរីរ៉ុធ | ប | បរិ.ជាន់ខ្ពស់ | អូស្ត្រាលី | គ្រប់គ្រងហិរញ្ញវត្ថុ | ទីផ្សារឧបករណ៍និស្សន្ទ និងសញ្ញាប័ណ្ណ | 010 590073 |
| 40 | រិន រដ្ឋា | ប | បរិ.ជាន់ខ្ពស់ | កូរ៉េខាងត្បូង | ហិរញ្ញវត្ថុ | ទីផ្សារឧបករណ៍និស្សន្ទ និងសញ្ញាប័ណ្ណ | 070 400945 |

18



19



20



21



22



23



24



25



26



27



28



29



30



31



32



33



34



35



36



37



38



39



40

## កំណត់សម្គាល់

និស្សិតអាចស្នើសុំគ្រូបង្រៀនណាម្នាក់ខាងលើដែលមានមុខជំនាញពាក់ព័ន្ធ ធ្វើជាគ្រូណែនាំរបាយការណ៍ស្រាវជ្រាវ ដោយមិនគិតពីកម្រិតសញ្ញាបត្រ។

និស្សិតអាចស្នើសុំគ្រូណែនាំដែលមានមុខជំនាញពាក់ព័ន្ធ ធ្វើជាគ្រូណែនាំនិក្ខេបបទ។ គ្រូណែនាំនិក្ខេបបទត្រូវជាគ្រូបង្រៀនដែលមានសញ្ញាបត្របណ្ឌិត ចំណែកគ្រូជំនួយនិក្ខេបបទ អាចមានសញ្ញាបត្របណ្ឌិត ឬបរិញ្ញាបត្រជាន់ខ្ពស់។



ការប្រជុំគ្រូបង្រៀនសាលាក្រោយបរិញ្ញាបត្រ, ០៩ កញ្ញា ២០២៣

# ៣. សារពីនិស្សិត

## និស្សិត ទូច គន្ធា

**ទូច គន្ធា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសរដ្ឋបាលសាធារណៈ ឆ្នាំទី១**

Email: touchkunthea7@gamil.com



ដើម្បីឆ្លើយតបនឹងការវិវត្តរីកចម្រើនឥតឈប់ឈររបស់សកលលោក ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងនៅក្នុងការធ្វើកំណែទម្រង់លើគ្រប់វិស័យ ឈានឆ្ពោះទៅកសាងប្រទេសមួយដែលមានសេដ្ឋកិច្ចរឹងមាំ និងព្យាយាមសម្របខ្លួនទៅនឹងបច្ចេកវិទ្យាឌីជីថល ខណៈពិភពលោកកំពុងស្ថិតក្នុងដំណាក់កាលបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ វិស័យអប់រំគឺជាវិស័យអាទិភាពមួយ ដែលរាជរដ្ឋាភិបាលបន្តយកចិត្តទុកដាក់ក្នុងការធ្វើកំណែទម្រង់ក្នុងគោលដៅកសាងមូលធនមនុស្ស ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទីមួយ។ ចំណុចសំខាន់មួយក្នុងដំណើរការកំណែទម្រង់ គឺការលើកកម្ពស់ស្តង់ដាគុណភាពអប់រំនៅតាមគ្រឹះស្ថានមធ្យមសិក្សា និងឧត្តមសិក្សា ទាំងរដ្ឋ និងឯកជនផងដែរ ។ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺជាគ្រឹះស្ថានឧត្តមសិក្សាមួយដែលចំណាស់ជាងគេក្នុងតួនាទីផ្តល់ការបណ្តុះបណ្តាលផ្នែកច្បាប់ រដ្ឋបាលសាធារណៈ និងសេដ្ឋកិច្ចប្រកបដោយគុណភាព និងជាទីទុកចិត្តរបស់យុវជន និស្សិត និងពលរដ្ឋទូទៅ ។ ធនធានមនុស្សដែលចេញពីការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យនេះ បានទទួលជោគជ័យភាគច្រើនរួចមកហើយក្នុងការទទួលបានការងារ មានប្រាក់ចំណូលសមរម្យទាំងក្នុងវិស័យរដ្ឋ និងឯកជន ហើយខ្លះទៀតក៏បានក្លាយជាថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាល និងសភានៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ បច្ចុប្បន្ននេះសាកលវិទ្យាល័យក៏បានបន្តកែទម្រង់កម្មវិធីសិក្សា និងលក្ខខណ្ឌនៃការសិក្សាផ្សេងៗទៀត ដើម្បីលើកកម្ពស់គុណភាពអប់រំ ឲ្យស្របតាមការវិវត្តរីកចម្រើននៃវិស័យអប់រំទាំងក្នុងប្រទេស និងសកលលោក ។

ដោយភាពជឿទុកចិត្តចំពោះគុណភាពអប់រំរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបែបនេះហើយ ទើបនាងខ្ញុំសម្រេចជ្រើសរើសទទួលយកការបណ្តុះបណ្តាលពីសាកលវិទ្យាល័យនេះទាំងក្នុងកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។ ចាប់តាំងពីថ្នាក់បរិញ្ញាបត្រ ដល់បរិញ្ញាបត្រជាន់ខ្ពស់ នាងខ្ញុំទទួលបានបទពិសោធន៍ផ្សេងៗគ្នាទៅតាមកម្រិតនៃការសិក្សា។ នៅថ្នាក់បរិញ្ញាបត្រ នាងខ្ញុំអាចនិយាយបានថាជាពេលវេលានៃការចាប់ផ្តើមវិវត្តខ្លួនមួយដំណាក់កាលទៀតក្នុងការសិក្សា និងសង្គម ប៉ុន្តែអំឡុងពេលសិក្សានៅសាកលវិទ្យាល័យនេះ នាងខ្ញុំមានអារម្មណ៍កក់ក្តៅ និងអាចចាប់បានរាល់ការបង្រៀនគ្រប់មុខវិជ្ជា ទោះបីជាមានពេលខ្លះពិបាកចំពោះបទពិសោធន៍ថ្មីក្នុងការស្រាវជ្រាវក៏ដោយ ដោយសារតែលោកគ្រូអ្នកគ្រូម្នាក់ៗសុទ្ធសឹងតែមានបទពិសោធន៍ មានគុណធម៌ និងសីលធម៌ល្អ តែងតែលើកទឹកចិត្ត និងផ្តល់ការបង្រៀនអស់ពីកម្លាំងកាយ និងចិត្តផងដែរ។ ដោយឡែក នៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ នាងខ្ញុំបានស្គាល់ និងសម្របខ្លួនជាមួយបទពិសោធន៍ថ្មីមួយទៀត ដែលលោកគ្រូអ្នកគ្រូបានផ្តល់ឲ្យ។ ពិសេសនោះគឺការទទួលខុសត្រូវកាន់តែ

ខ្ពស់ក្នុងការសិក្សា និងការស្រាវជ្រាវ ដោយសារតែលោកគ្រូអ្នកគ្រូម្នាក់ៗផ្ដល់កិច្ចការឲ្យនិស្សិតធ្វើជាប្រចាំ ដើម្បីពង្រីកនូវចំណេះដឹងបន្ថែម។ បើទោះជាពេលខ្លះ ការឆ្លើយតបជាមួយកិច្ចការដែលលោកគ្រូអ្នកគ្រូបានផ្ដល់ឲ្យ មិនបានល្អទាំងស្រុង ឬមិនទាន់ពេលវេលា ដោយសារតែនិស្សិតម្នាក់ៗក៏មមាញឹកនឹងការងាររៀងៗខ្លួនផង ប៉ុន្តែនាងខ្ញុំ និងមិត្តរួមថ្នាក់ នៅតែទទួលបានការសណ្ដោសប្រណី និងណែនាំបន្ថែមពីលោកគ្រូអ្នកគ្រូ ដើម្បីកែលម្អនៅរាល់ចំណុចខ្វះខាតនានា និងលើកទឹកចិត្តឲ្យខិតខំប្រឹងប្រែងបន្ថែមទៀតផងដែរ។ នេះជាភាពកក់ក្ដៅ និងជាកម្លាំងចិត្តដែលនិស្សិតម្នាក់ៗចង់បានពីលោកគ្រូ អ្នកគ្រូ ដែលត្រូវបានចាត់ទុកថាជា ឪពុកម្ដាយទីពីរដូចនេះដែរ ។ ជាងនេះទៅទៀត ក្រៅពីផ្ដល់ការបណ្ដុះបណ្ដាលនៅក្នុងសាលា សាកលវិទ្យាល័យបានរៀបចំ និងលើកទឹកចិត្តឲ្យនិស្សិតបានចូលរួមជាមួយការងារសង្គមជាច្រើន តាមរយៈការរៀបចំកម្មវិធីចុះកម្មសិក្សា ចូលរួមជួយការងារសង្គម ដូចជាផ្សព្វផ្សាយច្បាប់ចរាចរណ៍ សម្អាតបរិស្ថាន និងការងារសប្បុរសធម៌នានាទៀត ។

បើយើងងាកមកមើលពីបរិយាកាសនៃការសិក្សាវិញ យើងឃើញថា សាលាមានការរៀបចំបានយ៉ាងល្អផងដែរ ដូចជាតាមបន្ទប់រៀនមានផាសុកភាព មានសម្ភារៈគ្រប់គ្រាន់បម្រើឲ្យការសិក្សា ទាំងតុ កៅអី ស្លាយសម្រាប់ធ្វើបទបង្ហាញ និងអ៊ីនធឺណិត ។ បណ្ណាល័យ មានបណ្ដុំសៀវភៅជាច្រើនទៅតាមមុខជំនាញសម្រាប់ឲ្យនិស្សិតធ្វើការស្រាវជ្រាវ ទាំងភាសាខ្មែរ និងភាសាបរទេស ព្រមទាំងមានរៀបចំកន្លែងឲ្យនិស្សិតអាចស្វ័យសិក្សានិងពិភាក្សាគ្នាជាក្រុមបានផងដែរ ។ ចំណែកកង់ទីនសម្រាប់ទទួលទានអាហារ ក៏មានការរៀបចំមានអនាម័យល្អ បុគ្គលិកមានភាពរួសរាយរាក់ទាក់ និងមិនបង្កការរំខានណាមួយដល់ការសិក្សានោះទេ ។

យោងលើហេតុផលទាំងអស់នេះ នាងខ្ញុំជឿជាក់ថា សាកលវិទ្យាល័យនឹងនៅតែបន្តជាគ្រឹះស្ថានឧត្ដមសិក្សាដែលយុវជនគ្រប់រូបជឿទុកចិត្ត និងចង់មកទទួលយកបទពិសោធន៍សិក្សានៅទីនេះកាន់តែច្រើនបន្ថែមទៀត។ ជាទីបញ្ចប់ នាងខ្ញុំសូមគោរពថ្លែងអំណរគុណ និងដឹងគុណ ចំពោះឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកនាយកសាលាក្រោយបរិញ្ញាបត្រ និងលោកគ្រូអ្នកគ្រូទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលះបង់កម្លាំងកាយ ចិត្ត នៅក្នុងតួនាទីផ្ដល់ការអប់រំ បណ្ដុះបណ្ដាលដល់និស្សិតគ្រប់រូប សំដៅកសាងធនធានមនុស្សនៅក្នុងប្រទេសកម្ពុជាឲ្យមានគុណភាព និងចំណេះ ជំនាញពិតប្រាកដ ។ នាងខ្ញុំសូមគោរពជូនពរ ឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកនាយកសាលាក្រោយបរិញ្ញាបត្រ និងលោកគ្រូអ្នកគ្រូទាំងអស់ មានសុខភាពល្អ កម្លាំងមាំមួន បញ្ញាឈ្លាសវៃ និងជន្មាយុយឺនយូរ ដើម្បីបន្តលើកកម្ពស់វិស័យអប់រំកម្ពុជាបន្តទៀត ។





# និស្សិត ឌៀប ស៊ុយគីម

## ឌៀប ស៊ុយគីម ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសនីតិឯកជន ឆ្នាំទី១

## ឆ្នាំសិក្សា២០២៣-២០២៤

Email: terraindiep@gmail.com



"កុំចាំសិន" ត្រូវតែធ្វើភ្លាម ព្រោះពេលវាលាមិនចាំយើងនោះទេ នេះជាអ្វីដែលខ្ញុំចាំមិនភ្លេចពីសាស្ត្រាចារ្យជាទីស្រលាញ់របស់ខ្ញុំ ហាប់ ផល្លី ។ ខ្ញុំបាទឈ្មោះ ឌៀប ស៊ុយគីម ប្រធានថ្នាក់មកពីក្រុម MPL20-2B។

និយាយទៅខ្ញុំត្រូវទៅរៀនបន្តថ្នាក់អនុបណ្ឌិតនេះនៅបរទេស ក្រោយពីខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលគេតែងហៅថា RULE។ តាមពិតទៅ ខ្ញុំធ្លាប់បានសិក្សានៅបរទេសមួយរយៈ កាលពីរៀននៅវិទ្យាល័យ ហេតុនេះហើយ បានជាខ្ញុំចង់ទៅក្រេបយកចំណេះវិជ្ជាពីបរទេសបន្ត បន្ទាប់ពីរៀនចប់បរិញ្ញាបត្រ ដើម្បីត្រឡប់មកវិញ ងាយស្រួលជួយអភិវឌ្ឍប្រទេសឲ្យកាន់តែល្អប្រសើរ និងជួយបណ្ដុះបណ្ដាលធនធានមនុស្សជំនាន់ក្រោយឲ្យយល់ដឹងពីច្បាប់កាន់តែច្រើនឡើងៗ និងអាចឲ្យពួកគេជៀសវាងការប្រព្រឹត្តបទល្មើស។ ប៉ុន្តែបំណងនេះត្រូវបានខកខាន ដោយសារតែភាពមមាញឹកនឹងមុខរបរគ្រួសារច្រើនពេក ដោយមិនអាចដកខ្លួនទៅបន្តការសិក្សានៅបរទេសបាន។ ទោះបីយ៉ាងណាក៏ដោយ ដោយសារតែជានិស្ស័យនឹងសាកលវិទ្យាល័យដែលមានវ័យចំណាស់មួយនេះ ទើបនៅឆ្នាំ២០២៣ ខ្ញុំបានសម្រេចចិត្តត្រឡប់មកបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រឯកទេសនីតិឯកជនតែម្ដង។

ក្រោយពីបានសិក្សាអស់រយៈពេលជិតមួយឆ្នាំកន្លងមក និយាយដោយត្រង់ទៅ ទាំងកិច្ចការស្រាវជ្រាវ និងកិច្ចការផ្ទះក៏មានច្រើនគួរសមដែលធ្វើឲ្យពួកខ្ញុំកាន់តែមមាញឹក ប៉ុន្តែជាថ្នូរមកវិញ ពួកខ្ញុំទទួលបានចំណេះដឹងកាន់តែច្រើន។ រីឯការបង្រៀនរបស់លោកគ្រូអ្នកគ្រូវិញក៏មានភាពច្បាស់លាស់ លម្អិត និងប្រកបដោយវិជ្ជាជីវៈ តឹងរ៉ឹង ម៉ឺងម៉ាត់ និងមានភាពបត់បែន។ បើពិនិត្យមើលថ្នាក់ដឹកនាំ និងអ្នកច្បាប់ធំៗ ល្បីៗ រួមមាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលនៃគណៈអភិបាលខេត្តចៅក្រម ព្រះរាជអាជ្ញា មេធាវីខ្លាំងៗ ល្អៗ ភាគច្រើនសុទ្ធសឹងតែបានសិក្សារៀនសូត្រចេញពីសាកលវិទ្យាល័យនេះ។ ទាំងនេះគឺដោយសារតែសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាសាកលវិទ្យាល័យឈានមុខគេក្នុងការផ្តល់នូវគុណភាពសិក្សាខ្ពស់ សម្បូរបែប ទាំងផ្នែកទ្រឹស្តី និងការលើកយកមកសិក្សាអនុវត្តជាក់ស្តែង។ កម្មវិធីសិក្សាទំនើបឆ្លើយតបនឹងនិន្នាការនៃបរិបទសម័យថ្មីផងដែរ។

ចំពោះខ្ញុំផ្ទាល់ អ្វីដែលមិនអាចបំភ្លេចបាននោះគឺ ការចូលរួមជាមួយសកម្មភាពសង្គម ដែលបានចុះជួយធ្វើសាលារៀន បង្គន់ និងផ្តល់នូវតម្រូវការផ្សេងៗទៀតដល់សាលាមត្តេយ្យសិក្សាមួយនៅស្រុកព្រះស្ដេច ខេត្តព្រៃវែង។ ក្រៅពីនេះ នៅពេលធ្វើទស្សនកិច្ចសិក្សាទៅកន្លែងនោះ បានផ្តល់ឱកាសឲ្យនិស្សិត និងលោកគ្រូអ្នកគ្រូ មានភាពស្និទស្នាល ភាពរីករាយ និងបន្សល់ទុកអនុស្សាវរីយ៍មិនអាចបំភ្លេចបាន។

# និស្សិត ហេង នុតត្ថារ៉ា

និស្សិត ហេង នុតត្ថារ៉ា បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រង ឆ្នាំទី២

**Email:** nuttaraheng@gmail.com



វិស័យអប់រំនៅកម្ពុជា មានការរីកដុះដាលគួរឲ្យកត់សម្គាល់ មិនថាគ្រឹះស្ថានសាធារណៈ ឬគ្រឹះស្ថានឯកជន និងបានបន្តកំណែទម្រង់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងគោលបំណងលើកកម្ពស់ការអប់រំឲ្យកាន់តែមានប្រសិទ្ធភាព។ នៅក្នុងនោះ មានសាកលវិទ្យាល័យធំៗជាច្រើនដែលមានលោកគ្រូ-អ្នកគ្រូ ពោរពេញទៅដោយសញ្ញាបត្រខ្ពស់ៗ មានជំនាញវិជ្ជាជីវៈច្បាស់លាស់ ប្រកបដោយក្រមសីលធម៌អាកប្បកិរិយាល្អ និងបទពិសោធន៍យូរឆ្នាំ។ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាសាកលវិទ្យាល័យមួយដែលឈរលេខរៀងលំដាប់ក្នុងចំណោមសាកលវិទ្យាល័យធំៗក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានទទួលស្គាល់ពីគុណភាព វិធីសាស្រ្តក្នុងការបង្រៀន និងណែនាំនិស្សិតគ្រប់រូបឲ្យទទួលបាននូវចំណេះ និងជំនាញពិតប្រាកដ។

ចុងឆ្នាំ២០២១ ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ខ្ញុំបាទសម្រេចចិត្តជ្រើសរើសសាកលវិទ្យាល័យនេះ សិក្សាបន្តថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ មូលហេតុដែលខ្ញុំបានសម្រេចចិត្តបន្តការសិក្សានៅទីនេះ ពីព្រោះសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាគ្រឹះស្ថានអប់រំឈានមុខគេមួយក្នុងចំណោមគ្រឹះស្ថានអប់រំរបស់រដ្ឋផ្សេងៗទៀត និងត្រូវបានទទួលស្គាល់ពីគុណភាពនៃការអប់រំ រួមជាមួយលោកគ្រូអ្នកគ្រូដែលមានជំនាញច្បាស់លាស់ និងបទពិសោធន៍ក្នុងការបង្រៀនជាច្រើនឆ្នាំ ជាពិសេសនោះគឺសម្បូរទៅដោយលោកគ្រូអ្នកគ្រូដែលបានបញ្ចប់ថ្នាក់បណ្ឌិត រួមទាំងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដែលមកពីក្រៅប្រទេស ដែលជាសក្តានុពលដ៏ល្អសម្រាប់ខ្ញុំបាទសិក្សា និងក្រេបយកចំណេះវិជ្ជា។ ជាក់ស្តែង ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ គឺទាមទារឲ្យនិស្សិតមានភាពទទួលខុសត្រូវខ្ពស់លើការសិក្សារបស់ខ្លួន និងការសិក្សាស្រាវជ្រាវបន្ថែមពីលើការណែនាំរបស់សាស្រ្តាចារ្យក្នុងថ្នាក់ ដើម្បីអភិវឌ្ឍចំណេះដឹងរបស់ខ្លួនឲ្យកាន់តែរីកចម្រើនទ្វេដង។ យ៉ាងណាមិញ ចំពោះបទពិសោធន៍របស់ខ្ញុំបាទផ្ទាល់ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រងនេះ គឺជាបទពិសោធន៍ក្នុងជីវិតមួយភាគដែលមិនអាចបំភ្លេចបាន មានទាំងការសប្បាយរីករាយពេលទទួលបានចំណេះដឹងពីសាស្រ្តាចារ្យ និងភាពល្ងឹងជូរចត់ពេលអនុវត្តកិច្ចការងារជាក់ស្តែង ដែលសាស្រ្តាចារ្យដាក់ឲ្យអនុវត្ត។

ជាចុងក្រោយខ្ញុំបាទ សូមថ្លែងអំណរគុណដល់ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោកនាយកសាលាក្រោយបរិញ្ញាបត្រ គ្រូបន្ទុកថ្នាក់ និងលោកគ្រូអ្នកគ្រូបង្រៀន នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ចំពោះការលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត រួមទាំងពេលវេលាដ៏មានតម្លៃក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលប្រកបដោយគុណភាពសម្រាប់លើកកម្ពស់ធនធានមនុស្សនៅកម្ពុជា នាពេលបច្ចុប្បន្ន។

# និស្សិត សំ កុកហេង

## សំ កុកហេង ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសហិរញ្ញវត្ថុ ឆ្នាំទី២

Email: samkokheng.skh@gmail.com



សូមគោរព សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាទីគោរព! សួស្តីមិត្តៗ និស្សិតជាទីរាប់អាន។

ការចូលរៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចនេះ គឺតម្រូវឲ្យមានការប្រឡងសាកល្បងសមត្ថភាពដ៏តឹងរ៉ឹងជាប់ជាប្រចាំ។ ជាការពិតណាស់ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច គឺជាគ្រឹះស្ថានឧត្តមសិក្សារដ្ឋមួយដែលមានវ័យចំណាស់នៅប្រទេសកម្ពុជា ហើយក៏ជាទីណាត់ជួបនៃអ្នកមានចំណេះដឹង ចំណេះធ្វើ ជំនាញ និងបទពិសោធន៍ផងដែរ។

ការបន្តសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មួយនេះ គឺជាផ្នែកប្រសើរមួយដល់និស្សិត ព្រោះវាតម្រូវ និងទាមទារឲ្យមានការអនុវត្តជាក់ស្តែង ការស្រាវជ្រាវ ការបង្ហាញ និងការដោះស្រាយលើករណីសិក្សានៃទីផ្សារហិរញ្ញវត្ថុ ទីផ្សារមូលធន និងធ្វើកិច្ចការដើម្បីបំពេញ និងបង្កើននូវចំណេះ និងជំនាញ ឲ្យមានភាពរីកចម្រើន និងទំលំទូលាយ ពិសេសបង្រៀនពាក់ព័ន្ធនឹងការសម្រេចចិត្តប្រកបដោយហេតុផល និងការគិតគូរឲ្យបានស៊ីជម្រៅ។

ជាមួយនឹងការបន្ទាន់សម័យនៃកម្មវិធីសិក្សា និងការរៀបចំសិក្ខាសាលាដ៏ច្រើនសម្បូរបែប គឺជាចំណុចវិជ្ជមានដែលឆ្លើយតបទៅនឹងតម្រូវការសង្គម ការងារ ការប្រឡងប្រជែងអាហារូបករណ៍នានានៅក្នុងប្រទេស និងទៅរៀននៅក្រៅប្រទេស ព្រមទាំងការប្រឡងប្រជែងចូលបម្រើការងាររដ្ឋផងដែរ។ ដោយឡែក សំណង់អគារ គ្រឿងបរិក្ខារបង្រៀន របៀបរបបនៃការបង្រៀនរបស់លោកគ្រូអ្នកគ្រូ និងបរិស្ថានសិក្សាដែលប្រកបដោយបទដ្ឋានខ្ពស់ លោកគ្រូអ្នកគ្រូបណ្ឌិត អនុបណ្ឌិតដែលប្រកបដោយបទពិសោធន៍ ក្រមសីលធម៌ និងជំនាញវិជ្ជាជីវៈខ្ពស់បានធ្វើឲ្យខ្ញុំបាទ មានជំនឿក្នុងចិត្តថា ខ្ញុំបាទបានធ្វើការសម្រេចចិត្តមួយដ៏ត្រឹមត្រូវ ដែលបានជ្រើសរើសយកសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍខ្លួនឲ្យក្លាយទៅជាធនធានឲ្យកាន់តែមានតម្លៃចំពោះសង្គមគ្រួសារ និងសង្គមជាតិទាំងមូល។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណគុណដល់មិត្តនិស្សិតអ្នកអាន និងសូមឲ្យមិត្តនិស្សិតទទួលបាននូវភាពជោគជ័យក្នុងការសិក្សា មានសុខភាពល្អ ដើម្បីបន្តជាសសរទ្រូងនៃប្រទេសជាតិយើង ឲ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងគោលដៅអភិវឌ្ឍន៍ដោយចីរភាពលើធនធានមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។

# និស្សិត លុន ហានហ្វា

**លុន ហានហ្វា និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសនីតិឯកជន ឆ្នាំទី១**

Email: hanfalune2016@gmail.com



ខ្ញុំបាទបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយជោគជ័យ នៅឆ្នាំ២០១៧។ ជាលទ្ធផល នៃការខិតខំប្រឹងប្រែង និងក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ខ្ញុំបាទមានសមត្ថភាពគ្រប់គ្រាន់ និងមានឱកាសទទួលបានការងារដ៏ល្អមួយ។ រយៈពេល ៦ឆ្នាំកន្លងផុតទៅ និងស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹង និងអភិវឌ្ឍលើគ្រប់វិស័យ ឆ្ពោះទៅកាន់ចក្ខុវិស័យប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ព្រមទាំងក្លាយជាអារ្យប្រទេសជឿនលឿនមួយក្នុងតំបន់នាពេលអនាគត និងដោយយល់ថាធនធានមនុស្សដែលមានសមត្ថភាព ព្រមទាំងមានឧត្តមគតិខ្ពស់ជាសំខាន់ ខ្ញុំបាទបានសម្រេចចិត្តភ្លាមៗ ក្នុងការបន្តជ្រើសរើសយកសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ជាលទ្ធផលនៃការសិក្សារយៈពេល៩ខែកន្លងមកនេះ ខ្ញុំបាទទទួលបាននូវសមិទ្ធផលធំៗចំនួនបី រួមមាន៖

សមិទ្ធផលទី១ គឺ ការអភិវឌ្ឍនូវសមត្ថភាពផ្ទាល់ខ្លួន និងវិជ្ជាជីវៈក្នុងវិស័យច្បាប់។ អនុលោមតាមគោលការណ៍ និងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ព្រមទាំងការបង្ហាត់បង្រៀន ដឹកនាំ និងផ្តល់នូវអនុសាសន៍ល្អៗរបស់លោកគ្រូអ្នកគ្រូទាំងអស់ និស្សិតគ្រប់រូបបង្កើនបាននូវចំណេះដឹងផ្នែកច្បាប់ និងជំនាញផ្នែកទន់។ ផលជះនៃការសិក្សាដែលខ្ញុំទទួលបានរួមមាន សមត្ថភាពក្នុងការគិតបែបស៊ីជម្រៅ សមត្ថភាពវិភាគ ការគ្រប់គ្រងពេលវេលា គន្លឹះក្នុងការក្លាយជាអ្នកដឹកនាំ ជំនាញធ្វើបទបង្ហាញ និងជំនាញជាច្រើនទៀត ដែលជំនាញទាំងអស់នេះ ក៏បានជួយឲ្យខ្ញុំបាទទទួលបានជោគជ័យនៅកន្លែងធ្វើការផងដែរ។

សមិទ្ធផលទី២ គឺ ពង្រីកទំនាក់ទំនងវិជ្ជាជីវៈ និងសង្គម។ ខណៈពេលដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតគ្រប់រូបនឹងមានទំនាក់ទំនងជាមួយបណ្ឌិតបញ្ញាជន រួមទាំងនិស្សិត លោកគ្រូអ្នកគ្រូ និងអ្នកដែលកំពុងប្រកបវិជ្ជាជីវៈក្នុងវិស័យច្បាប់។ ទំនាក់ទំនងទាំងនេះ មានលេចចេញនូវបុគ្គលដែលមានគំនិតដូចគ្នា និងគំនិតផ្សេងគ្នាផង ដែលសុទ្ធសឹងតែជាចំណេះដឹងថ្មីៗ និងល្អៗសម្រាប់ការអភិវឌ្ឍរបស់ខ្ញុំបាទ។ លើសពីចំណេះដឹងទាំងនោះ ទំនាក់ទំនងនេះអាចបង្កើតនូវឱកាសដើម្បីពង្រីកទំនាក់ទំនងវិជ្ជាជីវៈផងដែរ ក្នុងការផ្លាស់ប្តូរនូវបទពិសោធន៍ ទំនាក់ទំនងការងារ ឱកាសនានាក៏ដូចជាកិច្ចសហប្រតិបត្តិការជាច្រើនបានកើតឡើង។

សមិទ្ធផលទី៣ គឺ ការបោះជំហានទៅមុខនៃការងារ។ ការសិក្សាកន្លងមកនេះ ខ្ញុំបាទទទួលស្គាល់អំពីកំណើននៃចំណេះដឹងថ្មីៗ ភាពស៊ីជម្រៅនៃការសិក្សា ភាពប៉ិនប្រសប់ និងទំនុកចិត្ត ដែលកត្តាទាំងនេះបានបើកឱកាសការងារថ្មីៗសម្រាប់ខ្ញុំបាទ។ វាដើរតួនាទីជាអ្នកជំរុញនូវនវានុវត្តន៍នៃវិជ្ជាជីវៈ និងជួយឲ្យផ្លាស់ទីពីកម្រិតទាប ឬមធ្យមទៅកម្រិតថ្នាក់គ្រប់គ្រងដឹកនាំ។ ទន្ទឹមនឹងនេះ ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ ធានាបាននូវនិរន្តរភាពនៃការងារ និងជួយឲ្យនិស្សិតមានសក្តានុពលខ្ពស់ក្នុងការប្រកួតប្រជែងការងារផងដែរ។ ថ្នាក់អនុបណ្ឌិត ឬបរិញ្ញាបត្រជាន់ខ្ពស់ជាច្រើននៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះទទួលយកនិស្សិតដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញផ្សេង ឬមិនពាក់ព័ន្ធ។ វាសបញ្ជាក់ ឲ្យឃើញថា អ្នកទាំងនោះក៏មានឱកាសដើម្បីធ្វើការផ្លាស់ប្តូរពាក់កណ្តាលអាជីព និងស្វែងរកការងារអ្វីដែលថ្មីហើយខ្លួនឯងស្រឡាញ់ផងដែរ។

សរុបជារួមមក ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចពិតជាបានផ្តល់នូវគុណប្រយោជន៍សំខាន់ជាច្រើនសម្រាប់រូបខ្ញុំបាទ។ ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា ប្រទេសកម្ពុជានឹងកើនបាននូវគ្រាប់ពូជធនធានមនុស្ស បញ្ញវន្ត អ្នកដឹកនាំ និងពង្រីកនូវវិសាលភាពនៃកិត្តិនាមរបស់ប្រទេសឲ្យកាន់តែល្បីរន្ទឺ។ ម្យ៉ាងវិញទៀត ខ្ញុំបាទក៏សំណូមពរដល់ពលរដ្ឋកម្ពុជាទាំងអស់ បណ្តុះនូវឆន្ទៈ និងខ្នះខ្នែងក្នុងការអភិវឌ្ឍនូវសមត្ថភាពរបស់ខ្លួន ព្រមទាំងជំរុញបន្តដល់អ្នកជំនាន់ក្រោយឲ្យប្រឹងប្រែងបង្កើនសមត្ថភាពខ្លួនដើម្បីចូលរួមកសាងប្រទេសកម្ពុជាឲ្យមានការរីកចម្រើន និងជឿនលឿនជាលំដាប់។

# និស្សិត ហម កុកយូ

## ហម កុកយូ អតីតនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសនីតិឯកជន

**Email:** kokyouhom@gmail.com



ក្រោយពីបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នាសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក អ្វីដែលជាការផ្តោតសំខាន់សម្រាប់ខ្ញុំគឺការស្វែងរកនូវការងារមួយសមស្របនិងជំនាញដែលខ្ញុំបានរៀនសូត្រ នាពេលកន្លង។ ប៉ុន្តែ ផ្ទុយទៅវិញ បន្ទាប់ពីខ្ញុំបានពិភាក្សាជាមួយក្រុមគ្រួសារក៏ដូចជាលោកគ្រូអ្នកគ្រូ រៀមច្បង និងការសាកសួរព័ត៌មានផ្សេងៗផងដែរនោះ ខ្ញុំបានសម្រេចចិត្តជ្រើសរើសបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ផ្នែកនីតិជន។

មូលហេតុនៃការសម្រេចចិត្តនេះគឺមកពី ចិត្តមួយចង់ស្វែងរកការងារធ្វើ រីឯចិត្តមួយចង់ទទួលបានចំណេះដឹងថ្មីបន្ថែមទៀតផងនោះ ខ្ញុំក៏បានរើសយកកាលវិភាគសិក្សា នាពេលចុងសប្តាហ៍ ដើម្បីបង្កភាពងាយស្រួលសម្រាប់ខ្ញុំអាចបំពេញការងារនៅរៀងរាល់ថ្ងៃចន្ទ រហូតដល់ថ្ងៃសុក្រ។ នៅពេលកំពុងសិក្សាបានមួយរយៈ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ ចំពោះការសិក្សាបន្តនៅសាលាក្រោយបរិញ្ញាបត្រនេះ។ ក៏ព្រោះថាចំណេះដឹងថ្មីដែលខ្ញុំមិនធ្លាប់បានជួបប្រទះពីមុននោះ គឺបានលេចចេញឡើងមកនៅពេលកំពុងសិក្សាតែម្តង តាមរយៈការណែនាំ និងបង្ហាត់បង្ហាញពីសំណាក់លោកគ្រូអ្នកគ្រូដែលបង្រៀនតាមមុខវិជ្ជានីមួយៗ ដែលសុទ្ធសឹងជាគ្រូមានចំណេះដឹង ជំនាញជំនាញច្បាស់លាស់ និងបទពិសោធន៍ជាច្រើនឆ្នាំ ក្នុងការអនុវត្តជាក់ស្តែងពាក់ព័ន្ធនឹង មុខវិជ្ជាបង្រៀនទាំងអស់នោះ។

សម្រាប់ខ្ញុំ ក្នុងរយៈពេល២ឆ្នាំ នៃការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិឯកជន បានផ្តល់ឲ្យខ្ញុំនូវអត្ថប្រយោជន៍ជាច្រើន ដើម្បីទុកសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តជាក់ស្តែងទាក់ទងនឹងតម្រូវការសង្គម នាពេលបច្ចុប្បន្ននេះ។ មិនត្រឹមតែប៉ុណ្ណោះ ខ្ញុំក៏ទទួលបាននូវការប្រាស្រ័យទាក់ទងគ្នាបានយ៉ាងល្អ ពីបងប្អូនមិត្តរួមជំនាន់របស់ខ្ញុំ ដែលពួកគាត់សុទ្ធតែជាអ្នកវិជ្ជាជីវៈកំពុងបំពេញការងារនៅតាមស្ថាប័ននានាថែមទៀតផង។ ជាងនេះទៅទៀត ខ្ញុំកាន់តែមិនអាចបំភ្លេចបាននូវ អនុស្សាវរីយ៍ល្អៗជាច្រើនពីថ្នាក់រៀននេះ រួមទាំងការយកចិត្តទុកដាក់បំផុត ពីសំណាក់លោកនាយកសាលាក្រោយបរិញ្ញាបត្រ ដែលតែងតែផ្តល់នូវដំបូន្មានល្អៗ និងចំណេះធ្វើជាច្រើនដល់ខ្ញុំ។

ជាចុងក្រោយ ក្នុងនាមជានិស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សូមលើកទឹកចិត្តដល់បងប្អូនមិត្តនិស្សិតជំនាន់ក្រោយៗទៀត គប្បីសម្រេចចិត្តឲ្យបានច្បាស់លាស់ ក្នុងការរៀបចំផែនការនៃការសិក្សារបស់ខ្លួន ដើម្បីទទួលបាននូវបទពិសោធន៍ល្អៗ និងចំណេះដឹងថ្មីបន្ថែមទៀត ដូចជារូបខ្ញុំផ្ទាល់។





## និស្សិត វង្ស រ៉ាឃីម




វង្ស រ៉ាឃីម ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ
ឯកទេសនីតិឯកជន ជំនាន់២២ ជំហាន១
ឆ្នាំសិក្សា២០២៤-២០២៥
Email: palirakhim@gmail.com


ការបណ្តុះគំនិតពីភាពត្រឹមត្រូវ សុទិដ្ឋិនិយម តម្លាភាព ច្នៃប្រឌិត និងការផ្សាភ្ជាប់រវាងទំនើបកម្មការអប់រំ និងអភិបាលកិច្ចបែបចូលរួម គឺជាសេណារីយ៉ូមួយសំខាន់ សម្រាប់អនាគតការអប់រំនៅកម្ពុជា ក្នុងយុគ-សម័យរលកអាកាស ឬបរិវត្តកម្មឌីជីថល។ ទស្សនទានចំហនេះ គ្រាន់តែជាការវិភាគ និងការព្យាករទុកសម្រាប់គុណតម្លៃកម្ពុជា។

គិតត្រឹមឆ្នាំ២០២២បាទចូលបម្រើការងារស្ម័គ្រចិត្តជាមួយសាស្ត្រាចារ្យបណ្ឌិត ហាប់ ផល្លី ស្ថិតក្នុងនាមជាជំនួយការ តាមដាន ត្រួតពិនិត្យ ចងក្រងបណ្តាបទប្បញ្ញត្តិវិស័យភូមិបាល និងរដ្ឋប្បវេណី នៅសាលាក្រោយបរិញ្ញា-បត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្រោយៗមក ខ្ញុំបាទនៅបន្តជួយកិច្ចការចាំបាច់មួយចំនួន ការរៀបចំសកម្មភាពសង្គម សិក្ខាសាលា អនុរក្សប្រឡង ដែលអាស្រ័យលើពេលវេលាផ្ទាល់ខ្លួនជាក់ស្តែងជាមួយលោកគ្រូអ្នកគ្រូនៅសាលាក្រោយបរិញ្ញាបត្រ។ ចន្លោះឆ្នាំ២០១៥ ដល់២០២១ ខ្ញុំបាទគឺជាអតីតនិស្សិតបានបញ្ចប់ការសិក្សាមកពីក្រៅប្រទេសទាំងកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកទេសសេដ្ឋ-កិច្ចកសិកម្ម។ យ៉ាងណាមិញ អំឡុងពេលរាលត្បាតនៃជំងឺសកល[កូវីត-១៩] ខ្ញុំបាទសម្រេចចិត្តបន្តការសិក្សាបន្ថែម ផ្នែកនីតិសាស្ត្រ ដែលធ្លាប់ជាជំនាញនិយមចិត្តខ្ញុំពីវ័យកុមារភាពផង និងតម្រូវការជាក់ស្តែងជាមួយការងារផង (អតីតមន្ត្រីទូត និងបកប្រែនៃស្ថានទូតសហព័ន្ធរុស្ស៊ីប្រចាំនៅកម្ពុជា)។ ការបញ្ចប់កម្រិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ខ្ញុំទទួលលទ្ធផលល្អណាស់[GPA4.0] និងចំណាត់ថ្នាក់លេខ១ ទាំងបួនឆ្នាំសិក្សា ក៏ដូចជាអាចទទួលលទ្ធភាពបន្តការសិក្សានៅក្រៅប្រទេសមួយចំនួនដែរ ដូចជានៅឯចក្រភពអង់គ្លេស សហព័ន្ធរុស្ស៊ី និងរាជាណាចក្រធិបតេយ្យលុចសំបួរ។ ប៉ុន្តែ ដោយសារអលទ្ធភាពហិរញ្ញវត្ថុ ពេលវេលា និងតម្រូវការវត្តមាននៅក្នុងប្រទេស ទើបខ្ញុំបាទសម្រេចចិត្តលះបង់ឱកាសអាហារូបករណ៍ នឹងត្រូវសម្រេចចិត្តបន្តការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសនីតិឯកជន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ។ ហាក់បីជាឧបនិស្ស័យក៏ថាបាន ដែលរាល់ជំហាននៃការសិក្សាឯកទេសថ្មីនេះ តែងតែវិលជុំនិងអាចភ្ជាប់បំណងបន្តលើការសិក្សាថ្នាក់បណ្ឌិត នាពេលអនាគតនៅទីនេះដដែល ក៏អាចថាបាន ជាពិសេស គោលបំណងចង់បន្តការបង្រៀននៅទីនេះ។

ការលត់ដំ និងការសិក្សាប្រកបដោយភាពប៉ិនប្រសប់ ច្បាស់លាស់ និងនិយាមស្រាវជ្រាវ ខ្ញុំបាទគឺពិតជាមានសេចក្តីត្រេកត្រអាល លំឱនគារវកិច្ចផ្លូវការ និងគោរពថ្លែងអំណរគុណចំពោះការអប់រំដ៏វិសេសវិសាលពីសំណាក់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ សាស្ត្រាចារ្យរង សាស្ត្រាចារ្យជំនួយ លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា មជ្ឈមណ្ឌលសហប្រតិបត្តិការបារាំង ថ្នាក់ពិសេសផ្នែកនីតិសាស្ត្រភាសាបារាំង និងបុគ្គលិកទាំងមូលនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យា-សាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែង ស្រាវជ្រាវបង្រៀនចំណេះវិជ្ជាច្បាប់ជាន់ខ្ពស់ និងលះបង់គ្រប់យ៉ាងសម្រាប់ការអប់រំច្បាប់នៅកម្ពុជាប្រកបដោយស្មារតីបុរេសកម្ម គុណភាព និងបរិយាបន្ន នៃរាល់សមិទ្ធិផលវិជ្ជមានដែលខ្ញុំបាទរៀបរាប់ខាងលើ៕

## ៤. ប្រតិទិនសម្រាប់ជំនាន់ និងជំហាននីមួយៗ ពេលចូលរៀន និងពេលបញ្ចប់

**និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់២១ ជំហាន១**

ឆ្នាំទី១ ឆមាសទី១ ចូលរៀនថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣ ☑
ឆ្នាំទី១ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ ☑
ឆ្នាំទី២ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៤ ☑
ឆ្នាំទី២ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥ នឹងបញ្ចប់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៥ ➔□

**និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់២១ ជំហាន២**

ឆ្នាំទី១ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤ ☑
ឆ្នាំទី១ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៤ ☑
ឆ្នាំទី២ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥ ➔□
ឆ្នាំទី២ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៥ នឹងបញ្ចប់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦ □□

**និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់២២ ជំហាន១**

ឆ្នាំទី១ ឆមាសទី១ ចូលរៀនថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៤ ☑
ឆ្នាំទី១ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥ ➔□
ឆ្នាំទី២ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៥ □
ឆ្នាំទី២ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៦ នឹងបញ្ចប់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៦ □□

**និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់២២ ជំហាន២**

ឆ្នាំទី១ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥ ➔□
ឆ្នាំទី១ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៥ □
ឆ្នាំទី២ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៦ □
ឆ្នាំទី២ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៦ នឹងបញ្ចប់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៧ □□

**និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់២៣ ជំហាន១**

ឆ្នាំទី១ ឆមាសទី១ ចូលរៀនថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ □
ឆ្នាំទី១ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៦ □
ឆ្នាំទី២ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៦ □
ឆ្នាំទី២ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៧ នឹងបញ្ចប់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៧ □□

**និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់២៣ ជំហាន២**

ឆ្នាំទី១ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៦ □
ឆ្នាំទី១ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៦ □
ឆ្នាំទី២ ឆមាសទី១ ចូលរៀនថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៧ □
ឆ្នាំទី២ ឆមាសទី២ ចូលរៀនថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៧ នឹងបញ្ចប់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៨ □□

☑ បានបញ្ចប់

➔□ កំពុងដំណើរការ (អំឡុងពេលបោះពុម្ពសៀវភៅនេះ) (សញ្ញា □ ពេលចប់ធីក ☑ វាផង)

□ មិនទាន់ចាប់ផ្ដើម / បញ្ចប់ (សញ្ញា □ ពេលចប់ធីក ☑ វាផង)

## ៥. សកម្មភាពក្រៅកម្មវិធីសិក្សារបស់សាលាក្រោយបរិញ្ញាបត្រ

ចាប់តាំងពីឆ្នាំ២០១៧មក សាលាក្រោយបរិញ្ញាបត្របានរៀបចំសកម្មភាពក្រៅកម្មវិធីសិក្សាសំខាន់ៗមួយចំនួន រួមមានសកម្មភាពសង្គម និងទស្សនកិច្ចសិក្សា ព្រមទាំងសកម្មភាពចុះជួយសហគមន៍។

### ៥.១. សកម្មភាពសង្គម និងទស្សនកិច្ចសិក្សារបស់សាលាក្រោយបរិញ្ញាបត្រ

ជារៀងរាល់ឆ្នាំ សាលាក្រោយបរិញ្ញាបត្របានគ្រោងធ្វើសកម្មភាពសង្គម និងទស្សនកិច្ចសិក្សាយ៉ាងតិច២ដង ពោលគឺទៅតាមឆមាសនីមួយៗដែលនិស្សិតសិក្សា។

| លរ | កាលបរិច្ឆេទ | សកម្មភាព | ទីកន្លែង | ចំនួនអ្នកចូលរួម |
|---|---|---|---|---|
| **២០១៧** | | | | |
| 1 | ១០ កញ្ញា ២០១៧ | សកម្មភាពសង្គម៖ ជួយសាងសង់អណ្តូងទឹកនៅវត្តអង្គកកោះ ភូមិកោះម៉ាក់ប្រាំង ឃុំបឹងសាលាខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត | ខេត្តកំពត | 120 |
| 2 | ៩ ធ្នូ ២០១៧ | សកម្មភាពសង្គម៖ ថវិកាជួយមន្ទីរពេទ្យគន្ធបុប្ផា | ភ្នំពេញ | N/A |
| 3 | ២៩-៣១ ធ្នូ ២០១៧ | សកម្មភាពចូលរួមជាមួយសហគមន៍៖ សកម្មភាពពន្យល់សិស្សបឋមសិក្សា ឡាបានសៀក ពីសារៈសំខាន់នៃការសិក្សា | រតនគិរី | 22 |
| **២០១៨** | | | | |
| 4 | ៤ មីនា ២០១៨ | ទស្សនកិច្ចសិក្សាទៅកាន់ប្រាសាទសំបូរព្រៃគុក | ខេត្តកំពង់ធំ | 129 |
| 5 | ១៦-១៨ មិថុនា ២០១៨ | ទស្សនកិច្ចសិក្សាទៅកាន់ខេត្តព្រះវិហារ និងសៀមរាប | ខេត្តព្រះវិហារ និងខេត្តសៀមរាប | 18 |
| 6 | ២៦ តុលា ២០១៨ | វិភាគទានសប្បុរសធម៌ទាក់ទងនឹងការផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកនៅក្នុងកម្មវិធីពិព័រណ៍សិក្សា២០១៨ | សភនវស | N/A |
| **២០១៩** | | | | |
| 7 | ០៥-០៦ មករា ២០១៩ | ទស្សនកិច្ចសិក្សាទៅខេត្តកំពត និងសកម្មភាពសង្គម | ខេត្តកំពត | 86 |
| 8 | ២១-២៤ មេសា ២០១៩ | ទស្សនកិច្ចសិក្សានៅប្រទេសម៉ាឡេស៊ី | ប្រទេសម៉ាឡេស៊ី | 21 |
| 9 | ០៧ កក្កដា ២០១៩ | សកម្មភាពសង្គម និងទស្សនកិច្ចសិក្សាសាលាបឋមសិក្សាត្រពាំងរកា និងភ្នំព្រះរាជទ្រព្យ | ខេត្តកណ្តាល | 206 |
| 10 | ២៥ ធ្នូ ២០១៩ | ទស្សនកិច្ចសិក្សានៅក្រុមប្រឹក្សាធម្មនុញ្ញ | ភ្នំពេញ | 90 |

| | | | | |
|---|---|---|---|---|
| ២០២០ | | | | |
| 11 | ១៨-២០ មករា ២០២០ | ទស្សនកិច្ចសិក្សា និងសកម្មភាពសង្គមនៅខេត្តមណ្ឌលគិរី | ខេត្តមណ្ឌលគិរី | 82 |
| ២០២១ | | | | |
| 12 | ២៦ កញ្ញា ២០២១ | សកម្មភាពសង្គម នៅសាលាបឋមសិក្សាគងជ័យ ឃុំព្រៃកកុយ ស្រុកកងមាស | ខេត្តកំពង់ចាម | 4 (អ្នកតំណាង) |
| ២០២២ | | | | |
| 13 | ៣១ មីនា ២០២២ | សកម្មភាពសង្គមនៅវិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី | ភ្នំពេញ | 16 |
| 14 | ២៨-២៩ សីហា ២០២២ | សកម្មភាពសង្គមនៅសហគមន៍ត្រពាំងសង្កែ | កំពត | 125 |
| ២០២៣ | | | | |
| 15 | ២៤-២៦ កុម្ភៈ ២០២៣ | សកម្មភាពសង្គម និងទស្សនកិច្ចសិក្សានៅវិទ្យាល័យហ៊ុនសែនអង្គរធំ | ខេត្តសៀមរាប | 64 |
| 16 | ២៧ មិថុនា ២០២៣ | ទស្សនកិច្ចសិក្សានៅក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ (C.I.C) | ភ្នំពេញ | 31 |
| 17 | ២៧ សីហា ២០២៣ | សកម្មភាពសង្គម និងទស្សនកិច្ចសិក្សាទៅសាលាមតេយ្យសហគមន៍ភូមិអង្គស្វាយទូ | ខេត្តព្រៃវែង | 136 |


អង្គរវត្ត, ២៤-៤៦ កុម្ភៈ ២០២៣


ខេត្តព្រៃវែង, ២៧ សីហា ២០២៣


ខេត្តព្រៃវែង, ២៧ សីហា ២០២៣

## ៥.២. សកម្មភាពចុះជួយសហគមន៍របស់សាលាក្រោយបរិញ្ញាបត្រ

ចាប់តាំងពីឆ្នាំ២០១៨មក សាលាក្រោយបរិញ្ញាបត្របានបង្កើតក្លឹបច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីជំរុញសកម្មភាពចុះជួយសហគមន៍។ សមាជិកក្លឹបគឺជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រដែលស្ម័គ្រចិត្តចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយច្បាប់ចរាចរណ៍ និងត្រូវបានជ្រើសរើសជា២ដំណាក់កាល រួមមាន៖ តាមរយៈការពិនិត្យពាក្យសុំ និងតាមរយៈការធ្វើសម្ភាស។

| លរ | កាលបរិច្ឆេទ | សកម្មភាព | ទីកន្លែង | ចំនួនអ្នកចូលរួម |
|---|---|---|---|---|
| **២០១៨** | | | | |
| 1 | ២៨ កុម្ភៈ ២០១៨ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យជាស៊ីមបឹងកេងកង | 89 |
| 2 | ១៥ មីនា ២០១៨ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យហ៊ុនសែនប៊ុនរ៉ានីវត្តភ្នំ | 78 |
| 3 | ២៩ ឧសភា ២០១៨ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យហ៊ុនសែនប៊ុនរ៉ានីវត្តភ្នំ | 100 |
| 4 | ១៤ កក្កដា ២០១៨ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | សភានវស | 45 |
| 5 | ០៧-០៨ ធ្នូ ២០១៨ | ការសំដែងរឿងអប់រំខ្លីអំពីច្បាប់ចរាចរណ៍ផ្លូវគោករបស់សមាជិកក្លឹបច្បាប់ចរាចរណ៍ផ្លូវគោក | សភានវស | |
| **២០១៩** | | | | |
| 6 | ២៩ មករា ២០១៩ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យទួលប្រាសាទសែនសុខ | 75 |
| 7 | ២៦ កុម្ភៈ ២០១៩ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យហ៊ុនសែនប៊ុនរ៉ានីវត្តភ្នំ | 122 |
| 8 | ១៤ មីនា ២០១៩ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យជាស៊ីមបឹងកេងកង | 90 |
| 9 | ១៩ មីនា ២០១៩ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យបឹងត្របែក | 94 |
| 10 | ២៩ មិថុនា ២០១៩ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | សភានវស | 138 |
| 11 | ១១ ធ្នូ ២០១៩ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | សាលាវេស្ទើន អន្តរជាតិ | 113 |

| | | | | |
|---|---|---|---|---|
| ២០២០ | | | | |
| 11 | ១០ មករា ២០២០ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យទួលប្រាសាទសែនសុខ | 126 |
| 12 | ៤ កុម្ភៈ ២០២០ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យបឹងត្របែក | 97 |
| 13 | ១២ កុម្ភៈ ២០២០ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យជាស៊ីមបឹងកេងកង | 77 |
| 14 | ១៨ កុម្ភៈ ២០២០ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យហ៊ុនសែនប៊ុនរ៉ានីផ្សារដើមថ្កូវ | 177 |
| 15 | ០៣ មីនា ២០២០ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យហ៊ុនសែនប៊ុនរ៉ានីវត្តភ្នំ | 191 |
| ២០២១ | | | | |
| 16 | ២០២១ | ផ្សព្វផ្សាយជាសារតាម Facebook | | |
| ២០២២ | | | | |
| 17 | ២០២២ | ផ្សព្វផ្សាយជាវីដេអូតាម Facebook | | |
| ២០២៣ | | | | |
| 18 | ១៩ មករា ២០២៣ | ការបណ្តុះបណ្តាលអ្នកបើកកង់បី និងការអនុវត្ត | ភ្នំពេញ | 33 |
| 19 | ២២ មីនា ២០២៣ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យហ៊ុនសែនស្អាង | 86 |
| 20 | ១៦ មិថុនា ២០២៣ | ការផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក | វិទ្យាល័យហ៊ុនសែនមិត្តភាព | 215 |
| ២០២៤ | | | | |
| 21 | ១០ សីហា ២០២៤ | យើងទាំងអស់គ្នាដើម្បីស្នាមញញឹមកុមារភ្នំរលៀង | ខេត្តកំពត | 28 |
| 22 | ១១ សីហា ២០២៤ | ការចូលរួមកសាង និងជាវព្រះពុទ្ធប្បដិមាលើភ្នំបូកគោ | ខេត្តកំពត | 28 |
| 23 | ១៣ មករា ២០២៤ | កសាងខ្ទះអង្គុយនៅអនុវិទ្យាល័យសន្សំកុសល | ខេត្តកំពង់ស្ពឺ | |
| 24 | ០២ កក្កដា ២០២៤ | ប្រគេនចង្ហាន់ និងតិយវត្ថុ ដល់សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌ | ខេត្តសៀមរាប | |
| 25 | ០៧ កញ្ញា ២០២៤ | ដាំកូនឈើចំនួន៧០០ដើម នៅក្នុងបរិវេណវត្តចន្ទមូលី នៅភូមិផ្អាវ ឃុំផ្អាវ ស្រុកបាធាយ ខេត្តកំពង់ចាម | ខេត្តកំពង់ចាម | |

យើងទាំងអស់គ្នាដើម្បីស្នាមញញឹមកុមារភ្នំរលៀង ១០ សីហា ២០២៤




ការចូលរួមកសាង និងជាវព្រះពុទ្ធប្បដិមាលើភ្នំបូកគោ ១១ សីហា ២០២៤



កសាងខ្ទះអង្គុយនៅអនុវិទ្យាល័យសន្សំកុសល ១៣ មករា ២០២៤



ប្រគេនចង្ហាន់ និងតិយវត្ថុ ដល់សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌ ០២ កក្កដា ២០២៤



ប្រគេនចង្ហាន់ និងតិយវត្ថុ ដល់សមណសិស្សពុទ្ធិកវិទ្យាល័យរាជបូណ៌ ០២ កក្កដា ២០២៤



ដាំកូនឈើចំនួន៧០០ដើម នៅក្នុងបរិវេណវត្តចន្ទមូលី ០៧ កញ្ញា ២០២៤



# ផ្នែកទី៥
# ថ្នាក់ដឹកនាំ និងមន្ត្រី

# ៧. ថ្នាក់ដឹកនាំសាលាក្រោយបរិញ្ញាបត្រ




**សាស្ត្រាចារ្យជំនួយ បណ្ឌិត ទិន ហេង**

**នាយកសាលាក្រោយបរិញ្ញាបត្រ**

លេខទូរស័ព្ទ៖ 092 317 327

Email: hengtin4@gmail.com





**លោក ម៉ៅ បុណ្ណា**

**នាយករងសាលាក្រោយបរិញ្ញាបត្រ**

លេខទូរស័ព្ទ៖ 012 697295

Email: bonnamao@yahoo.fr





**លោក ស្រ៊ិន ឌីណា**

ប្រធានការិយាល័យបណ្តុះបណ្តាល
ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

លេខទូរស័ព្ទ៖ 016 555736

Email: dynasrin@yahoo.com

## ២. មន្ត្រីទទួលបន្ទុកការងាររបស់សាលាក្រោយបរិញ្ញាបត្រ



**លោក ទេព បូណាឌុធ**

ទទួលបន្ទុក៖

- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ផ្នែករដ្ឋបាលសាធារណៈ
- ការងារសញ្ញាបត្រ និង
- ព័ត៌មាន

លេខទូរស័ព្ទ៖ 016 787828



**បណ្ឌិត ស្រៀង ស៊ីម**

ទទួលបន្ទុក៖

- ថ្នាក់បណ្ឌិត
- សម្របសម្រួលការងារស្រាវជ្រាវ
- ព័ត៌មាន

Tel: 092 445958



**លោកស្រី ព្រាប សុខកញ្ញា**

ទទួលបន្ទុក៖

- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ផ្នែកនីតិឯកជន
- ការងារសញ្ញាបត្រ និង
- ព័ត៌មាន

លេខទូរស័ព្ទ៖ 012 283628



**លោកស្រី ទូច កល្យាណ**

ទទួលបន្ទុក៖

- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ផ្នែកគ្រប់គ្រង និងហិរញ្ញវត្ថុ
- ការងារសញ្ញាបត្រ និង
- ព័ត៌មាន

លេខទូរស័ព្ទ៖ 077 919967



**កញ្ញា ចាន់ សំបូរ**

ទទួលបន្ទុក៖

- ថ្នាក់ត្រៀមនីតិសាស្ត្រ និងធុរកិច្ច
- សម្របសម្រួលការងារសង្គម
- ព័ត៌មាន

លេខទូរស័ព្ទ៖ 087 568108

ព័ត៌មានមកកាន់សាលាក្រោយបរិញ្ញាបត្រ៖

Email: rulegpinfo@gmail.com
Facebook: RULE Graduate School
Facebook: សាលាក្រោយបរិញ្ញាបត្រនៃ ស ភ ន វ ស



Campus Map of the Royal University of Law and Economics
Gate
Gate
Main Exit
Main Entrance
Gate
12
13
14
15
16
17
18
B
Hall A
Hall B
A
C
D
E
F
G
H
I
Library
01 A
Building A
02 B
Building B
03 C
Building C
04 D
Building D
05 E
Building E
06 F
Building F
07 G
Building G
08 H
Building H
09 I
Library-ELBBL-CSHL
10 A
Hall A
11 B
Hall B
12
Motor Parking
13
Car Parking
14
Car Parking
15
EDC Facility
16
Car Parking
17
Petanque Court
18
Volleyball Court

## លក្ខខណ្ឌជ្រើសរើសនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

- បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រនីតិសាស្ត្រ ឬបរិញ្ញាបត្រដែលមានតម្លៃស្មើ ឬជំនាញប្រហាក់ប្រហែល ឬបរិញ្ញាបត្រមុខជំនាញដទៃនិងមានបរិញ្ញាបត្ររងនៃមុខជំនាញខាងលើបន្ថែមមួយទៀត អាចចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសនីតិឯកជន ឬរដ្ឋបាលសាធារណៈ ឆ្នាំទី១បានតែម្តង។
- បេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច បរិញ្ញាបត្រធុរកិច្ច បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ឬបរិញ្ញាបត្រដែលមានតម្លៃស្មើ ឬជំនាញប្រហាក់ប្រហែល ឬបរិញ្ញាបត្រមុខជំនាញដទៃនិងមានបរិញ្ញាបត្ររងនៃមុខជំនាញខាងលើបន្ថែមមួយទៀត អាចចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រង ឬបរិញ្ញាបត្រជាន់ខ្ពស់ហិរញ្ញវត្ថុ ឆ្នាំទី១បានតែម្តង។




**អាសយដ្ឋានទាក់ទង**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
P.O.Box 842, Website: www.rule.edu.kh